ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២១



ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ

ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ និងហានិភ័យ

ប្រឈមចំពោះស្ថិរភាពហិរញ្ញវត្ថុ

# មាតិកា

**អារម្ភកថា** ..... i

**ខ្លឹមសារសង្ខេប** ..... iii

**I ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** ..... ១

១.១ ស្ថានភាពវិស័យខាងក្រៅ ..... ១

ក. សេដ្ឋកិច្ចពិភពលោក ..... ១

ខ. ជញ្ជីងទូទាត់កម្ពុជា ..... ៣

ខ.១ គណនីចរន្ត ..... ៤

ខ.២ គណនីហិរញ្ញវត្ថុ ..... ៥

គ. អត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ ..... ៧

១.២ ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ..... ១០

ក. កំណើនសេដ្ឋកិច្ច ..... ១០

ខ. វិស័យសំណង់ និងអចលនទ្រព្យ ..... ១២

គ. ស្ថានភាពអតិផរណា និងរូបិយវត្ថុ ..... ១៤

ឃ. វិស័យសារពើពន្ធ ..... ១៦

**II ប្រព័ន្ធធនាគារ៖ ប្រតិបត្តិការ និងស្ថិរភាព** ..... ២១

២.១ ទិដ្ឋភាពទូទៅប្រព័ន្ធធនាគារ ..... ២២

២.២ គ្រឹះស្ថានធនាគារពាណិជ្ជ ..... ២៤

ក. អន្តរការីយកម្មឥណទាននិងហានិភ័យឥណទាន ..... ២៤

ខ. ស្ថានភាពសន្ទនីយភាពនិងប្រភពមូលនិធិ ..... ៣៤

គ. លទ្ធភាពស្វែងរកប្រាក់ចំណេញនិងសាធនភាព ..... ៣៦

២.៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ៤០

ក. ប្រតិបត្តិការឥណទាន ..... ៤០

ខ. គុណភាពឥណទាន ..... ៤១

គ. ស្ថានភាពសន្ទនីយភាព និងមូលនិធិ ..... ៤២

ឃ. លទ្ធភាពស្វែងរកប្រាក់ចំណេញ ..... ៤៣

ង. ស្ថានភាពដើមទុន ..... ៤៤

២.៤ ធនាគារឯកទេស ..... ៤៧

**III វិស័យហិរញ្ញវត្ថុមិនមែនធនាគារ** ..... ៥១
៣.១ ទីផ្សារទ្រព្យសកម្ម ..... ៥១
ក. ទីផ្សារមូលធន ..... ៥១
ខ. ផ្សារមូលបត្របំណុល ..... ៥៤
៣.២ វិស័យធានារ៉ាប់រង ..... ៥៥
**IV ប្រព័ន្ធទូទាត់សងប្រាក់៖ ការអភិវឌ្ឍថ្មីៗ** ..... ៥៧

# អារម្ភកថា

សកម្មភាពសេដ្ឋកិច្ចពិភពលោកនិងក្នុងស្រុកបានងើបឡើងវិញក្នុងឆ្នាំ២០២១ បើទោះបីជាមានការលេចឡើងនូវមេរោគជំងឺកូវីដ-១៩ប្រភេទថ្មី និងមានអត្រាឆ្លងខ្ពស់ក៏ដោយ ខណៈការងើបឡើងវិញនៃសេដ្ឋកិច្ច មានភាពមិនស្មើសាច់និងផុយស្រួយ។ កត្តាអំណោយផលនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក និងការជំរុញការចាក់វ៉ាក់សាំងឆាប់រហ័ស បានជួយឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញក្នុងទម្រង់អក្សរ V ជាមួយនឹងកំណើនសេដ្ឋកិច្ចពី -៣,១% ក្នុងឆ្នាំ២០២០ ដល់ ៣% ក្នុងឆ្នាំ២០២១។ ការកើនឡើងនេះត្រូវបានគាំទ្រដោយការនាំចេញផលិតផលកម្មន្តសាលនិងកសិកម្ម ព្រមទាំងកំណើនការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ក៏ដូចជាការជួញដូរដុំនិងរាយ ខណៈវិស័យទេសចរណ៍បន្តមានការធ្លាក់ចុះ ដោយចំនួនភ្ញៀវអន្តរជាតិបានធ្លាក់ចុះ -៨៥% ក្នុងឆ្នាំ២០២១។

ភាពធន់និងរឹងមាំនៃប្រព័ន្ធធនាគារ ដែលគាំទ្រដោយគោលនយោបាយគាំទ្រ និងវិធានការ និងបទប្បញ្ញត្តិអនុគ្រោះរបស់ធនាគារជាតិនៃកម្ពុជា បានបន្តដើរតួនាទីជាអន្តរការីយកម្មដ៏សំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានចាំបាច់ដល់អាជីវកម្មនិងក្រុមគ្រួសារ។ សូចនាករសំខាន់ៗរបស់វិស័យធនាគារមានភាពល្អប្រសើរ ឆ្លុះបញ្ចាំងតាមរយៈភាពរឹងមាំនៃទ្រនាប់ដើមទុននិងសន្ទនីយភាព។ ទ្រព្យសកម្មសរុបនៃប្រព័ន្ធធនាគារបានកើនឡើង ១៨% ដល់ ២៨១,៥ ទ្រីលានរៀល ស្មើនឹងប្រមាណ ២៥០% នៃ ផ.ស.ស. ក្នុងឆ្នាំ២០២១។ កំណើនឥណទានមានភាពរឹងមាំក្នុងអត្រា ២៣,៥% និងបានបែងចែកទៅកាន់វិស័យផ្សេងៗក្នុងសេដ្ឋកិច្ច ស្របពេលដែលគុណភាពទ្រព្យសកម្មនៅបន្តមានភាពល្អប្រសើរ។ គោលនយោបាយរៀបចំឥណទានឡើងវិញរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់អតិថិជនដែលទទួលរងផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩ បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញគិតជាទឹកប្រាក់ ៤,៩ ប៊ីលានដុល្លារអាមេរិក ទៅដល់អតិថិជន ៣១០.៧៤៦ គណនី ចាប់តាំងពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩។ ទោះយ៉ាងណា ជាមួយនឹងការរំពឹងទុកនៃស្ថានភាពប្រសើរឡើងវិញ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមដកចេញជាបណ្តើរៗនូវវិធានការ និងគោលនយោបាយគាំទ្រមួយចំនួន។

ប្រទេសកម្ពុជាបានបើកចំហយ៉ាងពេញលេញដោយមិនមានការរឹតបន្តឹងការធ្វើដំណើរ ដោយសារអត្រានៃការចាក់វ៉ាក់សាំងមានកម្រិតខ្ពស់ និងចំនួនឆ្លងមានតិចតួច។ ទាក់ទងនឹងវិស័យពាណិជ្ជកម្មនិងការវិនិយោគ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងការដាក់ឱ្យប្រើប្រាស់នូវច្បាប់វិនិយោគថ្មី។ ទោះយ៉ាងណា ជំងឺកូវីដ-១៩នេះនៅមិនទាន់បញ្ចប់នៅឡើយ ហើយហានិភ័យនៃការវិវត្តរបស់ជំងឺនេះនៅតែមាន។ ជម្លោះរវាងអ៊ុយក្រែន-រុស្ស៊ី និងការបិទខ្ទប់ក្នុងប្រទេសចិន ក៏បានដាក់សម្ពាធលើកំណើនសេដ្ឋកិច្ចពិភពលោកផងដែរ។ អតិផរណា បានបន្តកើនឡើងបន្ថែមទៅលើអត្រាដែលខ្ពស់ស្រាប់រួចមកហើយនៅពេលមានអតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការដោយសារជំងឺកូវីដ-១៩។ នៅពេលដែលធនាគារកណ្តាលនៅក្នុងប្រទេសអភិវឌ្ឍន៍ព្យាយាមទប់ទល់នឹងអតិផរណាតាមរយៈការដំឡើងអត្រាការប្រាក់ ប្រទេសកំពុងលូតលាស់អាចជួបប្រទះនឹងភាពរឹតត្បិតនៃស្ថានភាពហិរញ្ញវត្ថុ លំហូរចេញនៃមូលធនកាន់តែច្រើន និងរូបិយវត្ថុក្នុងស្រុកធ្លាក់ថ្លៃ។

ខណៈពេលដែលយើងរៀនរស់នៅជាមួយនឹងជំងឺកូវីដ-១៩ សេដ្ឋកិច្ចពិភពលោកបាន និងកំពុងជួបប្រទះបញ្ហាប្រឈមជាច្រើន និងមានទស្សនវិស័យមិនច្បាស់លាស់។ ប្រឈមនឹងភាពមិនប្រាកដប្រជានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងជិតស្និទ្ធលើការវិវត្តក្នុងវិស័យធនាគារ និងសេដ្ឋកិច្ចជារួម ហើយនឹងត្រៀមខ្លួនជាស្រេចក្នុងការដាក់ចេញវិធានការចាំបាច់នានា ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចក្នុងស្រុក និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។

ដើម្បីរក្សាប្រព័ន្ធធនាគារឱ្យមានភាពរឹងមាំនិងស្ថិរភាព ធនាគារជាតិនៃកម្ពុជាបានពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួនជាបន្តបន្ទាប់ក្នុងការវិភាគ តាមដាន និងកាត់បន្ថយហានិភ័យដែលអាចកើតមានចំពោះស្ថិរភាពហិរញ្ញវត្ថុ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានកែលម្អនិងពង្រឹងរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ (FSR) ដែលជារបាយការណ៍ប្រចាំឆ្នាំដ៏សំខាន់មួយ ដោយផ្តោតជាចម្បងលើការវិវត្តនិងវាយតម្លៃហានិភ័យនៃវិស័យធនាគារដែលជាវិស័យធំជាងគេក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំងការវាយតម្លៃលើសេដ្ឋកិច្ចជារួមផងដែរ។ តាមរយៈការបោះផ្សាយរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ឆ្នាំ២០២១នេះ ធនាគារជាតិនៃកម្ពុជាសង្ឃឹមថា របាយការណ៍នេះនឹងផ្តល់ការវាយតម្លៃកាន់តែល្អប្រសើរនិងស៊ីជម្រៅជាងមុនទៅលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទីផ្សារហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់នៅកម្ពុជា ស្របពេលដែលធនាគារជាតិនៃកម្ពុជាខិតខំពង្រឹងតម្លាភាព និងអនុញ្ញាតឱ្យភាគីពាក់ព័ន្ធទាំងអស់ យល់ច្បាស់អំពីការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២

ទេសាភិបាល

ជា.ចាន់តូ

# ខ្លឹមសារសង្ខេប

**នៅឆ្នាំ២០២១ សេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញ ប៉ុន្តែក្នុងល្បឿនខុសគ្នា និងប្រឈមបញ្ហាជាច្រើន។** សេដ្ឋកិច្ចពិភពលោកបានកើន ៦,១% ប៉ុន្តែអត្រាកំណើនមានភាពខុសគ្នាទៅតាមប្រទេសនិងតំបន់។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍បានងើបឡើងលឿនជាងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ដោយសារអត្រាចាក់វ៉ាក់សាំងមានកម្រិតខ្ពស់និងលំហនយោបាយមានទំហំធំជាង។ សេដ្ឋកិច្ចអាស៊ានសម្រេចបានអត្រាកំណើនត្រឹម ២,៩% ដោយសារផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រភេទឌែលតា។ ក្រៅពីវិបត្តិកូវីដ-១៩ សេដ្ឋកិច្ចពិភពលោកនិងតំបន់បានប្រឈមនឹងបញ្ហាមួយចំនួនទៀត ដែលធ្វើឱ្យការងើបឡើងនៃសេដ្ឋកិច្ចថមថយ។ ជាក់ស្តែង ការកើនឡើងអតិផរណា អាចបង្កឱ្យស្ថានភាពហិរញ្ញវត្ថុសកលមានភាពរឹតត្បិតឆាប់រហ័ស ដែលប៉ះពាល់ដល់ដំណើរការស្តារសេដ្ឋកិច្ចឡើងវិញ ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍន៍។

**ការងើបឡើងសន្សឹមៗនៃសេដ្ឋកិច្ចពិភពលោក បានគាំទ្រដល់ការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជាដែលពឹងផ្អែកខ្លាំងលើកត្តាខាងក្រៅ។** នៅឆ្នាំ២០២១ សេដ្ឋកិច្ចកម្ពុជាបានកើនឡើង ៣% ដែលគាំទ្រជាចម្បងដោយកំណើននៃការនាំចេញ ២៥,១% (មិនរាប់បញ្ចូលមាស) ស្របពេលដែលអត្រាចាក់វ៉ាក់សាំងខ្ពស់បានគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសឱ្យងើបឡើងជាលំដាប់ផងដែរ។ វិស័យសំណង់និងអចលនទ្រព្យបានងើបឡើងក្នុងល្បឿនយឺត ខណៈដែលវិស័យកសិកម្មបន្តកើនឡើង ១,១%។ ទោះយ៉ាងណា សន្ទុះកំណើនតាមវិស័យមានភាពខុសគ្នា ដោយសារវិស័យទេសចរណ៍នៅតែបន្តទទួលរងផលប៉ះពាល់ ជាមួយការធ្លាក់ចុះភ្ញៀវអន្តរជាតិ -៨៥%។ ការកើនឡើងនៃករណីឆ្លងជំងឺកូវីដ-១៩ នៅកម្ពុជានិងបណ្តាប្រទេសផ្សេងទៀត បានជះឥទ្ធិពលដល់បរិយាកាសវិនិយោគឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃការបង្វែរប្រាក់ពីពលករកម្ពុជានៅក្រៅប្រទេស -៩,២% និងលំហូរវិនិយោគផ្ទាល់ពីបរទេស -៣,៩%។

**ស្ថានភាពសារពើពន្ធនិងរូបិយវត្ថុបន្តមានភាពអំណោយផល ដើម្បីជំរុញការងើបឡើងនៃសេដ្ឋកិច្ច។** រាជរដ្ឋាភិបាលកម្ពុជា បានបន្តដាក់ចេញវិធានការអន្តរាគមន៍ ដែលគិតជាទឹកប្រាក់សរុបប្រមាណ ២,៣ ប៊ីលានដុល្លារអាមេរិក ចាប់តាំងពីការដាក់ចេញលើកដំបូងក្នុងឆ្នាំ២០២០ ដើម្បីគាំទ្រដល់ក្រុមគ្រួសារក្រីក្រនិងអាជីវកម្មដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិនេះ។ ស្ថានភាពរូបិយវត្ថុក៏មានភាពអំណោយផលដែលបានសម្រួលដល់លំហូរឥណទានទៅផ្គត់ផ្គង់សេដ្ឋកិច្ចក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ ខណៈដែលការរៀបចំឥណទានឡើងវិញត្រូវបានអនុញ្ញាតបន្ត ដើម្បីកាត់បន្ថយបន្ទុកក្រុមគ្រួសារនិងក្រុមហ៊ុន-សហគ្រាស។

**បើទោះបីជាមានការអនុវត្តគោលនយោបាយវិត្ថារកម្មក៏ដោយ ស្ថានភាពបំណុលរាជរដ្ឋាភិបាលនិងអតិផរណាមានកម្រិតទាប។** បំណុលរាជរដ្ឋាភិបាលបានកើនឡើង ៧,៧% ដែលបានធ្វើឱ្យអនុបាតបំណុលធៀបនឹងផលិតផលក្នុងស្រុកសរុបស្មើនឹង ៣៦,៤% ប៉ុន្តែកម្រិតបំណុលនេះបន្តមាននិរន្តរភាព។ អតិផរណាមានកម្រិតទាបត្រឹម ២,៩% ដោយសារកំណើនយឺតនៃថ្លៃម្ហូបអាហារនិងអតិផរណាស្នូល ខណៈដែលការផ្គត់ផ្គង់រូបិយវត្ថុបានត្រឹមត្រូវ គួបផ្សំនឹងស្ថិរភាពអត្រាប្តូរប្រាក់ដែលបានរួមចំណែកដល់ការរក្សាបាននូវកម្រិតទាបនៃអត្រាអតិផរណា។

**ធនាគារជាតិនៃកម្ពុជាបានអន្តរាគមន៍យ៉ាងសកម្មលើទីផ្សារប្ដូរប្រាក់ ដើម្បីរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ ស្របពេលដែលទុនបម្រុងអន្តរជាតិបន្តមានកម្រិតខ្ពស់គ្រប់គ្រាន់។** ក្នុងឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកប្រមាណ ៦០០ លានដុល្លារអាមេរិក ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអាជីវករប្ដូរប្រាក់ ដើម្បីរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ដែលបានទទួលរងសម្ពាធពីការធ្លាក់ចុះនៃវិស័យទេសចរណ៍និងការបង្វែរប្រាក់របស់ពលករកម្ពុជាពីក្រៅប្រទេស រួមជាមួយនឹងបញ្ហាប្រឈមផ្សេងទៀតក្នុងដំណាក់កាលដែលសេដ្ឋកិច្ចកំពុងងើបឡើងពីវិបត្តិ និងការអូសបន្លាយនៃជំងឺកូវីដ-១៩។ អត្រាប្ដូរប្រាក់ប្រចាំឆ្នាំគិតជាមធ្យមស្មើនឹង ៤.០៩៩ រៀលក្នុងមួយដុល្លារអាមេរិក ដែលបានថយថ្លៃប្រហែល ១% ធៀបនឹងឆ្នាំ២០១៩។ ទុនបម្រុងអន្តរជាតិបានថមថយ -៥% ធៀបនឹងឆ្នាំ២០២០ ប៉ុន្តែអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានរហូតដល់ ៨,៣ខែ ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

**ប្រព័ន្ធធនាគារមានភាពរឹងមាំនិងធន់ ដែលបានបន្តផ្ដល់ហិរញ្ញប្បទានចាំបាច់ដល់ការស្ដារសេដ្ឋកិច្ចឡើងវិញពីវិបត្តិកូវីដ-១៩។** ទ្រព្យសកម្មនិងប្រាក់បញ្ញើនៃប្រព័ន្ធធនាគារបានកើនឡើង ១៨% និង ១៧,៧% រៀងគ្នា។ ទន្ទឹមនេះ ឥណទានបានកើនឡើងខ្លាំងដល់ ២៣,៥%។ នៅក្នុងប្រព័ន្ធធនាគារ ទ្រព្យសកម្មធនាគារពាណិជ្ជមានចំនួនច្រើនជាង ៨៥% នៃទ្រព្យសកម្មសរុប បន្ទាប់មកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFIs)។

**ឥណទានធនាគារមានកំណើនរឹងមាំនិងត្រូវបានបែងចែកទៅកាន់វិស័យនានា។** ឥណទានធនាគារបានកើនឡើង ២៦,៨% ដល់ ១៥៥,៣ ទ្រីលានរៀល ដែលភាគច្រើនត្រូវបានផ្ដល់ដល់វិស័យជួញដូរាយ ការទិញផ្ទះ ការជួញដូរដុំ សំណង់ និងអចលនទ្រព្យ ជាដើម។ ទ្រព្យសកម្មមានគុណភាពល្អ និងបន្តមានភាពប្រសើរឡើង ដោយសារអនុបាតឥណទានមិនដំណើរការ បានធ្លាក់ចុះមកត្រឹម ១,៨%។

**ស្ថានភាពសន្ទនីយភាពនិងដើមទុនក្នុងវិស័យធនាគារមានកម្រិតល្អ។** អនុបាតក្របខ័ណ្ឌសន្ទនីយភាពមានកម្រិតស្មើនឹង ១៥១,៦% ខ្ពស់ជាងកម្រិត ១០០% ក្នុងបទប្បញ្ញត្តិ។ អនុបាតសាធនភាពស្មើនឹង ២៣% ខ្ពស់ជាងកម្រិត ១៥% ក្នុងបទប្បញ្ញត្តិ និងឆ្លុះបញ្ចាំងពីភាពធន់របស់វិស័យធនាគារក្នុងការប្រឈមនឹងការខាតបង់ក្នុងករណីទទួលរងផលប៉ះពាល់ណាមួយ ដែលមិនត្រូវបានរំពឹងទុកជាមុន។ ទន្ទឹមនេះ ប្រាក់ចំណេញក្នុងវិស័យធនាគារក៏បន្តមាននិរន្តរភាពល្អ។

**វិស័យមីក្រូហិរញ្ញវត្ថុបានបន្តគាំទ្រដល់ក្រុមគ្រួសារ វិស័យកសិកម្ម និងសហគ្រាសធុនតូច និងមធ្យម ខណៈដែលគុណភាពឥណទានបន្តមានគុណភាពល្អ។** ឥណទានមីក្រូហិរញ្ញវត្ថុបានកើនឡើង ២៦% ក្នុងឆ្នាំ២០២១ ធៀបនឹង ១២,៥% ក្នុងឆ្នាំ២០២០ ដែលភាគច្រើនត្រូវបានបែងចែកដល់ក្រុមគ្រួសារ ការជួញដូរ កសិកម្ម សេវាកម្ម និងវិស័យផ្សេងទៀត។ អនុបាតឥណទានមិនដំណើរការបានកើនឡើងបន្តិចធៀបនឹងឆ្នាំ២០២០ ប៉ុន្តែនៅមានគុណភាពល្អ ក្នុងកម្រិត ២,៥% ក្នុងឆ្នាំ២០២១។

**ក្នុងអំឡុងវិបត្តិកូវីដ-១៩ សន្ទនីយភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) មានភាពគ្រប់គ្រាន់ ដើម្បីទប់ទល់នឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ។** អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ MDIs មានកម្រិត ១៦០% នៅចុងឆ្នាំ២០២១ ដែលលើសពីកម្រិតបទប្បញ្ញត្តិ។ អនុបាតសាធនភាពក៏មានកម្រិតខ្ពស់ ១៨,២% សម្រាប់ MDIs និង ៤០,៧% សម្រាប់ MFIs។

**វិស័យហិរញ្ញវត្ថុមិនមែនធនាគារបានបន្តរីកចម្រើនឡើងជាលំដាប់។** ទោះជាស្ថិតក្នុងអំឡុងពេលនៃការរាលដាលជំងឺកូវីដ-១៩ ទីផ្សារភាគហ៊ុនកម្ពុជាបានបន្ថែមក្រុមហ៊ុនចំនួនមួយនៅឆ្នាំ២០២១ ដោយក្រុមហ៊ុនមួយបានចុះបញ្ជីក្នុងប្រភេទទីផ្សារកំណើនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាលើកដំបូងចាប់តាំងពីការបង្កើតប្រភេទទីផ្សារនេះនៅឆ្នាំ២០១៥។ ជាមួយគ្នានេះ ទីផ្សារមូលបត្របំណុលបានក្លាយជាប្រភពស្វែងរកមូលនិធិជារូបិយវត្ថុដ៏សំខាន់មួយ សម្រាប់ហិរញ្ញប្បទានដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាក្រុមហ៊ុនឯកជននានា។ នៅចុងឆ្នាំ២០២១ មូលធនូបនីយកម្មទីផ្សារមានតម្លៃស្មើនឹង ៥៩២,៤ ប៊ីលានរៀល ដែលក្នុងនោះ ៣៧៧,៩ ប៊ីលានរៀលជាមូលបត្របំណុលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ វិស័យធានារ៉ាប់រងត្រូវបានរំពឹងថានឹងបន្តរីកចម្រើនផងដែរ ជាមួយការកើនឡើងនៃបុព្វលាភធានារ៉ាប់រង ចំនួន ១០,២% ដល់ ១,២ ទ្រីលានរៀល រាប់បញ្ចូលទាំងការធានារ៉ាប់រងទូទៅ និងអាយុជីវិត។

**ការអភិវឌ្ឍប្រព័ន្ធទូទាត់ក្នុងទសវត្សរ៍ចុងក្រោយបានគាំទ្រសកម្មភាពសេដ្ឋកិច្ច ក្នុងអំឡុងវិបត្តិកូវីដ-១៩។** ស្របតាមតម្រូវការទីផ្សារនៅកម្ពុជាដែលមានចំនួនប្រជាជនវ័យក្មេងច្រើន និងមានអត្រាប្រើប្រាស់ទូរស័ព្ទចល័តនិងអ៊ីនធឺណេតខ្ពស់ ធនាគារជាតិនៃកម្ពុជាបានបង្កភាពងាយស្រួល និងបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានលក្ខណៈអំណោយផលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍសេវាទូទាត់ឌីជីថលប្រកបដោយភាពច្នៃប្រឌិត។ ដោយសារប្រព័ន្ធទូទាត់មានលក្ខណៈទំនើប រាជរដ្ឋាភិបាលអាចផ្តល់ជំនួយសង្គមទាន់ពេលវេលាដល់កម្មករនិយោជិតនិងក្រុមគ្រួសារ ដែលទទួលរងផលប៉ះពាល់ តាមរយៈប្រព័ន្ធផ្ទេរប្រាក់ឌីជីថល។ ការទូទាត់តាមប្រព័ន្ធឌីជីថលបានគាំទ្រដល់និរន្តរភាពនៃប្រតិបត្តិការអាជីវកម្ម ក្នុងអំឡុងពេលនៃការរឹតបន្តឹងវិធានការរក្សាគម្លាតសង្គម។ គួរកត់សម្គាល់ថា នៅឆ្នាំ២០២១ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ជាប្រាក់រៀលនិងដុល្លារអាមេរិក បានកើនឡើងខ្លាំងដល់ ៣,៨ ដងនៃផលិតផលក្នុងស្រុកសរុប ជាមួយនឹងអត្រាកំណើន ៣៩,៥% ធៀបនឹងឆ្នាំ២០២០ ខណៈដែលចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនដល់ ១៣,៦ លានគណនី ឬស្មើនឹងជាង ៨០% នៃចំនួនប្រជាពលរដ្ឋសរុប។

## ទស្សនវិស័យ៖

**នៅឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងបន្តងើបឡើង ទោះបីជាប្រឈមនឹងហានិភ័យមួយចំនួនក៏ដោយ។** ស្របតាមទស្សនវិស័យសេដ្ឋកិច្ចពិភពលោកនិងតំបន់ សេដ្ឋកិច្ចកម្ពុជាអាចកើនឡើងក្នុងរង្វង់ ៥% ដែលគាំទ្រដោយចម្បងដោយការនាំចេញផលិតផលកម្មន្តសាល កសិកម្ម ការដឹកជញ្ជូន និងទូរគមនាគមន៍។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសចិន កូរ៉េ និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (RCEP) នាពេលថ្មីៗនេះ នឹងអាចទាក់ទាញការវិនិយោគនិងជំរុញការនាំចេញរបស់កម្ពុជាបន្ថែមទៀត។ ជាមួយការបន្ធូរបន្ថយជាលំដាប់នៃការរឹតត្បិតការធ្វើដំណើរ ដោយសារយុទ្ធនាការចាក់វ៉ាក់សាំងឆាប់រហ័សរួមបញ្ចូលទាំងការចាក់វ៉ាក់សាំងដូសជំរុញ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនឹងបន្តងើបឡើង ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈសន្ទស្សន៍ធ្វើដំណើរចល័តរបស់ Google។ ចំនួនភ្ញៀវអន្តរជាតិនិងភ្ញៀវទេសចរក្នុងស្រុក ក៏មានសញ្ញាកើនឡើងផងដែរនៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ ដែលនឹងគាំទ្រដល់ការងើបឡើងវិញនៃវិស័យសេវាកម្ម បន្ទាប់ពីធ្លាក់ចុះក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ខណៈដែលវិស័យសំណង់និងអចលនទ្រព្យត្រូវបានរំពឹងថានឹងងើបឡើងសន្សឹមៗ។

ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យជាច្រើនផងដែរ។ ថ្វីបើទំនាក់ទំនងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរវាងកម្ពុជាជាមួយរុស្ស៊ីនិងអ៊ុយក្រែនមិនមានទំហំគួរឱ្យកត់សម្គាល់ ការអូសបន្លាយនៃវិបត្តិរវាងប្រទេសទាំងពីរនឹងបង្កឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកជាពិសេសសហគមន៍អឺរ៉ុបដែលជាទិសដៅនាំចេញទំនិញដ៏សំខាន់របស់កម្ពុជា។ វិបត្តិនេះក៏បានដាក់បន្ទុកលើការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកនិងតំបន់ តាមរយៈការកើនឡើងថ្លៃទំនិញវត្ថុធាតុដើមលើទីផ្សារអន្តរជាតិ ដែលបង្កសម្ពាធកាន់តែខ្លាំងទៅលើអតិផរណាដែលមានកម្រិតខ្ពស់ស្រាប់ទៅហើយនៅតាមបណ្តាប្រទេសជាច្រើន។ ដោយសារកម្ពុជានាំចូលគ្រឿងឧបភោគបរិភោគជាច្រើននិងប្រេងឥន្ធនៈពីបរទេស អតិផរណាអាចកើនឡើងខ្ពស់ជាងឆ្នាំមុននិងដាក់សម្ពាធលើអំណាចទិញរបស់ក្រុមគ្រួសារ។ ទន្ទឹមនេះ ការថមថយល្បឿនសេដ្ឋកិច្ចចិននាពេលថ្មីៗ ដោយសារការអនុវត្តតឹងរ៉ឹងនៃយុទ្ធសាស្ត្រគ្មានកូវីដ ដែលនាំទៅដល់ការបិទខ្ទប់ញឹកញាប់នៅក្នុងតំបន់ជាច្រើននិងការថមថយនៃវិស័យអចលនទ្រព្យចិន អាចប៉ះពាល់ដល់ការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកលើការវិនិយោគនិងការនាំចូលវត្ថុធាតុដើមពីប្រទេសចិនសម្រាប់ឧស្សាហកម្មនាំចេញ។ ជាមួយគ្នានេះ ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុសកល ដោយសារការកើនឡើងនិងអូសបន្លាយនៃអតិផរណាចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២១មក អាចនឹងប៉ះពាល់ដល់លំហូរមូលធនទៅកាន់ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ហើយអាចបន្ថយសន្ទុះសេដ្ឋកិច្ចនៅក្នុងតំបន់ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាផងដែរ។ ដោយឡែក ទោះបីជាអត្រាឆ្លងវីរុសអូមីក្រុងនៅកម្ពុជាមានកម្រិតទាបនិងភាពធ្ងន់ធ្ងរនៃវីរុសនេះមានកម្រិតខ្សោយយ៉ាងណាក៏ដោយ ការគំរាមកំហែងមេរោគបំប្លែងខ្លួនថ្មីនៅតែអាចកើតមាន ដរាបណាវិបត្តិកូវីដ-១៩ នៅលើសកលលោកមិនទាន់ត្រូវបានបិទបញ្ចប់ទាំងស្រុងនោះទេ។ ក្រៅពីនេះ ការបន្តឆ្លងវីរុសអូមីក្រុងនៅតាមបណ្តាប្រទេសក្នុងតំបន់អាចបង្កការរំខានដល់សកម្មភាពសេដ្ឋកិច្ចនៅប្រទេសទាំងនោះ ហើយអាចមានផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា តាមរយៈការថមថយនៃការបង្វែរប្រាក់ពីពលករក្រៅប្រទេស ទេសចរណ៍ ការវិនិយោគ និងការនាំចេញ។ ក្រៅពីនេះ ការប្រែប្រួលអាកាសធាតុក៏អាចបង្កហានិភ័យដល់វិស័យកសិកម្មផងដែរ ដែលមានភាពងាយរងគ្រោះខ្លាំងទៅនឹងអាកាសធាតុ។

**ជាមួយទស្សនវិស័យសេដ្ឋកិច្ចខាងលើ ប្រព័ន្ធធនាគារកម្ពុជាដែលបានបង្ហាញពីភាពរឹងមាំក្នុងអំឡុងវិបត្តិកូវីដ-១៩ នឹងបន្តគាំទ្រដល់ការងើបឡើងនៃសេដ្ឋកិច្ច ប៉ុន្តែត្រូវមានការថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នលើការជំរុញកំណើនសេដ្ឋកិច្ចនិងការរក្សាស្ថិរភាពហិរញ្ញវត្ថុ។** ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ប្រព័ន្ធធនាគារបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច ដូចជាការរក្សាបាននូវនិរន្តរភាពនៃកំណើនឥណទាននិងការរៀបចំឥណទានឡើងវិញ ដែលបានកាត់បន្ថយសម្ពាធវិបត្តិសុខភាពសកលមកលើសេដ្ឋកិច្ចកម្ពុជា។ ភាពធន់នៃប្រព័ន្ធធនាគារ ឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃសន្ទនីយភាពនិងដើមទុននិងកម្រិតទាបនៃឥណទានមិនដំណើរការ ក៏ត្រូវបានគាំទ្រមួយផ្នែកដោយសារវិធានការរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។ ជាមួយការងើបឡើងនៃសេដ្ឋកិច្ច លក្ខខណ្ឌហិរញ្ញវត្ថុអំណោយផលនឹងអាចត្រូវកាត់បន្ថយ ដើម្បីចៀសវាងការបង្កហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុ ទោះបីជារហូតមកទល់ពេលនេះ ហានិភ័យស្ថិតក្នុងកម្រិតទាបមិនមានសញ្ញាគួរឱ្យព្រួយបារម្ភក៏ដោយ។

ទោះយ៉ាងណា ប្រព័ន្ធធនាគារក៏ប្រឈមនឹងហានិភ័យទាក់ទងនឹងភាពមិនច្បាស់លាស់នៃការវិវត្តជំងឺកូវីដ-១៩ និងការកើនឡើងនៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ដែលទាំងអស់នេះអាចបង្កើនហានិភ័យក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចនិងប៉ះពាល់ដល់ប្រាក់ចំណូលក្រុមគ្រួសារនិងក្រុមហ៊ុន-សហគ្រាស ដែលបង្កឱ្យមានការគរពូនបំណុល។ ទន្ទឹមនេះ ការថមថយប្រតិបត្តិការក្នុងទីផ្សារអចលនទ្រព្យនៅប្រទេសចិន អាចប៉ះពាល់ដល់បរិយាកាសវិនិយោគលើវិស័យអចលនទ្រព្យនិងសំណង់នៅកម្ពុជា ដែលអាចបង្កហានិភ័យដល់វិស័យធនាគារតាមរយៈឥណទានទៅកាន់វិស័យទាំងនោះ។ ការរឹតបន្តឹងលឿនជាងការរំពឹងទុកនូវលក្ខខណ្ឌហិរញ្ញវត្ថុសកលអាចប៉ះពាល់ដល់ MFIs ដែលមួយផ្នែកនៃមូលនិធិមានប្រភពមកពីបរទេស។ សម្រាប់គ្រឹះស្ថានធនាគារ និង MDIs បើទោះបីជាប្រភពមូលនិធិពឹងផ្អែកជាចម្បងលើប្រាក់បញ្ញើក្នុងប្រទេស ដែលមិនទទួលរងឥទ្ធិពលដោយផ្ទាល់ពីការកើនឡើងអត្រាការប្រាក់លើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ គ្រឹះស្ថានទាំងនេះអាចទទួលរងឥទ្ធិពលដោយប្រយោល ដោយសារសេដ្ឋកិច្ចកម្ពុជាមានទំហំតូចនិងបើកចំហខ្លាំង ធនាគារជាតិនៃកម្ពុជានឹងបន្តសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីតាមដានឱ្យបានដិតដល់លើការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចនិងរក្សាឱ្យបាននូវភាពរឹងមាំនៃប្រព័ន្ធធនាគារ។ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមបន្ថយវិធានការគាំទ្រមួយចំនួនរួចមកហើយ ដូចជាការរៀបចំឥណទានឡើងវិញ ដែលឥឡូវនេះត្រូវបានអនុញ្ញាតសម្រាប់តែអតិថិជនថ្មីប៉ុណ្ណោះ។ ការចាកចេញពីគោលនយោបាយគាំទ្រផ្សេងទៀតនឹងត្រូវបានពិចារណាដោយហ្មត់ចត់ សំដៅពង្រឹងភាពធន់និងស្ថិរភាពហិរញ្ញវត្ថុ ប៉ុន្តែការចាកចេញនឹងត្រូវប្រព្រឹត្តទៅសន្សឹមៗ ដើម្បីចៀសវាងការបង្អាក់ដល់ការងើបឡើងនៃសេដ្ឋកិច្ច និងស្របតាមការវិវត្តនៃទស្សនវិស័យនិងហានិភ័យជាក់ស្តែង។

# I ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

*ក្នុងឆ្នាំ២០២១ សេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញ ប៉ុន្តែមានភាពមិនស្មើសាច់ ដោយសារការរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់សកលនិងការបន្តរាលដាលជំងឺកូវីដ-១៩ នៅក្នុងបណ្តាប្រទេសជាច្រើន។ កំណើនសេដ្ឋកិច្ចពិភពលោកបានគាំទ្រដល់ការនាំចេញរបស់កម្ពុជា ស្របពេលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកបានកើនឡើងសន្សឹមៗ ដែលត្រូវបានគាំទ្រដោយយុទ្ធនាការចាក់វ៉ាក់សាំងឆាប់រហ័ស។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជាបានកើនឡើង ៣% ទោះបីជាមានបញ្ហាប្រឈមចម្បងៗមួយចំនួន ដូចជាការបន្តធ្លាក់ចុះលំហូរវិនិយោគផ្ទាល់បរទេស វិស័យទេសចរណ៍ និងប្រាក់បង្វែរពីពលករក្រៅប្រទេស ខណៈដែលការនាំចូលបានកើនឡើង។ បញ្ហាប្រឈមទាំងអស់នេះ បានរួមចំណែកធ្វើឱ្យអតិរេកសមតុល្យជញ្ជីងទូទាត់រួមតូចជាងមុន និងបានបង្កសម្ពាធថយថ្លៃលើអត្រាប្តូរប្រាក់រៀលផងដែរ។ ទោះយ៉ាងណា កម្រិតខ្ពស់គ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិដែលត្រូវបានគរពូនពេលកន្លងមក និងការធ្វើអន្តរាគមន៍ទាន់ពេលវេលារបស់ធនាគារជាតិនៃកម្ពុជានៅក្នុងទីផ្សារប្តូរប្រាក់ បានបន្ថយសម្ពាធអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងកម្រិតគ្រប់គ្រងបាន។ លើសពីនេះ ការរក្សាលក្ខខណ្ឌហិរញ្ញវត្ថុអំណោយផលស្របនឹងនយោបាយសារពើពន្ធវិត្ថារកម្ម បានជំរុញការងើបឡើងនៃសេដ្ឋកិច្ច។ ទោះបីគោលនយោបាយនានានៅបន្តមានលក្ខណៈវិត្ថារកម្មដើម្បីគាំទ្រកំណើនក្តី អតិផរណានៅតែមានកម្រិតទាបជាង ៣% ដែលមួយផ្នែកត្រូវបានគាំទ្រដោយការគ្រប់គ្រងបានល្អនូវការផ្គត់ផ្គង់រូបិយវត្ថុនិងស្ថិរភាពអត្រាប្តូរប្រាក់ ខណៈដែលហានិភ័យវិបត្តិបំណុលក្រៅប្រទេសរបស់កម្ពុជាបន្តមានកម្រិតទាប។*

## ១.១ ស្ថានភាពវិស័យខាងក្រៅ

### ក. សេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចពិភពលោកស្ថិតក្នុងដំណាក់-កាលស្តារឡើងវិញ ប៉ុន្តែការងើបឡើងមានភាពខុសគ្នា ហើយសន្ទុះកំណើនបានថមថយដោយសារការបន្តរាលដាលជំងឺកូវីដ-១៩។ កំណើនសេដ្ឋកិច្ចពិភពលោកបានងើបឡើងពី -៣,១% ក្នុងឆ្នាំ២០២០ ដល់ ៦,១% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ១.១) ជាចម្បងដោយសារការងើបឡើងលឿនរបស់ប្រទេសអភិវឌ្ឍន៍ដែលគាំទ្រដោយការអនុវត្តនយោបាយរូបិយវត្ថុនិងសារពើពន្ធវិត្ថារកម្មមិនធ្លាប់មានពីមុនមក និងអត្រាចាក់វ៉ាក់សាំងខ្ពស់។ ក្នុងឆ្នាំ២០២១ ប្រទេសអភិវឌ្ឍន៍មានកំណើន ៥,២% ខណៈសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងប្រទេសកំពុងអភិវឌ្ឍន៍បាន

១.១ ការព្យាករសេដ្ឋកិច្ចពិភពលោក




ប្រភព៖ ការព្យាករសេដ្ឋកិច្ចពិភពលោករបស់ IMF ចេញផ្សាយ ខែមេសា ឆ្នាំ២០២២ និងរបាយការណ៍របស់ AMRO (ឆ្នាំ២០២១ និងឆ្នាំ២០២២)

កើនឡើង ៦,៨% ដែលគាំទ្រមួយផ្នែកដោយកំណើនសេដ្ឋកិច្ចខ្ពស់នៃប្រទេសចិន ៨,១%។ សេដ្ឋកិច្ចពិភពលោកគួរតែមានកំណើនខ្ពស់ជាងនេះ ប្រសិនមិនមានការរាលដាលសាជាថ្មីនៃវលក កូវីដ-១៩ ប្រភេទឌែលតា នៅក្នុងឆមាសទី២។ ចំពោះតំបន់អាស៊ាន ដំណើរការស្តារសេដ្ឋកិច្ចឡើងវិញត្រូវបានបង្អាក់ដោយប្រទេសជាច្រើនក្នុងតំបន់បានរឹតបន្តឹងវិធានការបិទខ្ទប់ សំដៅទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យកំណើនសេដ្ឋកិច្ចងើបឡើងយឺត ត្រឹម ២,៩%។

**ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកបានទទួលរងសម្ពាធពីការកើនឡើងអតិផរណា និងបញ្ហាប្រឈមសំខាន់ៗមួយចំនួនទៀតក្រៅពីការអូសបន្លាយនៃជំងឺកូវីដ-១៩។** ការកើនឡើងថ្លៃដើមដឹកជញ្ជូន ថ្លៃទំនិញ និងថ្លៃម្ហូបអាហាររួមទាំងការរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់ និងការស្ទុះឡើងខ្លាំងនៃតម្រូវការ បាននាំឱ្យអតិផរណាកើន-ឡើងនៅក្នុងប្រទេសជាច្រើន ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ដែលអតិផរណាបានកើនឡើងខ្លាំងពី ០,៧% ក្នុងឆ្នាំ២០២០ ដល់ ៣,១% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ១.២)។ ការកើនឡើងនៃអតិផរណា ភាពតានតឹងពាណិជ្ជកម្មនិងភូមិសាស្រ្តនយោបាយ ការប្រែប្រួលអាកាសធាតុ ការកើនឡើងបំណុលសាធារណៈនិងឯកជន ការកើនឡើងនៃភាពក្រីក្រនិងវិសមភាពសង្គម គឺជាបញ្ហាប្រឈមចម្បងៗដែលបានធ្វើឱ្យការស្តារសេដ្ឋកិច្ចឡើងវិញជួបឧបសគ្គយ៉ាងខ្លាំង។ ទោះយ៉ាងណា គួរបញ្ជាក់ថា អតិផរណាក្នុងតំបន់អាស៊ានមានកម្រិតទាបត្រឹម ២,៥% នៅក្នុងឆ្នាំ២០២១ ដោយសារការងើបឡើងយឺតនៃសេដ្ឋកិច្ច ដែលធ្វើឱ្យអតិផរណាស្ថិតក្នុងកម្រិតទាប និងកំណើនថ្លៃម្ហូបអាហារស្ថិតក្នុងកម្រិតមធ្យម។

**១.២ អតិផរណាពិភពលោក**




ប្រភព ៖ ការព្យាករសេដ្ឋកិច្ចពិភពលោករបស់ IMF ចេញផ្សាយខែមេសា ឆ្នាំ២០២២

កម្រិតខ្ពស់និងការអូសបន្លាយនៃ**អតិផរណា នៅបណ្តាប្រទេសជាច្រើនអាចធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុសកលមានការរឹតបន្តឹងលឿនជាងការរំពឹងទុក ដែលក្នុងឆ្នាំ២០២១ នៅមានភាពអំណោយផលនៅឡើយ។** ធនាគារកណ្តាលភាគច្រើន មិនថានៅក្នុងប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងលូតលាស់ ឬប្រទេសកំពុងអភិវឌ្ឍន៍បានរក្សាអត្រាការប្រាក់គោលក្នុងកម្រិតមួយទាបដើម្បីគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។ ទោះយ៉ាងណា ការកើនឡើងសម្ពាធអតិផរណាបានជំរុញធនាគារកណ្តាលមួយចំនួន ជាពិសេសប្រទេសអភិវឌ្ឍន៍ឱ្យចាប់ផ្តើមធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុ។ ការអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិតមានន័យថាការចំណាយក្នុងការស្តារសេដ្ឋកិច្ចឡើងវិញត្រូវកើនឡើង ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ដែលមានលំហនយោបាយតូច។ យ៉ាងណាមិញ វិស័យធនាគារសកលនៅតែមានភាពធន់ដោយសារភាពរឹងមាំនៃដើមទុននិងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់លំហូរនៃឥណទានដើម្បីផ្តល់ហិរញ្ញប្បទានដល់សេដ្ឋកិច្ច។

## ខ. ជញ្ជីងទូទាត់កម្ពុជា

**អតិរេកសមតុល្យជញ្ជីងទូទាត់បានបន្ថយមកត្រឹម ០,៣% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) (ក្រាហ្វ ១.៣)។** កាលពីឆ្នាំ២០២០ អតិរេកជញ្ជីងទូទាត់បានរួមតូចមកត្រឹម ២,៥% នៃផ.ស.ស។ នៅឆ្នាំ២០២១ ឱនភាពគណនីចរន្តនិងដើមទុនបានកើនឡើងដល់ ៤៩,៨%នៃផ.ស.ស (៧,៥% នៃផ.ស.ស ក្នុងឆ្នាំ២០២០) បន្ទាប់ពីការកើនឡើងខ្លាំងនៃការនាំចូលទំនិញនិងឱនភាពធំនៃគណនីសេវាកម្មសុទ្ធ បានដាក់សម្ពាធបន្ថែមលើសមតុល្យជញ្ជីងទូទាត់។ ទោះយ៉ាងណា គណនីហិរញ្ញវត្ថុនៅតែអាចរក្សាសមតុល្យរួមជញ្ជីងទូទាត់ឱ្យបន្តវិជ្ជមាន ជាមួយនឹងកំណើន

**១.៣ ជញ្ជីងទូទាត់កម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បំណុលសុទ្ធ (លំហូរចូល) ចំនួន ៤៥,១% នៃ ផ.ស.ស គាំទ្រដោយគណនីវិនិយោគផ្ទាល់បរទេស និងការវិនិយោគផ្សេងទៀត។

## ខ.១ គណនីចរន្ត

**ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក បានជំរុញការនាំចេញរបស់កម្ពុជា ប៉ុន្តែការនាំចូលបានកើនឡើងខ្លាំង ដែលបានធ្វើឱ្យឱនភាពសមតុល្យពាណិជ្ជកម្មទំនិញធំជាងមុន។** ពាណិជ្ជកម្មទំនិញមានឱនភាព ៤១,៧% នៃ ផ.ស.ស ធៀបនឹង ៩,៨% នៃផ.ស.ស ក្នុងឆ្នាំ២០២០ (ក្រាហ្វ ១.៤) ដោយសារតែការកើនឡើងនៃការនាំចូលទំនិញ ៤៥,៩% រួមមានការកើនឡើងខ្លាំងនៃការនាំចូលមាស (៥ដង) បន្ទាប់មកគឺសម្ភារនិងបរិក្ខារសំណង់ (២៧,១%) វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ (២៥,២%) ប្រេងឥន្ធនៈ (៤២%) និងយានយន្ត (៥,២%)។ ទន្ទឹមនេះ ការនាំចេញបានកើនឡើង ៥,១% (មិនរាប់បញ្ចូលមាស ការនាំចេញកើនឡើង ២៥,១%) គាំទ្រដោយការកើនឡើងការនាំចេញសម្លៀកបំពាក់[១] (១៥,៤%) គ្រឿងបង្គុំអេឡិចត្រូនិក (៥២%) កង់ (១៨,៧%) និងកៅស៊ូ (៤៦,៧%)។ គួរបញ្ជាក់ផងដែរថា ប្រសិនបើមិនរាប់បញ្ចូលការនាំចេញ-នាំចូលមាស[២] នោះពាណិជ្ជកម្មទំនិញមានឱនភាព -២០% នៃ ផ.ស.ស ក្នុងឆ្នាំ២០២១ ដែលខ្ពស់ជាងបន្តិចធៀបនឹងឱនភាពនៅឆ្នាំ២០២០ (-១៧,៦%)។

**១.៤ ការនាំចេញ-នាំចូល និងសមតុល្យពាណិជ្ជកម្មទំនិញ**




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ការអូសបន្លាយការឆ្លងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជានិងក្នុងតំបន់បានធ្វើឱ្យគណនីសេវាកម្មសុទ្ធមានឱនភាពធំ ហើយប្រាក់បង្វែររបស់ពលករពីក្រៅប្រទេសបន្តធ្លាក់ចុះ។** នៅឆ្នាំ២០២១ ភ្ញៀវអន្តរជាតិចូលមកកម្ពុជាមានតែ ០,២ លាននាក់ ធ្លាក់ចុះ -៨៥% ដែលបានធ្វើឱ្យ

[១] រួមមាន៖ សម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលកាត់ដេរផ្សេងៗ
[២] ចាប់តាំងពីឆ្នាំ២០២០ ពាណិជ្ជកម្មអន្តរជាតិជាមាស មានការកើនឡើងគួរឱ្យកត់សម្គាល់

គណនីសេវាកម្មសុទ្ធមានឱនភាព ១,៤ ប៊ីលានដុល្លារអាមេរិក (-៥,៩% នៃផ.ស.ស)។ ជាមួយគ្នានេះ តម្រូវការទាបនៃចំនួនពលករទេសន្តប្រវេសន៍ដោយសារផ្ទុះឡើងនៃជំងឺកូវីដ-១៩ និងវិធានការតឹងរ៉ឹងនៅក្នុងប្រទេសដែលពលករកម្ពុជាកំពុងធ្វើការ បានធ្វើឱ្យចំនួនពលករទេសន្តប្រវេសន៍កម្ពុជាថយចុះពី ១,២ លាននាក់ ក្នុងឆ្នាំ២០២០ មក ១,១ លាននាក់ នៅឆ្នាំ២០២១[៣] និងប្រាក់បង្វើររបស់ពលករពីក្រៅប្រទេសបានថយចុះ -៩,២% មកត្រឹម ១,១ ប៊ីលានដុល្លារអាមេរិក (ក្រាហ្វ ១.៥) ជាចម្បងដោយសារការធ្លាក់ចុះប្រាក់បង្វើររបស់ពលករពីប្រទេសថៃ (-១៥,៩%) ខណៈដែលប្រាក់បង្វើររបស់ពលករពីប្រទេសកូរ៉េ ជប៉ុន និងម៉ាឡេស៊ី បានកើនឡើង ១,១% ០,៧% និង ៥,៩% រៀងគ្នា។

**១.៥ ប្រាក់បង្វើររបស់ពលករតាមប្រទេស**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ.២ គណនីហិរញ្ញវត្ថុ

**លំហូរវិនិយោគផ្ទាល់បរទេសមិនទាន់ប្រសើរឡើងវិញនៅឡើយ ដោយសារតែភាពមិនប្រាកដប្រជា ពាក់ព័ន្ធនឹងការរាលដាលជំងឺកូវីដ-១៩។** លំហូរចូលវិនិយោគផ្ទាល់បរទេសមាន ៣,៥ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដោយបានធ្លាក់ចុះ -៣,៩% (ក្រាហ្វ ១.៦)។ ការធ្លាក់ចុះវិនិយោគក្នុងខ្ទង់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានធ្វើឱ្យការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ ដែលមានប្រមាណមួយភាគបីនៃវិនិយោគផ្ទាល់បរទេសសរុប បានធ្លាក់ចុះ -៣%។ ការវិនិយោគក្នុងវិស័យមិនមែនហិរញ្ញវត្ថុបានថយចុះ -៤,៤% ជាពិសេសការស្នាក់នៅ[៤] (-៤៣,៧%) កសិកម្ម (-២២,៣%) និងទូរគមនាគមន៍ (-១១,១%)។ ទោះយ៉ាងណាវិស័យមួយចំនួនផ្សេងទៀតបន្តមានកំណើនវិជ្ជមាន ដូចជា វិស័យកម្មន្តសាល (២១,៣%)

**១.៦ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ**




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

---

[៣] ទិន្នន័យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

[៤] វិស័យនេះរួមមានសណ្ឋាគារ ភោជនីយដ្ឋាន និងលំនៅដ្ឋាន

និងវិស័យសំណង់និងអចលនទ្រព្យ (១,១%)។ វិស័យវារីអគ្គិសនី និងថាមពលដែលមានសមាមាត្រ ៤,៣% នៃវិនិយោគផ្ទាល់បរទេសសរុបក្នុងឆ្នាំ២០២១ បានកើនឡើងគួរឱ្យកត់សម្គាល់ ២,៦ដង ដែលបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញការវិនិយោគទៅក្នុងវិស័យនេះ ដើម្បីកាត់បន្ថយថ្លៃថាមពល ដែលជាឧបសគ្គចម្បងមួយក្នុងការបង្កើនល្បឿនអភិវឌ្ឍសេដ្ឋកិច្ចជាតិ នាពេលកន្លងមក។

**វិនិយោគផ្ទាល់បរទេសនៅកម្ពុជាមានប្រភពភាគច្រើនមកពីតំបន់អាស៊ី ហើយប្រទេសចិនឈរនៅលំដាប់ទី១។** ប្រទេសចិននៅតែជាប្រទេសដែលបាននាំមុខក្នុងការវិនិយោគនៅកម្ពុជា ដោយមានទំហំជិតពាក់កណ្ដាលនៃលំហូរទុនវិនិយោគសរុបក្នុងឆ្នាំ២០២១ (ក្រាហ្វ ១.៧)។ ការវិនិយោគពីប្រទេសចិន ភាគច្រើនទៅលើវិស័យកម្មន្តសាល ហិរញ្ញវត្ថុ សំណង់និងអចលនទ្រព្យ និងការស្នាក់នៅ។ ទន្ទឹមនេះ សមាមាត្រនៃការវិនិយោគពីប្រទេសអាស៊ីផ្សេងទៀតរួមមាន៖ សិង្ហបុរី (៨,៣%) កូរ៉េ (៨,១%) ជប៉ុន (៥,៩%) ថៃ (៤,៤%) និងម៉ាឡេស៊ី (៣,៨%)។

**១.៧ លំហូរវិនិយោគផ្ទាល់បរទេសតាមប្រទេស**
(ឆ្នាំ២០២១)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ត្រឹមចុងឆ្នាំ២០២១ បំណុលក្រៅប្រទេសដុល[៩]បានកើនឡើង ១៣,៩%។** បំណុលក្រៅប្រទេសដុលបានកើនដល់ ២០,១ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៦៩,១% នៃផ.ស.ស (ក្រាហ្វ ១.៨) ដោយសារការកើនឡើងបំណុលឯកជន។ បំណុលក្រៅប្រទេសសរុបរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើបានកើនឡើង ១៧,៧% ដល់ ១០,២ ប៊ីលានដុល្លារអាមេរិក ដែលក្នុងនោះមាន ៥,៨ ប៊ីលានដុល្លារអាមេរិក គឺជាកម្ចីរយៈពេលវែង។

**១.៨ សមាសធាតុនៃបំណុលក្រៅប្រទេសដុល**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៩] បំណុលក្រៅប្រទេសដុលរាប់បញ្ចូលបំណុលសាធារណៈក្រៅប្រទេស (រដ្ឋាភិបាល និងធនាគារកណ្ដាល) និងបំណុលរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើ

បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាល សុទ្ធតែជាកម្ចីរយៈពេលវែង និងបានកើនឡើង ៧,៧% ដល់ ៩,៥ ប៊ីលានដុល្លារអាមេរិក។

### គ. អត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ

**បញ្ហាប្រឈមនានាក្នុងដំណើរការស្តារសេដ្ឋកិច្ចឡើងវិញ និងការរួមតូចនៃអតិរេកជញ្ជីងទូទាត់បានដាក់សម្ពាធដល់តម្លៃប្រាក់រៀល ប៉ុន្តែអាចគ្រប់គ្រងបាន។** សម្ពាធទីផ្សារប្តូរប្រាក់[៦] (EMP) ស្ថិតនៅក្នុងគន្លងប្រក្រតី (ក្រាហ្វ ១.៩) ដោយសារការធ្វើអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជាក្នុងទីផ្សារប្តូរប្រាក់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក។

**១.៩ សម្ពាធទីផ្សារប្តូរប្រាក់ (EMP)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្នុងឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដេញថ្លៃប្រាក់ដុល្លារអាមេរិកជិត ៦០០ លានដុល្លារអាមេរិក ទៅឱ្យគ្រឹះស្ថានធនាគារ និងអាជីវករប្តូរប្រាក់។** ការធ្វើអន្តរាគមន៍នេះបានរួមចំណែករក្សាអត្រាប្តូរប្រាក់ឱ្យមានស្ថិរភាព ដោយអត្រាប្តូរប្រាក់ជាមធ្យម ៤.០៩៩ រៀលក្នុងមួយដុល្លារអាមេរិក ពោលគឺបានថយថ្លៃប្រមាណ ១% ធៀបនឹងឆ្នាំ២០១៩។ ជាមួយគ្នានេះ អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) បានថយថ្លៃ ២,៦% ប៉ុន្តែអត្រាអតិផរណាខ្ពស់នៅក្នុងប្រទេសកម្ពុជាបានផាត់ទាត់មួយផ្នែកនៃការធ្លាក់ថ្លៃនេះ ហើយធ្វើឱ្យអត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) ថយថ្លៃ តែ ១,១% (ក្រាហ្វ ១.១០) ដែលបានជួយបង្កើនភាពប្រកួតប្រជែងនៃការធ្វើពាណិជ្ជកម្មរបស់កម្ពុជា។

**១.១០ អត្រាប្តូរប្រាក់**




សម្គាល់៖ សន្ទស្សន៍ខ្ពស់បង្ហាញពីការធ្លាក់ថ្លៃនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដៃគូពាណិជ្ជកម្ម

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**បើទោះបីជាធនាគារជាតិនៃកម្ពុជាបានអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារប្តូរប្រាក់ ទុនបម្រុងអន្តរជាតិនៅតែមានកម្រិត**

---

[៦] វិធីសាស្ត្រនៃការគណនាសម្ពាធទីផ្សារប្តូរប្រាក់មានបង្ហាញនៅទំព័រទី១៣ នៃរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០១៨

**ខ្ពស់គ្រប់គ្រាន់ ដែលអាចរក្សាជំនឿទុកចិត្តរបស់សាធារណជនមកលើសេដ្ឋកិច្ចកម្ពុជា។** គិតត្រឹមចុងឆ្នាំ២០២១ ទុនបម្រុងអន្តរជាតិមាន ២០,៣ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៧០% នៃផ.ស.ស បានថយចុះ -៥% ធៀបនឹងឆ្នាំ២០២០ ប៉ុន្តែអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានជាង ៨,៣ខែ (ក្រាហ្វ ១.១១) ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ បើគិតតាមអនុបាតនៃភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិតាមរង្វាស់ផ្សេងទៀត ទុនបម្រុងអន្តរជាតិមានប្រមាណ ៥២% ធៀបនឹងរូបិយវត្ថុទូទៅ ដែលខ្ពស់ជាងកម្រិតគោល ២០%។ ទោះយ៉ាងណា នៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចដែលមានដុល្លាររូបនីយកម្មខ្ពស់ (ទុនបម្រុងអន្តរជាតិមានសមាមាត្រ ៦២,៧% ធៀបនឹងប្រាក់បញ្ញើជារូបិយប័ណ្ណ) និងការអនុវត្តរបបអត្រាប្តូរប្រាក់មានស្ថិរភាព ដូចករណីប្រទេសកម្ពុជា ការគរពូនទុនបម្រុងអន្តរជាតិបន្ថែមមានភាពចាំបាច់ ដើម្បីពង្រឹងម៉ាក្រូសេដ្ឋកិច្ច និងភាពធន់នៃវិស័យហិរញ្ញវត្ថុទល់នឹងការប៉ះទង្គិចនានា។

**១.១១ ទុនបម្រុងអន្តរជាតិ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់៖ ១.១**

## ការវិភាគតារាងតុល្យការ

ស្ថានភាពហិរញ្ញវត្ថុនៃគ្រប់វិស័យក្នុងឆ្នាំ២០២១ បានកើនឡើង បើទោះជាមានជំងឺកូវីដ-១៩។ ស្ថានភាពហិរញ្ញវត្ថុដុល (ទាំងផ្នែកទ្រព្យសកម្ម និងទ្រព្យអកម្ម) សរុបមាន ចំនួន ៤២៣,៨ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ៩,២% ធៀបនឹង ៣៨៨ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។ គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត (ODCs) បានដើរតួនាទីយ៉ាងសកម្មក្នុងការប្រមូលមូលធន (ពិសេសពីអង្គភាពគ្រួសារ) និងបានផ្តល់មូលធនទាំងនោះ មួយភាគធំបន្តទៅកាន់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ (NFCs)។ ចំពោះស្ថានភាពហិរញ្ញវត្ថុសុទ្ធវិញ ODCs បានបង្ហាញអំពីទ្រព្យសកម្មសុទ្ធ ចំនួន ២ ប៊ីលានដុល្លារអាមេរិក កើនឡើង ២០% (ឆ្នាំលើឆ្នាំ) ពីចំនួន ១,៦ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។ លំហូរមូលធនពីគ្រប់វិស័យចូលក្នុង ODCs មានចំនួន ៦០,៧ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១៥,៦% (ឆ្នាំលើឆ្នាំ) ជាចម្បងបណ្តាលមកពីការកើនឡើងនៃលំហូរចូលមូលធនពីអង្គភាពគ្រួសារ (១៧,៩%) វិស័យខាងក្រៅ (១៧,៤%) និង NFCs (១០,៥%)។ ដោយឡែក មូលធនដែល ODCs បានផ្តល់ទៅកាន់គ្រប់វិស័យវិញមានចំនួន ៦២,៧ ប៊ីលានដុល្លារអាមេរិក បានកើន ១៥,៧% ពីចំនួន ៥៤,២ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំមុន ដោយសារការកើនឡើងនៃការផ្តល់មូលធនទៅកាន់ NFCs និងអង្គភាពគ្រួសារ ដែលភាគច្រើនជាប្រាក់កម្ចី។

**ក** **ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យដុល ឆ្នាំ២០២១**

(គិតជាប៊ីលានដុល្លារអាមេរិក)




កំណត់សម្គាល់ ៖
- ទំហំរង្វង់ តំណាងឱ្យទំហំទឹកប្រាក់សរុបនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់វិស័យនីមួយៗ
- ពណ៌នៃខ្សែដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។

**ខ** **ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យសុទ្ធ ឆ្នាំ២០២១**

(គិតជាប៊ីលានដុល្លារអាមេរិក)




កំណត់សម្គាល់:
- វិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ ក្រហម សំដៅលើឥណទាយិក (Net debtor) ខណៈដែលវិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ បៃតង សំដៅលើឥណទាយក (Net Creditor)
- ទំហំរង្វង់ តំណាងឱ្យទំហំស្ថានភាពសុទ្ធ (Net Position) របស់វិស័យនីមួយៗ
- សញ្ញាព្រួញដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។

វិស័យខាងក្រៅ និង ODCs ជាប្រភពមូលធនសំខាន់សម្រាប់ NFCs។ NFCs បានបង្ហាញឥណទេយ្យត្រូវសងសុទ្ធចំនួន ៥៤,១ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១៣,៣% ដោយសារការកើនឡើងនៃលំហូរចូលនៃវិនិយោគពីវិស័យខាងក្រៅ (១០,១%) និងប្រាក់កម្ចីពី

ODC (១៣,១%)។ NFCs បានទទួលចូលលំហូរមូលធនសរុបចំនួន ៧០,៣ ប៊ីលានដុល្លារអាមេរិក កើនឡើង ១០,៩% (ឆ្នាំលើឆ្នាំ) ខណៈដែលលំហូរមូលធនចេញទៅកាន់គ្រប់វិស័យមានចំនួន ១៦,២ ប៊ីលានដុល្លារអាមេរិក បានកើន ៣%។

ភាពប្រទាក់ក្រឡានៃវិស័យខាងក្រៅ និងគ្រប់វិស័យក្នុងប្រទេសកម្ពុជាកើនឡើងវិញ បន្ទាប់ពីបានធ្លាក់ចុះកាលពីឆ្នាំមុន។ ឥណទេយ្យត្រូវទារសុទ្ធនៃវិស័យខាងក្រៅមានចំនួន ២៩,៣ ប៊ីលានដុល្លារអាមេរិក កើនឡើង ៣៣,២%។ លំហូរមូលធនពីវិស័យខាងក្រៅចូលមកគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា មានចំនួន ៦១,៤ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១០,៩% ខណៈលំហូរចេញទៅវិស័យក្រៅប្រទេសវិញមានចំនួន ៣២,១ ប៊ីលានដុល្លារអាមេរិក ថយចុះ ១៦,២%។ NFCs ជាអ្នកទទួលមូលធនចម្បងពីវិស័យនេះ ដែលមានសមាមាត្រស្មើនឹង ៦៧% នៃលំហូរចេញសរុបពីវិស័យខាងក្រៅ ខណៈដែលលំហូរមូលធនពី NFCs ទៅកាន់វិស័យខាងក្រៅបានរួមចំណែកត្រឹម ២៣% ប៉ុណ្ណោះ។

## ១.២ ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក

### ក. កំណើនសេដ្ឋកិច្ច

ស្របតាមការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក សេដ្ឋកិច្ចកម្ពុជាបានកើនឡើង ៣% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ១.១២)។ កំណើនវិជ្ជមាននេះ ត្រូវបានគាំទ្រដោយការនាំចេញនៃផលិតផលកាត់ដេរនិងផលិតផលកម្មន្តសាលផ្សេងៗ វិស័យសំណង់ កសិកម្ម និងការជួញដូរដុំនិងរាយ។ យ៉ាងណាមិញ ការងើបឡើងតាមវិស័យមានភាពខុសគ្នា តួយ៉ាងវិស័យទេសចរណ៍នៅបន្តធ្លាក់ចុះ។

**១.១២ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**វិស័យកម្មន្តសាលបានងើបឡើងវិញយ៉ាងឆាប់រហ័ស ដោយសារភាពប្រសើរឡើងនៃតម្រូវការខាងក្រៅ**។ ការនាំចេញផលិតផលកាត់ដេរ (សមាមាត្រ ៦៥,១% នៃការនាំចេញសរុប) បានកើនឡើង ១៥,៤% ខណៈការនាំចេញផលិតផលមិនមែនកាត់ដេរបានកើនឡើង ៥២% (មិនរាប់បញ្ចូលការនាំចេញមាស) ជាពិសេស ការនាំចេញគ្រឿងបង្គុំអេឡិចត្រូនិក កង់ និងផលិតផលកសិកម្មផ្សេងទៀត។

**ជាមួយនឹងភាពប្រសើរឡើងនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក វិស័យសំណង់បានងើបឡើងសន្សឹមៗ។** ចាប់តាំងពីការធ្លាក់ចុះ ក្នុងឆ្នាំ២០១០ ដោយសារវិបត្តិហិរញ្ញវត្ថុសកល សកម្មភាពវិស័យសំណង់បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអត្រាមធ្យម ១៧,៣%។ ប៉ុន្តែ ការរាលដាលជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់ដល់វិស័យនេះនិងធ្វើឱ្យថយចុះ -១,៨% នៅឆ្នាំ២០២០។ នៅឆ្នាំ២០២១ វិស័យនេះបានងើបឡើងបន្តិចវិញជាមួយនឹងអត្រាកំណើន ១,១% (ក្រាហ្វ ១.១៣)។

**វិស័យកសិកម្មបានបន្តគាំទ្រការងើប-ឡើងនៃសេដ្ឋកិច្ច ជាមួយអត្រាកំណើន ១,១%** (ក្រាហ្វ ១.១៣)។ វិស័យនេះ ត្រូវបានគាំទ្រដោយការកើនឡើងនៃការវិនិយោគ វិធានការគាំទ្ររបស់រាជរដ្ឋាភិបាល លក្ខខណ្ឌអាកាសធាតុអំណោយផល និងការកើនឡើងនៃកម្លាំងពលកម្ម។ ផ្ទៃដីដាំដុះនិងទិន្នផលស្រូវរដូវវស្សាបានកើនឡើង ៩% និង ១០,២% រៀងគ្នា។ យ៉ាងណាមិញ ផលវារីវប្បកម្មជាពិសេសការចិញ្ចឹមត្រីនិងបង្គា មានកំណើនអវិជ្ជមានប្រមាណ -១៣% ដោយសារតែការធ្លាក់ចុះនៃតម្រូវការក្នុងស្រុក និងការប្រកួតប្រជែងនៃការនាំចូល។

**ការរីករាលដាលជំងឺកូវីដ-១៩ នៅកម្ពុជា និងក្នុងតំបន់បានផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរលើវិស័យទេសចរណ៍។** ចំនួនភ្ញៀវអន្តរជាតិបន្តធ្លាក់ចុះ -៨៥% (ដល់ ១៩៦.៤៩៥ នាក់) បន្ទាប់ពីបានធ្លាក់ចុះ -៨០,២% នៅឆ្នាំ២០២០ (ក្រាហ្វ ១.១៤) ដែលការណ៍នេះបានបង្កផលប៉ះពាល់ដល់វិស័យទេសចរណ៍និងអាជីវកម្មពាក់ព័ន្ធ។ យ៉ាងណាមិញ ភាពជោគជ័យនៃយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស ដែលមានប្រជាជនសរុបប្រមាណ ៩០% បានទទួលការចាក់វ៉ាក់សាំងគិតត្រឹមចុងឆ្នាំ២០២១ បានធ្វើឱ្យអាជ្ញាធរអាចបន្ធូរបន្ថយបន្តិចម្តងៗនូវការរឹតត្បិតការធ្វើដំណើរ

**១.១៣ កំណើនវិស័យសំណង់និងកសិកម្ម**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និង ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**១.១៤ ចំនួនភ្ញៀវអន្តរជាតិ បែងចែកតាមគោលបំណង**




ប្រភព៖ ក្រសួងទេសចរណ៍និងនាយកដ្ឋានអន្តោប្រវេសន៍ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២១ ដែលបានធ្វើឱ្យវិស័យទេសចរណ៍មានសកម្មភាពឡើងវិញ គាំទ្រជាចម្បងដោយសារការងើបឡើងនៃភ្ញៀវទេសចរក្នុងស្រុក។

**នៅឆ្នាំ២០២១ កម្ពុជាបានទទួលភ្ញៀវទេសចរថៃច្រើនជាងគេ ខណៈភ្ញៀវទេសចរចិនបានធ្លាក់មកនៅលំដាប់ទី២។** នៅចន្លោះឆ្នាំ២០១៦ និង២០២០ ភ្ញៀវទេសចរចិនមានចំនួនច្រើនជាងគេ ជាមួយសមាមាត្រជាមធ្យម ២៧,៣% បន្ទាប់មកគឺភ្ញៀវទេសចរវៀតណាម (១៤,៩%) ថៃ (៧,៥%) និង ឡាវ (៦,៩%)។ ការរឹតបន្តឹងការធ្វើដំណើររបស់ប្រទេសចិន និងការធ្លាក់ចុះជារួមនៃការធ្វើដំណើរផ្លូវឆ្ងាយក្នុងអំឡុងវិបត្តិកូវីដ-១៩ បានធ្វើឱ្យប្រទេសថៃក្លាយជាប្រភពភ្ញៀវទេសចរមកលេងកម្ពុជាច្រើនជាងគេ (សមាមាត្រ ៤១,៧%) ខ្ពស់ជាងប្រទេសចិននិងបណ្តាប្រទេសដទៃទៀត (ក្រាហ្វ ១.១៥)។

**១.១៥ សមាមាត្រនៃភ្ញៀវទេសចរតាមប្រទេស**




ប្រភព៖ ក្រសួងទេសចរណ៍និងនាយកដ្ឋានអន្តោប្រវេសន៍ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ខ. វិស័យសំណង់ និងអចលនទ្រព្យ

**ការអភិវឌ្ឍវិស័យសំណង់និងអចលនទ្រព្យក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយមានការរីកចម្រើន ទន្ទឹមនឹងកំណើនឥណទានខ្ពស់ទៅកាន់វិស័យនេះដែលទាមទារឱ្យមានការតាមដានដោយហ្មត់ចត់ទៅលើហានិភ័យស្ថិរភាពហិរញ្ញវត្ថុដែលអាចកើតចេញពីវិស័យនេះ។** ទោះបីជាកំណើនសេដ្ឋកិច្ចកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់មុនវិបត្តិកូវីដ-១៩ ក៏សេដ្ឋកិច្ចបន្តពឹងផ្អែកលើវិស័យមួយចំនួនតូច ដែលក្នុងនោះវិស័យសំណង់និងអចលនទ្រព្យបានរួមចំណែកប្រមាណមួយភាគបី នៃផ.ស.ស។ ដោយសារឥណទានទៅកាន់វិស័យនេះមានកំណើនខ្ពស់នាពេលកន្លងមក (មើលជំពូក ២) ការតាមដានវិស័យសំណង់ និងអចលនទ្រព្យមានភាពចាំបាច់។

**សន្ទស្សន៍ថ្លៃលំនៅដ្ឋាន (RPPI)[៧] ត្រូវបានចងក្រងដើម្បីតាមដានស្ថានភាពទីផ្សារលំនៅ-ដ្ឋាន។ លទ្ធផលបានបង្ហាញថាទីផ្សារនេះមានស្ថិរភាពទាំងនៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្ត (ក្រាហ្វ ១.១៦)។** ក្នុងឆ្នាំ២០២១នេះ សន្ទស្សន៍ថ្លៃលំនៅដ្ឋានជារួម បានកើនឡើង ១០,៩% ធៀបនឹងឆ្នាំ២០២០ ដែលឆ្លុះបញ្ចាំងអំពីការបន្តមានភាពទាក់ទាញនៃទីផ្សារលំនៅដ្ឋាន ទោះបីជាប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ។ កត្តាចម្បងនៃកំណើនថ្លៃនេះ បណ្តាលមកពីការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីតំបន់មួយទៅតំបន់មួយនៅកម្ពុជា និងតម្រូវការខ្ពស់នៃលំនៅដ្ឋានដែលមានតម្លៃសមរម្យនិងមធ្យម នៅក្នុងតំបន់ជុំវិញរាជធានីភ្នំពេញដោយសារការកើនឡើងនៃលំហូរប្រជាពលរដ្ឋពីខេត្តមករាជធានី ដើម្បីធ្វើការ ឬសិក្សា។

**១.១៦ សន្ទស្សន៍ថ្លៃលំនៅដ្ឋាន**




សម្គាល់៖ ឆ្នាំ២០២០ ជាឆ្នាំគោល ស្មើនឹង ១០០
ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ការកើនឡើងនៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ និងលំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យសំណង់និងអចលនទ្រព្យ បានបង្ហាញពីសញ្ញានៃការងើបឡើងនៃវិស័យនេះនៅឆ្នាំ២០២១។** ការនាំចូលសម្ភារនិងបរិក្ខារសំណង់បានកើនឡើង ២៧,១% បន្ទាប់ពីបានធ្លាក់ចុះ -១២,២% នៅឆ្នាំ២០២០ (ក្រាហ្វ ១.១៧) ដែលបានឆ្លុះបញ្ចាំងពីការចាប់ផ្តើមឡើងវិញនៃគម្រោងសាងសង់ដែលបានផ្អាក ឬពន្យារនាឆ្នាំកន្លងទៅ។ ទន្ទឹមនេះ លំហូរវិនិយោគផ្ទាល់បរទេស ទៅកាន់វិស័យសំណង់និងអចលនទ្រព្យ

**១.១៧ កំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់**




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង
ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

---

[៧] វិធីសាស្រ្តដែលត្រូវបានប្រើប្រាស់ដើម្បីគណនាសន្ទស្សន៍ថ្លៃលំនៅដ្ឋានគឺវិធីសាស្រ្ត time-dummy hedonic ជាមួយទិន្នន័យរំកិល (rolling window) ចំនួន១៨ខែ តាមការណែនាំស្តីពីការចងក្រងសន្ទស្សន៍ថ្លៃលំនៅដ្ឋានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ IMF ដែលបោះផ្សាយនៅឆ្នាំ២០២០ (https://www.imf.org/en/Data/Statistics/RPPI-guide)។ អថេរដែលប្រើប្រាស់ក្នុងម៉ូដែលរួមមាន កាលបរិច្ឆេទ ប្រភេទនៃអចលនទ្រព្យ ប័ណ្ណកម្មសិទ្ធ ទីតាំង (ខេត្ត ឬស្រុក) ផ្ទៃក្រឡាសាងសង់ ផ្ទៃក្រឡាដី តម្លៃទិញ ចំនួនជាន់ ចំនួនបន្ទប់ដេក និងប្រវែងទទឹងនៃលំនៅដ្ឋាន។ អថេរទាំងអស់ត្រូវបានយកចេញពីប្រតិបត្តិការឥណទានដើម្បីទិញលំនៅដ្ឋានពីធនាគារពាណិជ្ជចំនួន ៦៧ ជាមួយនឹងចំនួនប្រតិបត្តិការប្រចាំខែប្រហែល ១០០០។

បានកើនឡើង ១,១% បន្ទាប់ពីបានធ្លាក់ចុះ -១០,៦% នៅឆ្នាំ២០២០។

**ទោះយ៉ាងណា វិស័យនេះនៅបន្តមានហានិភ័យ ដោយសារវិនិយោគិនអាចនៅរង់ចាំការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចមុននឹងសម្រេចចិត្តវិនិយោគបន្ថែម។** ទោះបីជាវិស័យនេះចាប់ផ្តើមងើបឡើង ចំនួននិងតម្លៃគម្រោងសាងសង់ដែលត្រូវបានអនុម័ត នៅធ្លាក់ចុះ -១១,២% និង -៣១,២% រៀងគ្នា (ក្រាហ្វ ១.១៨) ដែលបង្ហាញថាវិនិយោគិនអាចកំពុងតែរង់ចាំមើលការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចនៅឡើយ។ ទន្ទឹមនេះ ទីផ្សារខុនដូមានសភាពនៅទ្រឹង ជាពិសេសខុនដូប្រភេទប្រណិតនិងមធ្យម ដែលពឹងផ្អែកលើអ្នកទិញពីបរទេស។ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងជិតដល់ជាមួយអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ដើម្បីតាមដានការប្រែប្រួលនៅក្នុងវិស័យនេះ និងផលបច្ច័យទៅលើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**១.១៨ កំណើនចំនួននិងតម្លៃគម្រោងសំណង់**




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## គ. ស្ថានភាពអតិផរណា និងរូបិយវត្ថុ

**អតិផរណាបន្តមានកម្រិតទាបជាមធ្យម ២,៩% ដោយសារការថមថយកំណើនថ្លៃម្ហូបអាហារ និងអតិផរណាស្នូល (ក្រាហ្វ ១.១៩)។** ថ្លៃក្រុមម្ហូបអាហារនិងអតិផរណាស្នូលមានកំណើនយឺតជាងមុនត្រឹម ២,៧% និង ១,៦% រៀងគ្នា (ធៀបនឹង ៤,៦% និង ២,១% នៅឆ្នាំ ២០២០) ដោយសារការធ្លាក់ចុះនៃតម្រូវការបណ្តាលមកពីវិធានការរឹតត្បិតនានា បន្ទាប់ពី "ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ" ដែលជាការឆ្លងរាលដាលជំងឺកូវីដ-១៩ លើកដំបូងនៅកម្ពុជា។ ទោះយ៉ាងណា ថ្លៃទំនិញទាក់ទងនឹងប្រេងឥន្ធនៈ បានកើនឡើងខ្លាំងដល់ ៨,៦% បន្ទាប់ពីធ្លាក់ចុះ -៣,២% កាលពីឆ្នាំ២០២០ ដោយសារការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក។

**១.១៩ ការរួមចំណែកក្នុងអតិផរណារួម**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**កម្រិតទាបនិងស្ថិរភាពអតិផរណាត្រូវបានរួមចំណែកដោយស្ថិរភាពអត្រាប្តូរប្រាក់ និងការគ្រប់គ្រងលើការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2)។** នៅក្នុងឆ្នាំ២០២១ រូបិយវត្ថុទូទៅ (M2) បានកើនឡើង ១៦,៣% ស្របតាមការងើបឡើងនៃសេដ្ឋកិច្ច ដោយមិនបានដាក់សម្ពាធលើអតិផរណានោះឡើយ (ក្រាហ្វ ១.២០)។ កំណើនរូបិយវត្ថុទូទៅត្រូវបានគាំទ្រដោយការកើនឡើងនៃប្រាក់បញ្ញើ ១៧,១% ទោះបីជាមានការរាលដាលជំងឺកូវីដ-១៩ (ការណ៍នេះឆ្លុះបញ្ចាំងពីជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារ) និងកំណើនរូបិយវត្ថុក្នុងចរាចរណ៍ ៨,៣%។

**លក្ខខណ្ឌហិរញ្ញវត្ថុនៅតែអំណោយផលដើម្បីគាំទ្រការស្តារសេដ្ឋកិច្ចឡើងវិញ។** ធនាគារជាតិនៃកម្ពុជាបានរក្សាលក្ខខណ្ឌហិរញ្ញវត្ថុអំណោយផល ដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់ប្រព័ន្ធធនាគារជាមួយថ្លៃដើមទាប រួមមានការរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ច (RRR) ៧% សម្រាប់គ្រប់រូបិយប័ណ្ណទាំងអស់ និងកាត់បន្ថយអត្រាការប្រាក់ដេញថ្លៃអប្បបរមានៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ចំនួន ០,៥% សម្រាប់គ្រប់តណប្រតិទានទាំងអស់។ ក្រៅពីនេះ ក្នុងចំណោមវិធានការគាំទ្រផ្សេងទៀត ធនាគារជាតិនៃកម្ពុជាបានរក្សាទ្រនាប់ដើមទុនខនស៊ើវេសិន ១,២៥% និងបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តរៀបចំឥណទានឡើងវិញសម្រាប់ប្រជាពលរដ្ឋ និងក្រុមហ៊ុន-សហគ្រាស ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ មកលើសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារ។

**ប្រសិនបើដុល្លារូបនីយកម្មមិនមានកម្រិតខ្ពស់ ធនាគារជាតិនៃកម្ពុជានឹងមានជម្រើសគោលនយោបាយបន្ថែមទៀតសម្រាប់**

**១.២០ រូបិយវត្ថុទូទៅ (M2)**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ស្តារសេដ្ឋកិច្ចឡើងវិញ។** សេដ្ឋកិច្ចពឹងផ្អែកលើប្រាក់រៀលនឹងផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តនយោបាយរូបិយវត្ថុកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីកាត់បន្ថយផលប៉ះពាល់កើតចេញពីការប៉ះទង្គិចនានាមកលើសេដ្ឋកិច្ចជាតិ។ ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងខិតខំកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបន្តិចម្តងៗ តាមរយៈការសម្រួលដល់ការប្រើប្រាស់ប្រាក់រៀល ដូចជាការដាក់ចេញបទប្បញ្ញត្តិជំរុញកម្ចីជាប្រាក់រៀល និងលើកកម្ពស់ការយល់ដឹងសាធារណជនមកលើតួនាទីរូបិយវត្ថុក្នុងការពង្រឹងភាពធន់នៃសេដ្ឋកិច្ច។ ការខិតខំប្រឹងប្រែងនេះបានរួមចំណែកកាត់បន្ថយជាបណ្តើរៗនូវដុល្លារូបនីយកម្មហិរញ្ញវត្ថុ វាស់វែងដោយអនុបាតនៃប្រាក់បញ្ញើរូបិយប័ណ្ណបរទេសនៅក្នុងរូបិយវត្ថុទូទៅ M2 និងក្នុងប្រាក់បញ្ញើសរុប។ ទោះយ៉ាងណា កម្រិតដុល្លារូបនីយកម្មនៅតែខ្ពស់ជាង ៨០% (ក្រាហ្វ ១.២១) ដែលដាក់កម្រិតលើតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការកំណត់បរិមាណផ្គត់ផ្គង់រូបិយវត្ថុនិងអត្រាការប្រាក់។ អាស្រ័យហេតុនេះ ការសម្របសម្រួលផ្នែកគោលនយោបាយនិងការចូលរួមយ៉ាងសកម្មពីសាធារណជននិងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ពិតជាមានសារៈសំខាន់ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត។

**១.២១ ដុល្លារូបនីយកម្មហិរញ្ញវត្ថុ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឃ វិស័យសារពើពន្ធ

**ការថមថយការប្រមូលចំណូល និងការបន្តគាំទ្រសារពើពន្ធរបស់រាជរដ្ឋាភិបាល បានធ្វើឱ្យឱនភាពកើនឡើង និងដាក់សម្ពាធបន្ថែមលើហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល** (ក្រាហ្វ ១.២២)។ សមតុល្យសារពើពន្ធរបស់រាជរដ្ឋាភិបាលបានបង្ហាញពីការកើនឡើងនៃការខ្ចីសុទ្ធប្រមាណ -៥,៣% នៃផ.ស.ស ធៀបនឹង -៣,៨% នៃផ.ស.ស ក្នុងឆ្នាំ ២០២០។ ឱនភាពនេះបានធ្វើឱ្យទុនបម្រុង

**១.២២ គណនីសារពើពន្ធ**




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

របស់រាជរដ្ឋាភិបាលថយចុះ និងបង្កើនបំណុលរបស់រាជរដ្ឋាភិបាល។

**ការងើបឡើងយឺតនៃសេដ្ឋកិច្ច និងវិធានការបន្ធូរបន្ថយពន្ធមួយចំនួនរបស់រាជរដ្ឋាភិបាលបានបណ្តាលឱ្យចំណូលធ្លាក់ចុះ។** ចំណូលរបស់រាជរដ្ឋាភិបាល មានចំនួន ២០,៨ ទ្រីលានរៀល ដែលបានបន្តធ្លាក់ចុះ -១០,២% (ក្រាហ្វ ១.២៣) ប៉ុន្តែមានភាពប្រសើរជាងឆ្នាំ២០២០ (-១៥,១%) ជាចម្បងបណ្តាលមកពីការថយចុះនៃការប្រមូលពន្ធ ៩,២% ដែលក្នុងនោះពន្ធលើទំនិញនិងសេវាប្រើប្រាស់ -៩,៦% និងពន្ធលើពាណិជ្ជកម្មអន្តរជាតិក្រៅប្រទេស -៣% ខណៈដែលពន្ធលើប្រាក់ចំណូលបានកើនឡើង ២,៦%។ ទន្ទឹមនេះ ជំនួយដែលមានសមាមាត្រ ៥% នៃចំណូលសរុប បានធ្លាក់ចុះ ៤៩%។

**រាជរដ្ឋាភិបាលកម្ពុជាបន្តផ្តល់កញ្ចប់វិភាជន៍ថវិកាជំរុញសេដ្ឋកិច្ច (stimulus Package) ដើម្បីគាំពារប្រជាពលរដ្ឋងាយរងគ្រោះខ្លាំង និងគាំទ្រការស្តារសេដ្ឋកិច្ចឡើងវិញ។** ទោះបីជារាជរដ្ឋាភិបាលបង្កើនវិភាជន៍ថវិកាជំរុញសេដ្ឋកិច្ចក៏ចំណាយសរុបដែលមានចំនួន ២៦,៤ ទ្រីលានរៀល បានថយចុះ -២,៦% (ក្រាហ្វ ១.២៤) ដោយសារការរឹតត្បិតការចំណាយចរន្ត ជាពិសេសប្រាក់បៀវត្សរ៍ (-១០,៩%) និងការប្រើប្រាស់ទំនិញ និងសេវាកម្ម (-២៦,៣%)។ ទន្ទឹមនេះ ចំណាយដើមទុននិងអត្ថប្រយោជន៍សង្គមបានធ្លាក់ចុះ -៦,៧% ព្រមគ្នា។ គួររំលេចផងដែរថា ក្នុងឆ្នាំ២០២០-២០២១ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការអន្តរាគមន៍ចំនួន ១០ជុំ និងបានចំណាយថវិកាប្រមាណ ២,៣ ប៊ីលានដុល្លារអាមេរិក ដើម្បីជួយក្រុមគ្រួសារក្រីក្រនិងងាយរងគ្រោះ ប្រមាណ ២ លានគ្រួសារ ព្រមទាំងបានគាំទ្រដល់អាជីវកម្មដែលរងផលប៉ះពាល់ខ្លាំងដោយវិបត្តិកូវីដ-១៩។

**១.២៣ ការរួមចំណែកក្នុងកំណើនប្រាក់ចំណូល**




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**១.២៤ ការរួមចំណែកក្នុងកំណើនប្រាក់ចំណូល**




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ហានិភ័យបំណុលរបស់រាជរដ្ឋាភិបាលមានកម្រិតទាប ទោះបីជាសម្ពាធលើហិរញ្ញប្បទានបានកើនឡើង។** គិតត្រឹមចុងឆ្នាំ២០២១ បំណុលរបស់រាជរដ្ឋាភិបាលបានកើនឡើង ៧,៧% ដល់ ៩,៤៩ ប៊ីលានដុល្លារអាមេរិក (៣៥,៤% នៃ ផ.ស.ស) (ក្រាហ្វ ១.២៥)។ ប្រទេសចិន ជាប្រទេសផ្តល់ប្រាក់កម្ចីធំជាងគេ ជាមួយសមាមាត្រ ៤២,៧% នៃបំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលសរុប បន្ទាប់មកគឺពហុភាគី (៣០,៤%) ប្រទេសជប៉ុន (៩,២%) និងប្រទេសកូរ៉េ (៥,៣%) (ក្រាហ្វ ១.២៦)។ យោងតាមការវិភាគចីរភាពបំណុលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំណុលរាជរដ្ឋាភិបាលនៅមានកម្រិតហានិភ័យទាប។ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផ.ស.ស មានសមាមាត្រស្មើនឹង ២៤,៤% ទាបជាងកម្រិតអនុបាតគោល ៤០%។

**១.២៥ បំណុលសាធារណៈ**




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**១.២៦ សមាមាត្របំណុលសាធារណៈក្រៅប្រទេសបែងចែកតាមប្រទេសចម្បងៗ**

(គិតត្រឹមឆ្នាំ២០២១)




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រអប់៖ ១.២

## គោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលដើម្បីជួយលើកស្ទួយអាជីវកម្មក្នុងស្រុក និងសុខុមាលភាពសង្គមក្នុងបរិការណ៍នៃការរាលដាលជំងឺកូវីដ-១៩

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើសកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងឆ្នាំ ២០២០-២០២១ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិកា ២,៣ ប៊ីលានដុល្លារអាមេរិក និងបានដាក់ចេញវិធានការអន្តរាគមន៍ចំនួន ១០ជុំ។ ការអន្តរាគមន៍នេះបានរួមចំណែករក្សាអាជីវកម្មឱ្យនៅដំណើរការ ជំរុញកំណើនសេដ្ឋកិច្ច និងផ្តល់តម្រូវការមូលដ្ឋានសម្រាប់ក្រុមគ្រួសារដែលងាយរងគ្រោះចំនួន ៧០០.០០០ គ្រួសារ។ វិធានការទាំងនោះ រួមមាន៖

- ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតកាត់ដេរ ចំនួន ៧០ដុល្លារអាមេរិក ក្នុងមួយខែ (រាជរដ្ឋាភិបាល ៤០ដុល្លារអាមេរិក និងនិយោជក ៣០ដុល្លារអាមេរិក) រហូតដល់ចុងឆ្នាំ ២០២១។
- លើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទសម្រាប់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍ នៅក្នុងខេត្តកំពត ក្រុងព្រះសីហនុ ខេត្តកែប ខេត្តសៀមរាប រាជធានីភ្នំពេញ ក្រុងបាវិត និងក្រុងប៉ោយប៉ែត រហូតដល់ចុងឆ្នាំ២០២១។
- លើកលែងការបង់ពន្ធអប្បបរមាប្រចាំខែ សម្រាប់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជា ចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២១។
- ដាក់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារមូលដ្ឋាន រយៈពេលពីរឆ្នាំ (ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)។
- លើកលែងការបង់វិភាគទានសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពនៃបេឡាជាតិសន្តិសុខសង្គម ក្នុងអំឡុងពេលព្យួរ ឬផ្អាកដំណើរការអាជីវកម្ម។
- លើកលែងការបង់ពន្ធអប្បបរមា សម្រាប់ក្រុមហ៊ុនអាកាសចរណ៍ដែលបានចុះបញ្ជីនៅកម្ពុជា រហូតដល់ចុងឆ្នាំ២០២១។
- ពន្យារពេលការបង់ប្រាក់ជំពាក់កម្រៃអាកាសចរស៊ីវិល រហូតដល់ចុងឆ្នាំ២០២១។
- ផ្តល់ប្រាក់ឧបត្ថម្ភ ៤០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករ-និយោជិតដែលបំពេញការងារក្នុងវិស័យទេសចរណ៍ ដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍រហូតដល់ចុងឆ្នាំ២០២១។
- ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ក្រុមគ្រួសារដែលងាយរងគ្រោះ នៅក្នុងតំបន់បិទខ្ទប់។
- ផ្តល់ការលើកលែងពន្ធរយៈពេលប្រាំមួយខែ ទៅមួយឆ្នាំ សម្រាប់រោងចក្រដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការរាលដាលនៃជំងឺកូវីដ-១៩ និងការព្យួរអ្វីៗទាំងអស់លើកលែងតែអាវុធ (EBA)″ ។
- លើកលែងការបង់កម្រៃថ្លៃអាជ្ញាប័ណ្ណទាំងអស់នៅក្នុងវិស័យទេសចរណ៍ សម្រាប់ឆ្នាំ២០២១។

- ផ្តល់ការលើកលែងពន្ធនិងកាត់បន្ថយការធ្វើសវនកម្មលើសណ្ឋាគារ និងផ្ទះសំណាក់សម្រាប់ឆ្នាំ២០២០។
- លើកលែងពន្ធប្រថាប់ត្រាសម្រាប់ផ្ទះដែលមានតម្លៃទាបជាង ៧០.០០០ ដុល្លារអាមេរិក។
- ផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប ដើម្បីជួយសហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យកសិកម្ម និងផលិតកម្ម។
- ផ្តល់គម្រោងហិរញ្ញប្បទានពិសេស ដល់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃកសិផល។
- បង្កើតគម្រោងធានាឥណទាន ដើម្បីបន្ធូរបន្ថយសម្ពាធទុនបង្វិល។
- ទម្លាក់ពន្ធកាត់ទុកលើកម្ចីរបស់ម្ចាស់កម្ចីទាំងប្រភពខាងក្រៅនិងខាងក្នុងស្រុក។
- បង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ជំនាញឡើងវិញ សម្រាប់កម្មករ-និយោជិតដែលត្រូវបានបញ្ឈប់ពីការងារ សម្រាប់វិស័យទេសចរណ៍ និងកាត់ដេរ។

# II ប្រព័ន្ធធនាគារៈ ប្រតិបត្តិការ និងស្ថិរភាព

ប្រព័ន្ធធនាគារបានបន្តរក្សាភាពរឹងមាំ និងមានភាពធន់ ស្របពេលដែលបាននិងបន្តផ្តល់ហិរញ្ញប្បទានចាំបាច់ក្នុងការគាំទ្រការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩។ ទ្រព្យសកម្ម និងប្រាក់បញ្ញើរបស់ប្រព័ន្ធធនាគារមានកំណើន ១៨% និង ១៧,៧% រៀងគ្នា ជាមួយនឹងឥណទានមានកំណើនខ្ពស់ ២៣,៥%។ នៅក្នុងប្រព័ន្ធធនាគារ ធនាគារពាណិជ្ជបានរួមចំណែកជាង ៨៥% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារ បន្ទាប់មកគឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI)។ ឥណទានរបស់វិស័យធនាគារមានកំណើនរឹងមាំ ២៦,៤% ដល់ ១៥៥,៣ ទ្រីលានរៀល ដែលបានផ្តល់ទៅកាន់វិស័យជួញដូររាយ ឥណទានទិញផ្ទះ ការជួញដូរដុំ សំណង់ និងអចលនទ្រព្យ។ គុណភាពទ្រព្យសកម្មបន្តមានសុខភាពល្អ ដែលប្រសើរឡើងបន្តិចក្នុងឆ្នាំ២០២១ ដោយអនុបាតឥណទានមិនដំណើរការ បានធ្លាក់ចុះមកនៅ ១,៨%។ កម្រិតសន្ទនីយភាពនិងដើមទុនរបស់ធនាគារបន្តមានសុខភាពល្អ ដោយមានកម្រិត ១៥១,៦% និង ២៣% រៀងគ្នា ខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ។ ទន្ទឹមនេះ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ធនាគារបន្តមានចីរភាព។ សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ទ្រព្យសកម្មសរុបមានកំណើន ៧,៣% ហើយឥណទានបានកើនឡើង ២៦% ដែលបានផ្តល់ជាចម្បងទៅកាន់អង្គភាពគ្រួសារ ការជួញដូរ កសិកម្ម និងសេវាកម្ម។ ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ គុណភាពឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុបន្តមានភាពរឹងមាំ ដោយអនុបាតឥណទានមិនដំណើរការមានកម្រិតទាបគួបផ្សំនឹងកម្រិតខ្ពស់នៃសន្ទនីយភាព ដែលត្រូវបានឆ្លុះបញ្ចាំងដោយអនុបាតក្របខ័ណ្ឌសន្ទនីយភាពបន្តមានកម្រិតខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ។ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់វិស័យមីក្រូហិរញ្ញវត្ថុបន្តមានចីរភាព ដែលបានរួមចំណែកដល់រក្សាកម្រិតខ្ពស់នៃអនុបាតសាធនភាព ១៨,២% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៤០,៧% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ សម្រាប់ធនាគារឯកទេស កំណើនឥណទានបានធ្លាក់ចុះ -២៤,៨% ដែលបណ្តាលមកពីការប្រែប្រួលនៃចំនួនគ្រឹះស្ថាន។ ទន្ទឹមនេះ ធនាគារឯកទេសបានផ្តល់ឥណទានទៅកាន់វិស័យផ្សេងៗ រួមមាន តម្រូវការផ្ទាល់ខ្លួន ការជួញដូររាយ ឥណទានទិញផ្ទះ អចលនទ្រព្យ និងវិស័យផ្សេងៗទៀត។ អនុបាតឥណទានមិនដំណើរការសម្រាប់ធនាគារឯកទេសមានកម្រិត ៩,១% ក្នុងឆ្នាំ២០២១ ខណៈដែលអនុបាតសាធនភាពមានកម្រិត ៣៧%។

## ២.១ និន្នាការទូទៅប្រព័ន្ធធនាគារ

ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជានៅបន្តប្រមូលផ្តុំភាគច្រើនដោយគ្រឹះស្ថានធនាគារ និងមានទំហំធំបើធៀបនឹងផ.ស.ស។ ធនាគារពាណិជ្ជរួមចំណែកប្រមាណ ៨៥,៣% នៃប្រព័ន្ធធនាគារនៅកម្ពុជា[៨] ដោយមានធនាគារពាណិជ្ជចំនួន ៥៤ គ្រឹះស្ថាន និងទ្រព្យសកម្មសរុបចំនួន ២៤១,៨ ទ្រីលានរៀល គិតត្រឹមខែធ្នូ ឆ្នាំ២០២១។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ជាអ្នករួមចំណែកធំបន្ទាប់ ដែលបានរួមចំណែក ១១,៣% នៃទ្រព្យសកម្មប្រព័ន្ធធនាគារសរុប។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ៧៩ និងធនាគារឯកទេសចំនួន ១០ បានរួមចំណែក ១,៨% និង ០,៩% រៀងគ្នា នៃទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារសរុប។ ចំណែក ១% ទៀតគឺរួមចំណែកដោយក្រុមហ៊ុនភតិសន្យាចំនួន ១៨ និងគ្រឹះស្ថានឥណទានជនបទចំនួន ២៣២។

**តារាង ២.១៖ រចនាសម្ព័ន្ធប្រព័ន្ធធនាគារកម្ពុជា**
**(ខែធ្នូ ឆ្នាំ២០២១)**

| គ្រឹះស្ថាន | ចំនួន | ទ្រព្យសកម្ម (ទ្រីលានរៀល) | សមាមាត្រ (% នៃទ្រព្យសកម្មសរុប) |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៥៤ | ២៤១,៨ | ៨៥,៣% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៥ | ៣១,៩ | ១១,៣% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | ៧៩ | ៥,១ | ១,៨% |
| ធនាគារឯកទេស | ១០ | ២,៦ | ០,៩% |
| ក្រុមហ៊ុនភតិសន្យា | ១៧ | ១,៨ | ០,៧% |
| គ្រឹះស្ថានឥណទានជនបទ | ២៣២ | ០,២៤ | ០,០៩% |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹមចុងឆ្នាំ២០២១ ទ្រព្យសកម្មសរុបរបស់វិស័យធនាគារមានប្រមាណ ២៨១,៥ ទ្រីលានរៀល កើនឡើង ១៨% ធៀបនឹងឆ្នាំ២០២០។ វិស័យធនាគារមានទំហំធំឆ្លុះបញ្ចាំងតាមរយៈ ទ្រព្យសកម្មធៀបនឹងផ.ស.ស ដែលមានកម្រិត ២៥១% ក្នុងឆ្នាំ២០២១។ ឥណទាននិងប្រាក់បញ្ញើសរុបក្នុងវិស័យធនាគារមានកម្រិត ១៦៩% និង ១៤៣% រៀងគ្នា នៃផ.ស.ស (ក្រាហ្វ ២.១)។ អន្តរការីយកម្មហិរញ្ញវត្ថុ ដែលវាស់ស្ទង់ចនាករចម្បងៗធៀបនឹងផ.ស.ស បានបង្ហាញពីកំណើនខ្ពស់ក្នុងអំឡុងឆ្នាំ២០២០-២០២១ ដោយសារការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច (-៣,១% ក្នុងឆ្នាំ

**២.១ ប្រព័ន្ធធនាគារនៅកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៨] ប្រព័ន្ធធនាគារត្រូវបានកំណត់យ៉ាងទូលំទូលាយ រួមបញ្ចូលធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ធនាគារឯកទេស ក្រុមហ៊ុនភតិសន្យា និងគ្រឹះស្ថានឥណទានជនបទ ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ដូចដែលនឹងបង្ហាញនៅក្នុងជំពូកទី៣ខាងមុខ ចំណែកនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ជាចម្បងក្រុមហ៊ុនធានារ៉ាប់រង) មានការរួមចំណែកតិចតួច ហើយទ្រព្យកម្មសិទ្ធិនិងមូលបត្រ ស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ។

២០២០)។ លើសពីនេះ ដោយកំណើនឥណទានមានល្បឿនលឿនជាងកំណើនប្រាក់បញ្ញើ គម្លាតរវាងឥណទាននិងប្រាក់បញ្ញើបានកើនឡើង ដែលបានធ្វើឱ្យគ្រឹះស្ថានមួយចំនួនបានស្វែងរកមូលនិធិផ្សេងៗបន្ថែមទៀត។

ជារួម ការរួមចំណែករបស់គ្រឹះស្ថានធនាគារក្នុងអន្តរការីយកម្មហិរញ្ញវត្ថុ បានគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ កាលពីពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា បានប៉ាន់ស្មានថាប្រមាណ ៧០% នៃប្រជាជនកម្ពុជាអាចប្រើប្រាស់សេវាហិរញ្ញវត្ថុ រួមមាន ឥណទាន ប្រាក់បញ្ញើ ការផ្ទេរប្រាក់ និងការទូទាត់តាមឌីជីថល។

**កំណើននៃទ្រព្យសកម្ម និងប្រាក់បញ្ញើក្នុងវិស័យធនាគារបានងើបឡើងវិញក្នុងឆ្នាំ២០២១ បន្ទាប់ពីបានថមថយក្នុងឆ្នាំ២០២០ ខណៈឥណទានមានកំណើនរឹងមាំ។** ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទាននៃវិស័យធនាគារក្នុងឆ្នាំ២០២១មានកំណើន ១៨% ១៧,៧% និង ២៣,៥% រៀងគ្នាឆ្នាំលើឆ្នាំ ដែលបង្ហាញពីការងើបឡើងវិញបន្ទាប់ពីបានថយចុះក្នុងឆ្នាំ២០២០ ដោយសារវិបត្តិជំងឺកូវីដ-១៩ (ក្រាហ្វ ២.២)។ ឥណទានមានកំណើនរឹងមាំ ប្រហាក់ប្រហែលនឹងកំណើនកាលពីឆ្នាំ២០១៩ ប៉ុន្តែមានកម្រិតខ្ពស់ជាងកាលពីឆ្នាំ២០១៦-២០១៧ ខណៈទ្រព្យសកម្មនិងប្រាក់បញ្ញើងើបឡើងវិញក្នុងកំណើនមធ្យម។

កំណើនខ្ពស់នៃឥណទាន[១] បានធ្វើឱ្យអនុបាតឥណទានធៀបនឹងផ.ស.ស កើនឡើងដល់ ១៧៩% (ក្រាហ្វ ២.៣) និងធ្វើឱ្យគម្លាត

**២.២ ប្រព័ន្ធធនាគារនៅកម្ពុជា**
(កំណើន ឆ្នាំលើឆ្នាំ)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៣ អនុបាតឥណទានធៀបនឹងផ.ស.ស និងកំណើនឥណទាន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១] ឥណទានសំដៅលើឥណទានផ្តល់ដោយធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

រវាងឥណទាននិងផ.ស.ស[១០] កើនឡើងដល់ ៤២,៧%។ ការកើនឡើងនៃគម្លាតនេះ បណ្ដាលមកពីការធ្លាក់ចុះកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែទាមទារនូវការតាមដានបន្ថែម។ លើសពីនេះ ការកើនឡើងលឿននៃឥណទានមួយផ្នែកមកពីការកើនឡើងនៃភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ ដោយគ្រឹះស្ថានធនាគារបានពង្រីកវិសាលភាពប្រតិបត្តិការរបស់ខ្លួន។ កំណើនឥណទាន ព្រមទាំងការវិវត្តកាន់តែទូលំទូលាយនៃទ្រព្យសកម្មនិងលទ្ធភាពសងត្រលប់របស់អតិថិជន ត្រូវបានវិភាគលម្អិតលើគុណភាពទ្រព្យសកម្មធនាគារនៅផ្នែកបន្ទាប់។

## ២.២ គ្រឹះស្ថានធនាគារពាណិជ្ជ

### ក. អន្តរការីយកម្មឥណទាននិងហានិភ័យឥណទាន

**ឥណទានរបស់ធនាគារពាណិជ្ជបានផ្ដល់ទៅកាន់វិស័យឯកជន ដោយឥណទានសាជីវកម្មមានចំណែកធំជាងគេ និងបន្ទាប់មកគឺឥណទានទៅកាន់ក្រុមគ្រួសារ។** ឥណទានទៅកាន់វិស័យឯកជនបានបន្តកើនឡើងក្នុងឆ្នាំ២០២១ ក្នុងកម្រិត ២៦,៤% ធៀបនឹងកំណើន ២៣,៧% ក្នុងឆ្នាំ២០២០ (ក្រាហ្វ ២.៤)។ សមាមាត្រឥណទានទៅកាន់វិស័យសាធារណៈនិងឯកជន បានបង្ហាញថា ឥណទានរបស់ធនាគារស្ទើរតែទាំងស្រុងត្រូវបានផ្ដល់ទៅកាន់វិស័យឯកជន ដោយឥណទានទៅកាន់វិស័យសាធារណៈមានចំណែកត្រឹម ០,៨% ប៉ុណ្ណោះក្នុងឆ្នាំ២០២១។ លើសពីនេះ ចាប់តាំងពីឆ្នាំ២០១៦មក ឥណទានទៅកាន់វិស័យសាធារណៈទាំងអស់ ត្រូវបានផ្ដល់ទៅកាន់សហគ្រាសរដ្ឋ ដោយសាររាជរដ្ឋាភិបាលមិនមានស្នើសុំឥណទានថ្មីពីវិស័យធនាគារនោះទេ ដែលបានបង្ហាញថា វិស័យឯកជននៅ

២.៤ កម្ចីពីធនាគារពាណិជ្ជ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១០] គម្លាតនេះគឺជាភាពខុសគ្នារវាងអនុបាតឥណទានធៀបនឹងផ.ស.សនិងនិន្នាការរយៈពេលវែង វាស់ស្ទង់តាមរយៈ one-side HP filter with a smoothing parameter ស្មើនឹង ៤០០.០០០។

តែជាវិស័យចម្បងដែលទទួលបានឥណទានពីធនាគារ ដោយគ្រឹះស្ថានធនាគារបន្តដើរតួនាទីក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច។

នៅក្នុងវិស័យឯកជន ឥណទានមួយផ្នែកធំត្រូវបានផ្តល់ទៅកាន់សាជីវកម្ម បន្ទាប់មកគឺក្រុមគ្រួសារ។ ជាក់ស្តែង ក្នុងឆ្នាំ២០២១ ឥណទានសម្រាប់សាជីវកម្ម (រួមបញ្ចូលធុរកិច្ចគ្រប់ប្រភេទ និងទំហំ) មានទំហំ ១១៩ ទ្រីលានរៀលនៃឥណទានសរុប (៧៦,៦% នៃឥណទានទៅកាន់វិស័យឯកជន) ជាមួយនឹងកំណើន ២៦,១%។ ទន្ទឹមនេះ ឥណទានទៅកាន់ក្រុមគ្រួសារមានទំហំ ៣៦,៣ ទ្រីលានរៀល ដែលរួមចំណែកប្រមាណ ២៣,៤% នៃឥណទានរបស់ធនាគារទៅកាន់វិស័យឯកជន។ ការរួមចំណែកនៃឥណទានទៅកាន់ក្រុមគ្រួសារបានបន្តកើនឡើងក្នុងរយៈពេលកន្លងមក ដោយកើនឡើងពី ១៨,៧% ក្នុងឆ្នាំ២០១៦ ដល់ ២៣,៤% នៅឆ្នាំ២០២១ (ក្រាហ្វ ២.៥)។

**ឥណទានភាគច្រើនត្រូវបានផ្តល់ជាប្រាក់ដុល្លារអាមេរិក ខណៈពេលដែលការផ្តល់ឥណទានជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារបន្តស្ថិតនៅលើកម្រិតកំណត់ដោយធនាគារជាតិនៃកម្ពុជា ១០%។** ការបែងចែកឥណទានសរុបតាមរូបិយប័ណ្ណបានបង្ហាញថា ឥណទានជាដុល្លារអាមេរិកមានប្រមាណជិត ៨៨,៦% នៃឥណទានសរុបក្នុងឆ្នាំ២០២១ ខណៈឥណទានជារៀលមានប្រមាណ ១១,៤% (ក្រាហ្វ ២.៦)។ ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ច កាលពីឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសតម្រូវឱ្យគ្រឹះស្ថានធនាគារផ្តល់ឥណទានជារៀលយ៉ាងតិច ១០% នៃសំពៀតឥណទានសរុប។ ជាលទ្ធផល ការរួមចំណែករបស់ឥណទានជារៀលក្នុងឥណទានសរុបបានបន្តកើនឡើងពី ១,៥% ក្នុងឆ្នាំ២០១៦ ដល់ ១១,៤% ក្នុងឆ្នាំ

២.៥ **ឥណទានទៅកាន់វិស័យឯកជន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៦ **ឥណទានតាមរូបិយប័ណ្ណ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២០២១ បើទោះបានកើនឡើងយឺតធៀបនឹងឆ្នាំ ២០២០ក៏ដោយ។ ការលើកកម្ពស់ការផ្តល់ឥណទានជារៀលត្រូវបានគាំទ្រដោយប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ។

**ជារួម ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារពាណិជ្ជត្រូវបានបែងចែកទៅកាន់វិស័យផ្សេងៗក្នុងសេដ្ឋកិច្ច ខណៈឥណទានមួយភាគពីរ ត្រូវបានផ្តល់ទៅកាន់វិស័យធំៗពីររួមមាន៖ ឥណទានទិញផ្ទះ សំណង់ និងអចលនទ្រព្យ និងបន្ទាប់មករួមមាន ការជួញដូរដុំនិងរាយ។** ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារពាណិជ្ជទៅកាន់វិស័យនានាបង្ហាញថា ការជួញដូររាយរួមចំណែកធំជាងគេជាមួយនឹងសមតុល្យឥណទានប្រមាណ ២៦ ទ្រីលានរៀល និងរួមចំណែកប្រមាណ ១៦,៧% នៃឥណទានធនាគារសរុប (ក្រាហ្វ ២.៧)។ ឥណទានទិញផ្ទះមានចំនួន ២២,៣ ទ្រីលានរៀល និងមានចំណែកធំទី២ ប្រមាណ ១៤,៤% នៃឥណទានសរុប។ ឥណទានត្រូវបានផ្តល់ទៅកាន់វិស័យ ៤ ផ្សេងទៀតក្នុងសមាមាត្រប្រហាក់ប្រហែលគ្នា ប្រមាណ ៩% (ការជួញដូរដុំ សំណង់ សកម្មភាពអចលនទ្រព្យ និងឥណទានផ្ទាល់ខ្លួនផ្សេងទៀតដែលមិនរួមបញ្ចូលឥណទានទិញផ្ទះ)។ ឥណទានធនាគារទៅកាន់សណ្ឋាគារនិងភោជនីយដ្ឋានមានកម្រិតទាប ប្រមាណ ៤,៧% នៃសមតុល្យឥណទានសរុប ដោយវិស័យនេះបានរងផលប៉ះពាល់ខ្លាំងពីការបិទខ្ទប់ប្រទេសដោយសារវិបត្តិជំងឺកូវីដ-១៩ និងការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរអន្តរជាតិ។

ល្បឿននៃការផ្តល់ឥណទានបានកើនឡើងនៅក្នុងវិស័យមួយចំនួនធំ។ បន្ទាប់ពីបានថមថយក្នុងឆ្នាំ២០២០ វិស័យចម្បងៗទាំងអស់មានកំណើនរឹងមាំក្នុងឆ្នាំ២០២១ ជាពិសេសឥណទានទៅកាន់វិស័យសណ្ឋាគារនិងភោជនីយដ្ឋាន (កើន ៩១,៦%

**២.៧**

**ឥណទានធនាគារទៅតាមវិស័យ តម្លៃនិងសមាមាត្រ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឆ្នាំលើឆ្នាំ) បើទោះជាបានកើនពីកម្រិតទាបក៏ដោយ (ក្រាហ្វ ២.៨)។ កំណើននេះបង្ហាញពីកំណើនតម្រូវការហិរញ្ញប្បទានរបស់វិស័យនេះដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩។ វិស័យផ្សេងៗទៀតដូចជា ការជួញដូររាយ ឥណទានទិញផ្ទះ សកម្មភាពអចលនទ្រព្យ និងកសិកម្ម មានកំណើនឥណទានប្រមាណ ៣០% ឆ្នាំលើឆ្នាំ ខណៈការជួញដូរដុំមានកំណើនយឺតត្រឹម ២១,៣% ធៀបនឹងវិស័យចម្បងៗផ្សេងទៀត។

ចំណែកឥណទានទៅកាន់វិស័យអចលនទ្រព្យនិងក្រុមគ្រួសារបានបន្តកើនឡើង។ ដោយល្បឿននិងទំហំនៃការផ្តល់ឥណទានទៅកាន់វិស័យនានាមានភាពខុសៗគ្នា និន្នាការនៃការផ្តល់ឥណទានបានបង្ហាញពីចំណែករបស់វិស័យមួយចំនួនមានការកើនឡើង (ក្រាហ្វ ២.៩)។ ជាក់ស្តែង ចំណែកឥណទានទៅកាន់ក្រុមគ្រួសារ (រួមមាន ឥណទានទិញផ្ទះ និងការឱ្យខ្ចីជាបុគ្គល) និង ចំណែកឥណទានសម្រាប់សកម្មភាពអចលនទ្រព្យបានកើនឡើង ខណៈចំណែកឥណទានទៅកាន់វិស័យកម្មន្តសាលនិងការជួញដូរដុំបានថយចុះ។ ដោយសារឥណទានសម្រាប់ក្រុមគ្រួសារជាឥណទានទំហំតូចនិងមានការធ្វើពិពិធកម្ម ការកើនឡើងនៃការផ្តល់ឥណទានរបស់ធនាគារទៅកាន់ក្រុមគ្រួសារ គួរតែពង្រឹងការធ្វើពិពិធកម្មនៃសំពៀតឥណទានតាមរយៈការអនុវត្តការផ្តល់ឥណទានដោយប្រុងប្រយ័ត្ន។

**ទោះយ៉ាងណា ការប្រមូលផ្តុំនៃការផ្តល់ឥណទានសម្រាប់ធនាគារធំជាងគេចំនួន៥បានថមថយ។** ក្នុងឆ្នាំ២០២១ ការផ្តល់ឥណទានពីធនាគារធំជាងគេចំនួន៥ មានចំណែកប្រមាណជិតពាក់កណ្តាល (៤៩,៧%) នៃឥណទានសរុបក្នុងវិស័យឯកជន ដោយធនាគារធំជាងគេចំនួន៣

២.៨ **ឥណទានធនាគារតាមវិស័យ**

(កំណើន ឆ្នាំលើឆ្នាំ)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៩ **ឥណទានធនាគារតាមវិស័យសំខាន់ៗ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

មានចំណែកប្រមាណ ៥០,១% (ក្រាហ្វ ២.១០)។ ធនាគារធំជាងគេទី ៦ ដល់ ១៥ មានចំណែក ២៤,២% នៃឥណទានសរុប ខណៈធនាគារ ៣៩ ផ្សេងទៀតរួមចំណែក ២៦,១% ក្នុងឆ្នាំ២០២១។ ចំណែកនៃឥណទានរបស់ធនាគារធំជាងគេចំនួន៥ បានថមថយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដោយចំណែកនៃការផ្តល់ឥណទានរបស់ធនាគារតូចៗចាប់ផ្តើមកើនឡើង គួបផ្សំនឹងការកើនឡើងនៃចំនួនធនាគារ។ លើសពីនេះ រចនាសម្ព័ន្ធក្នុងវិស័យធនាគារត្រូវបានផ្លាស់ប្តូរ ដោយការរីកលូតលាស់នៃឌីជីថលូបនីយកម្មហិរញ្ញវត្ថុបានបង្កើនភាពប្រកួតប្រជែងផងដែរ។

**កំណើនឥណទានទៅកាន់ក្រុមគ្រួសារត្រូវបានជំរុញជាចម្បងដោយកម្ចីទិញផ្ទះ។** ឥណទានទៅកាន់ក្រុមគ្រួសារបានកើនឡើង ២៧,៤% ក្នុងឆ្នាំ២០២១ ដែលជាកំណើនសមស្របមួយ ប៉ុន្តែនៅមានល្បឿនយឺតជាងកំណើនក្នុងរយៈពេល៦ឆ្នាំចុងក្រោយ (ក្រាហ្វ ២.១១)។ ឥណទានសរុបទៅកាន់ក្រុមគ្រួសារមាន ៣៦,៣ ទ្រីលានរៀល ដែលបានធ្វើឱ្យក្រុមគ្រួសារជាវិស័យចម្បងក្នុងការទទួលបានឥណទានពីគ្រឹះស្ថានធនាគារ ដោយរួមចំណែកប្រមាណ ២៣,២% នៃសមតុល្យឥណទានសរុប។ ក្នុងនោះ កម្ចីទិញផ្ទះមានចំណែកប្រមាណ ៦១,៥% ដែលបានផ្តល់ទៅកាន់ក្រុមគ្រួសារ និងសម្រាប់តែការទិញផ្ទះលើកដំបូងប៉ុណ្ណោះ ខណៈចំណែកផ្សេងទៀត (៣៨,៥%) រួមមាន ការឱ្យខ្ចីជាបុគ្គល និងការឱ្យខ្ចីប័ណ្ណឥណទាន។

**ឥណទានទៅកាន់វិស័យអចលនទ្រព្យ និងសំណង់មានចំណែកប្រមាណជិត ១ភាគ៥ នៃឥណទានធនាគារសរុប និងមានចំណែកកើនដល់ប្រមាណជាង ១ភាគ៣ បើរួមបញ្ចូលទាំងកម្ចីទិញផ្ទះ។** ឥណទានធនាគារទៅកាន់

**២.១០ សមាមាត្រឥណទានតាមធនាគារ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.១១ ប្រាក់កម្ចីពីធនាគារទៅកាន់ក្រុមគ្រួសារ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សកម្មភាពអចលនទ្រព្យនិងវិស័យសំណង់មានកំណើន ៣០% និង ២២,៣% រៀងគ្នា ក្នុងឆ្នាំ ២០២១ (ក្រាហ្វ ២.១២)។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ឥណទានទៅកាន់វិស័យអចលនទ្រព្យមានកំណើនខ្ពស់ ធៀបនឹងឥណទានទៅកាន់វិស័យសំណង់ ដែលធ្វើឱ្យការរួមចំណែករបស់ឥណទានទៅកាន់វិស័យអចលនទ្រព្យកើនពី ៣៨% ដល់ ៤៨% នៃឥណទានទៅកាន់វិស័យអចលនទ្រព្យនិងសំណង់សរុបនៅក្នុងរយៈពេលដូចគ្នា។

**២.១២ ឥណទានទៅកាន់វិស័យអចលនទ្រព្យនិងសំណង់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បញ្ហាប្រឈមពាក់ព័ន្ធនឹងឥណទានទៅកាន់វិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារអាចត្រូវបានវាយតម្លៃតាមរយៈការបូកបញ្ចូលឥណទានទៅកាន់ផ្នែក៖ i/-អចលនទ្រព្យ ii/-សំណង់ iii/-ឥណទានទិញផ្ទះផ្ទាល់ខ្លួនរបស់ក្រុមគ្រួសារ។ ឥណទានសរុបរបស់ផ្នែកទាំង៣នេះបានបង្ហាញថា ការផ្តល់ឥណទានពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យរបស់ធនាគារមានចំណែកប្រមាណជាង ១ភាគ៣ នៃសំពៀតឥណទានសរុប (ក្រាហ្វ ២.១៣)។ ចំណែកនេះបានកើនឡើងក្នុងរយៈពេលកន្លងមកពី ២២% ក្នុងឆ្នាំ២០១៦ ដល់ ៣៣% ក្នុងឆ្នាំ២០២១។

**២.១៣ ឥណទានទៅកាន់វិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទោះបីជាគ្រឹះស្ថានធនាគារបានផ្តល់ឥណទានច្រើនទៅកាន់វិស័យអចលនទ្រព្យ ប៉ុន្តែហានិភ័យឥណទាននៃអនុវិស័យទាំង៣ នៅតែអាចគ្រប់គ្រងបាន។ ហានិភ័យពីការផ្តល់កម្ចីទិញផ្ទះមានលក្ខណៈខុសគ្នាពីការផ្តល់ឥណទានដោយផ្ទាល់របស់ធនាគារទៅកាន់វិស័យអចលនទ្រព្យនិងសំណង់ ដោយកម្ចីទិញផ្ទះគឺជាឥណទានទំហំតូចៗទៅកាន់ក្រុមគ្រួសារច្រើន និងមានលក្ខណៈពិពិធកម្ម។ ទីផ្សារអចលនទ្រព្យនៅបន្តមានភាពធន់ ទោះក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ ដោយសន្ទស្សន៍ថ្លៃលំនៅដ្ឋានបន្តមាន

កំណើន ១២,២% ក្នុងឆ្នាំ២០២១ (សូមមើលក្រាហ្វ ១.១១ ក្នុងជំពូក១)។ ស្របពេលដែលទីផ្សារអចលនទ្រព្យសម្រាប់ពាណិជ្ជកម្មបានរងផលប៉ះពាល់ខ្លាំងក្នុងអំឡុងពេលបិទខ្ទប់ដោយសារវិបត្តិជំងឺកូវីដ-១៩ ឥណទានរបស់គ្រឹះស្ថានធនាគារទៅវិស័យនេះមានចំណែកត្រឹម ៦% នៃឥណទានទៅកាន់សកម្មភាពអចលនទ្រព្យសរុប។ ទោះយ៉ាងណា តម្លៃអចលនទ្រព្យនាពេលខាងមុខនៅមានភាពមិនច្បាស់លាស់ ក្នុងពេលដែលអត្រាជួលនៃប្រភេទអចលនទ្រព្យខ្លះមានកម្រិតទាប បូកនឹងមានការផ្គត់ផ្គង់បន្ថែមទៅក្នុងទីផ្សារក្នុងអំឡុងឆ្នាំ២០២២-២០២៣[១១]។

កំណើនខ្ពស់នៃឥណទាន គួបផ្សំនឹងការដាក់ចេញនូវវិធានការអនុគ្រោះដោយធនាគារជាតិនៃកម្ពុជា បានធ្វើឱ្យកម្រិតឥណទានមិនដំណើរការបន្តមានកម្រិតទាប។ អនុបាតឥណទានមិនដំណើរការរបស់ធនាគារពាណិជ្ជបានថយចុះមកនៅត្រឹម ១,៨% ដែលជាកម្រិតប្រហាក់ប្រហែលនឹងកម្រិតមុនវិបត្តិជំងឺកូវីដ-១៩ និងមានភាពប្រសើរជាង កម្រិត ១,៩% កាលពីឆ្នាំ២០២០ (ក្រាហ្វ ២.១៤)។ បើទោះជាឥណទានមិនដំណើរការសរុបបានកើនឡើង (កើន ១៨%) ក្នុងឆ្នាំ២០២១ ប៉ុន្តែកំណើនឥណទានខ្ពស់បានធ្វើឱ្យអនុបាតឥណទានមិនដំណើរការថយចុះមកវិញ។ លើសពីនេះវិធានការអនុគ្រោះដែលបានដាក់ចេញចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩ បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគាររៀបចំឥណទានឡើងវិញ ដោយរក្សាចំណាត់ថ្នាក់ឥណទានដដែល។ ជាក់ស្តែង គ្រឹះស្ថានធនាគារបានរៀបចំឥណទានឡើងវិញជាមធ្យម ប្រមាណ

**២.១៤ ឥណទានមិនដំណើរការ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១១] ការស្រាវជ្រាវរបស់ក្រុមហ៊ុនអចលនទ្រព្យក្នុងស្រុក CBRE បានបង្ហាញថាការផ្គត់ផ្គង់ខុនដូត្រូវបានរំពឹងថានឹងអាចកើនឡើងគុណនឹងពីរក្នុងរយៈពេល២ឆ្នាំខាងមុខនេះ។ ការផ្គត់ផ្គង់ផ្សារទំនើបសហគមន៍និងទីតាំងការិយាល័យក៏ត្រូវបានរំពឹងនឹងកើនឡើងជាង ២០% ក្នុងរយៈពេលដូចគ្នានេះដែរ។ កំណើននៃការផ្គត់ផ្គង់អាចនឹងដាក់បន្ទុកដល់តម្លៃប្រសិនបើមិនមានតម្រូវការគ្រប់គ្រាន់ ដោយសារអត្រាជួលមានកម្រិតទាបជាង ៧០% សម្រាប់ប្រភេទអចលនទ្រព្យទាំងពីរនេះ យោងតាម CBRE។

១០,៩% នៃឥណទានសរុប ចាប់ពីខែមេសា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២១។

កាលពីខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំស្តីពីកាតព្វកិច្ចធ្វើចំណាត់ថ្នាក់ និងសំវិធានធនចំពោះឥណទានរៀបចំឡើងវិញ ដោយតម្រូវឱ្យគ្រឹះស្ថានធនាគារកំណត់ឥណទានដំណើរការជាឥណទានមានស្ថានភាពល្អ និងត្រូវបានចាត់ថ្នាក់ជាឥណទាន "ឃ្លាំមើល" ដែលត្រូវធ្វើសំវិធានធន ៣% នៃឥណទានដុល។ ឥណទានរៀបចំឡើងវិញដែលមានស្ថានភាពមិនល្អ ត្រូវបានកំណត់ជាឥណទានមិនដំណើរការ និងត្រូវចាត់ថ្នាក់ថា "ឥណទានបាត់បង់" ដែលត្រូវធ្វើសំវិធានធន ១០០% នៃឥណទានដុល។ ជាលទ្ធផល ចំណែកនៃឥណទានឃ្លាំមើលបានកើនឡើងក្នុងឆ្នាំ ២០២១ (ក្រាហ្វ ២.១៥)។ ចំណែកធំ (៦៣%) នៃឥណទានឃ្លាំមើលក៏បានបង្ហាញថាគ្រឹះស្ថានធនាគារបានចាត់ថ្នាក់ឥណទានរៀបចំឡើងវិញភាគច្រើនថាជាឥណទានមានស្ថានភាពល្អ។ ផ្ទុយពីនេះ ចំណែកនៃឥណទានបាត់បង់មានចំណែកតូច (១៩%)។ ជារួម ការធ្វើចំណាត់ថ្នាក់ឥណទានមិនដំណើរការបានបង្ហាញថា ផលប៉ះពាល់នៃការថមថយកំណើនសេដ្ឋកិច្ចបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ ទៅលើគុណភាពទ្រព្យសកម្មរបស់ធនាគារ គឺត្រូវបានគ្រប់គ្រងបាន។

**២.១៥ ចំណាត់ថ្នាក់ឥណទានមិនដំណើរការ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឥណទានមិនដំណើរការទៅតាមវិស័យបានបង្ហាញថាវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំណែកធំជាងគេ (៥៧៧ ប៊ីលានរៀល) បន្ទាប់មកការជួញដូររាយ (៤២៣ ប៊ីលានរៀល) និងសំណង់ (២៧១ ប៊ីលានរៀល) (ក្រាហ្វ ២.១៦)។ ក្នុងឆ្នាំ២០២១ ឥណទានមិនដំណើរការរបស់វិស័យមួយចំនួនធំបានកើនឡើង លើកលែងកម្មន្តសាលដែលបានថយចុះប្រមាណ ៧៥,៨

**២.១៦ ឥណទានមិនដំណើរការតាមវិស័យ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប៊ីលានរៀល។ ឥណទានរៀបចំឡើងវិញក្នុងវិស័យសណ្ឋាគារនិងភោជនីយដ្ឋានមានកំណើនខ្ពស់ជាងគេ (១០៨ ប៊ីលានរៀល) បន្ទាប់មកការជួញដូររាយ (៩៩ ប៊ីលានរៀល) និងតម្រូវការផ្ទាល់ខ្លួន (៥៩,៥ ប៊ីលានរៀល)។ ទន្ទឹមនេះ ឥណទានរៀបចំឡើងវិញសម្រាប់សកម្មភាពអចលនទ្រព្យ និងសំណង់មានកំណើនតិចតួចប្រមាណ ១០,៥ ប៊ីលានរៀល និង ២៨,៩ ប៊ីលានរៀល រៀងគ្នា។

អនុបាតឥណទានមិនដំណើរការតាមវិស័យបានបង្ហាញពីនិន្នាការស្របគ្នាជាមួយនឹងអត្រាឆ្លងជំងឺកូវីដ-១៩ ទោះបីជាវិស័យមួយចំនួនមាននិន្នាការខុសគ្នា។ អនុបាតឥណទានមិនដំណើរការនៃវិស័យសណ្ឋាគារនិងភោជនីយដ្ឋានបានកើនឡើងពី ២,៩% ក្នុងឆ្នាំ២០២០ ដល់ ៣,១% ក្នុងឆ្នាំ២០២១ ដោយវិស័យនេះបន្តស្ថិតក្នុងស្ថានភាពតានតឹង ទន្ទឹមនឹងការបន្តធ្លាក់ចុះនៃការមកដល់នៃភ្ញៀវទេសចរ និងវិធានការការបិទខ្ទប់ក្នុងឆ្នាំ២០២១ (ក្រាហ្វ ២.១៧)។ អនុបាតឥណទានមិនដំណើរការនៃវិស័យមិនមែនសេវាហិរញ្ញវត្ថុផ្សេងទៀតក៏មានការកើនឡើង។ ទោះយ៉ាងណា អនុបាតឥណទានមិនដំណើរការនៃវិស័យមួយចំនួនបានថយចុះ រួមមាន កសិកម្ម សំណង់ ឧស្សាហកម្មរ៉ែ ការជួញដូរដុំ និងភតិសន្យាប្រតិបត្តិការ ដែលបានជួយធ្វើឱ្យអនុបាតឥណទានមិនដំណើរការសរុបថយចុះបន្តិចពី ១,៩% ក្នុងឆ្នាំ២០២០ មកនៅ ១,៨% ក្នុងឆ្នាំ២០២១។ អនុបាតឥណទានមិនដំណើរការសម្រាប់សកម្មភាពអចលនទ្រព្យមានកម្រិតទាប ក្នុងចំណោមវិស័យផ្សេងៗក្នុងផ្នែកធុរកិច្ច ដោយបន្តមានអនុបាត ១% ក្នុងរយៈពេល២ឆ្នាំជាប់គ្នា។

**២.១៧ អនុបាតឥណទានមិនដំណើរការតាមវិស័យ**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អនុបាតឥណទានមិនដំណើរការរបស់ឥណទាន២ប្រភេទក្នុងវិស័យក្រុមគ្រួសារ (ឥណទានទិញផ្ទះ និងឥណទានបុគ្គលផ្សេងទៀត)

បន្តមានកម្រិតទាប ១% និង ១,៥% រៀងគ្នា បើទោះជាឥណទានបុគ្គលផ្សេងទៀតបានកើនឡើងបន្តិចបើធៀបនឹង ១,៣% នៅឆ្នាំ២០២០ (ក្រាហ្វ ២.១៨)។ ចំណែកនៃកម្ចីទិញផ្ទះដែលមានប្រមាណ ៦២% នៃឥណទានក្រុមគ្រួសារសរុប និងគុណភាពល្អនៃឥណទាន បានជួយធ្វើឱ្យអនុបាតឥណទានមិនដំណើរការសរុបរបស់វិស័យក្រុមគ្រួសារស្ថិតក្នុងកម្រិតទាប ១,២%។

**សំវិធានធនជាក់លាក់បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលកន្លងមក ដែលបានផ្តល់ទ្រនាប់ការពារបន្ថែមដល់គ្រឹះស្ថានធនាគារក្នុងការទប់ទល់នឹងហានិភ័យនានាពីការថយចុះនៃគុណភាពឥណទាន។** ក្នុងឆ្នាំ២០២១ សំវិធានធនជាក់លាក់បានកើនដល់ ១,៨ ទ្រីលានរៀលជំរុញដោយកំណើននៃសំវិធានធនជាក់លាក់បន្ថែម ៤៩៧ ប៊ីលានរៀល ដែលជាការកើនឡើងខ្ពស់បំផុតក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (ក្រាហ្វ ២.១៩)។ ជាលទ្ធផល សំវិធានធនជាក់លាក់ធៀបនឹងឥណទានមិនដំណើរការមានកម្រិត ៦០% ដែលជាកម្រិតខ្ពស់បំផុតក្នុងរយៈពេលចុងក្រោយនេះ បើទោះជាមានកំណើនឥណទានមិនដំណើរការ ដោយសេដ្ឋកិច្ចបន្តប្រឈមនឹងការថយចុះដោយសារវិបត្តិជំងឺកូវីដ-១៩។ ការបន្តកើនឡើងនៃសំវិធានធននេះគឺត្រូវបានលើកទឹកចិត្ត ដោយអាចជួយដល់គ្រឹះស្ថានធនាគារក្នុងការគ្រប់គ្រងការកើនឡើងនៃឥណទានមិនដំណើរការ នៅពេលដែលវិធានការបទប្បញ្ញត្តិគាំទ្រនានាត្រូវបានដកចេញទាំងស្រុង។

២.១៨ **អនុបាតឥណទានមិនដំណើរការសម្រាប់ឥណទានក្រុមគ្រួសារ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.១៩ **ឥណទានមិនដំណើរការ និងសំវិធានធន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. ស្ថានភាពសន្ទនីយភាពនិងប្រភពមូលនិធិ

កម្រិតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនៅបន្តមានកម្រិតខ្ពស់ បើទោះជាមានការថយចុះបន្តិចក្នុងឆ្នាំ២០២១ ក៏ដោយ។ អនុបាតក្របខ័ណ្ឌសន្ទនីយភាពដែលជាវិធានការម៉ាក្រូប្រុងប្រយ័ត្នមួយធានាថាគ្រឹះស្ថានធនាគារមានបរិមាណទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ សំដៅបំពេញតម្រូវការសន្ទនីយភាពក្នុងរយៈពេល ៣០ថ្ងៃ ត្រូវបានដាក់អនុវត្តជាលើកដំបូងនៅខែកញ្ញា ឆ្នាំ២០១៦ ជាមួយនឹងការកំណត់កម្រិតអប្បបរមា ៦០%។ អនុបាតក្របខ័ណ្ឌសន្ទនីយភាពត្រូវបានដាក់ឱ្យអនុវត្តជាដំណាក់កាល រហូតបានបំពេញទាំងស្រុងក្នុងកម្រិត ១០០% ក្នុងឆ្នាំ២០២០ ដែលស្របតាមគោលការណ៍បាសែល III។ អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារពាណិជ្ជមានកម្រិត ១៥១,៦% ក្នុងឆ្នាំ២០២១ ដែលខ្ពស់ជាងកម្រិតដោយបទប្បញ្ញត្តិ (១០០%) ដែលការណ៍នេះបានបង្ហាញពីភាពធន់នៃកម្រិតសន្ទនីយភាព ដើម្បីប្រឈមមុខនឹងស្ថានភាពតានតឹងផ្នែកសាច់ប្រាក់ក្នុងរយៈពេលខ្លីណាមួយ (ក្រាហ្វ ២.២០)។

**២.២០ អនុបាតក្របខ័ណ្ឌសន្ទនីយភាពនៃធនាគារ**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កម្រិតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារបានថយចុះតិចតួច តាមរយៈការវិភាគលើសូចនាករផ្សេងៗទៀត។ ជាក់ស្តែង អនុបាតទ្រព្យសកម្មសន្ទនីយធៀបនឹងទ្រព្យសកម្មសរុប ដែលជាអនុបាតបង្ហាញពីលទ្ធភាពអាចបំពេញលំហូរចេញនៃសាច់ប្រាក់ទាំងរំពឹងទុកនិងមិនបានរំពឹងទុក បានថមថយពី ១៧,៦% ក្នុងឆ្នាំ២០២០ ដល់ ១៦,២% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ២.២១)។ ទន្ទឹមនេះ ទ្រព្យសកម្មសន្ទនីយធៀបនឹងបំណុលរយៈពេលខ្លី ដែលបង្ហាញពីកម្រិតដែលគ្រឹះស្ថានធនាគារអាចបំពេញការដកមូលនិធិក្នុងរយៈពេលខ្លីដោយមិនមានការដកសាច់ប្រាក់ បានថយចុះពី ២៧,១% មក ២៥,៣% ក្នុងអំឡុងពេលដូចគ្នា។

**២.២១ អនុបាតសន្ទនីយភាព**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការកើនឡើងខ្ពស់នៃឥណទាន ធៀបទៅនឹងការកៀរគរប្រាក់បញ្ញើ ក៏នាំឱ្យមានការកើនឡើងនៃអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើក្នុងកម្រិត ១០៨,៧% នៅឆ្នាំ២០២១។

**២.២២ ប្រភពមូលនិធិនៃធនាគារ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្រាប់ប្រភពមូលនិធិរបស់គ្រឹះស្ថានធនាគារ សមាមាត្រប្រាក់បញ្ញើរបស់អតិថិជនបានកើនឡើងដល់ ៦៥,៥% នៃប្រភពទុនសរុប ស្របពេលដែលមូលនិធិកម្ចី (រយៈពេលខ្លីនិងវែង) មានចំណែក ១៣,៣% និងដើមទុនមានចំណែកប្រមាណ ២១% (ក្រាហ្វ ២.២២)។ ប្រភពមូលនិធិជារួមមានស្ថិរភាព ដោយប្រាក់បញ្ញើរបស់អតិថិជនស្ថិតក្នុងរង្វង់ប្រមាណ ២/៣ នៃប្រភពមូលនិធិរបស់គ្រឹះស្ថានធនាគារ។ យោងតាមការវិភាគតាមប្រភេទនៃប្រាក់បញ្ញើបានបង្ហាញថា ប្រាក់បញ្ញើមានកាលកំណត់មានសមាមាត្រធំជាងគេ ៤៥,២% បន្ទាប់មកប្រាក់បញ្ញើសន្សំ ៣០,៥% និងប្រាក់បញ្ញើចរន្ត ២៤%។ ក្នុងឆ្នាំ២០២១ ប្រាក់បញ្ញើសរុបរបស់អតិថិជនបានកើន ១៥,១% (ដល់ ១៤២,៩ ទ្រីលានរៀល) ធៀបនឹង ១៤,៦% ក្នុងឆ្នាំ២០២០។

**២.២៣ ប្រាក់បញ្ញើអតិថិជន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារមួយចំនួនធំគឺជាប្រាក់ដុល្លារអាមេរិក ដូចនឹងឥណទានដែរ។ អតិថិជនភាគច្រើននៅតែបន្តជ្រើសរើសដាក់ប្រាក់បញ្ញើជាដុល្លារអាមេរិក ដែលមានសមាមាត្រ ៩១,៤% នៃប្រាក់បញ្ញើសរុបក្នុងឆ្នាំ២០២១។ ខណៈពេលដែលចំណែកនៃប្រាក់បញ្ញើជារៀលបានកើនឡើងពី ៦,១% ក្នុងឆ្នាំ២០១៨ ដល់ ៩,៦% ក្នុងឆ្នាំ២០២១ កម្រិតដុល្លាររូបនីយកម្មបន្តមានកម្រិតខ្ពស់ (ក្រាហ្វ ២.២៣)។ វិធានការរបស់ធនាគារជាតិនៃកម្ពុជាដែលតម្រូវឱ្យធនាគារផ្តល់ឥណទានជារៀលយ៉ាងតិច ១០% នៃឥណទានសរុប បានលើកទឹកចិត្តឱ្យធនាគារបង្កើនការដាក់ប្រាក់បញ្ញើជារៀលបន្ថែមទៀត ប៉ុន្តែទំហំឥណទានជារៀលក្នុងឆ្នាំ២០២១

(១៨,៣ ទ្រីលានរៀល) បន្តមានកម្រិតខ្ពស់ជាងទំហំប្រាក់បញ្ញើជារៀល (១៣,៧ ទ្រីលានរៀល) ដែលទាមទារឱ្យធនាគារជាតិនៃកម្ពុជាត្រូវចាក់បញ្ចូលសាច់ប្រាក់ជារៀលជាបន្តបន្ទាប់តាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា។

សម្រាប់ឥណប្រតិទាននៃឥណទាននិងប្រាក់បញ្ញើរបស់ធនាគារក្នុងឆ្នាំ២០២១បានបង្ហាញថា ប្រាក់បញ្ញើជារួមមានទំហំធំជាងឥណទានសម្រាប់ឥណប្រតិទានរយៈពេលខ្លី ខណៈដែលឥណទានមានទំហំធំជាងប្រាក់បញ្ញើសម្រាប់ឥណប្រតិទានរយៈពេល២ឆ្នាំនិងលើសពីនេះ (ក្រាហ្វ ២.២៤)។ ជាក់ស្តែង ភាពមិនស៊ីគ្នានៃឥណប្រតិទានរវាងឥណទាននិងប្រាក់បញ្ញើគឺមានភាពប្រក្រតី ដោយសារមុខងាររបស់ធនាគារក្នុងការបម្លែងឥណប្រតិទាន ដោយបំណុលរយៈពេលខ្លីត្រូវបានប្រែក្លាយទៅជាទ្រព្យសកម្មរយៈពេលវែង។ ទោះយ៉ាងណា ប្រសិនបើភាពមិនស៊ីគ្នានេះមានកម្រិតខ្ពស់ខ្លាំង ធនាគារអាចនឹងជួបប្រទះនឹងហានិភ័យសន្ទនីយភាព ជាពិសេសប្រសិនបើធនាគារទាំងនោះពឹងផ្អែកកាន់តែខ្លាំងទៅលើមូលធនមិនចម្បងដែលមានរយៈពេលខ្លី និងមិនសូវមានស្ថិរភាព។

**២.២៤ ឥណទាននិងប្រាក់បញ្ញើ នៅតាមឥណប្រតិទាន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ. លទ្ធភាពស្វែងរកប្រាក់ចំណេញនិងសាធនភាព

**ប្រាក់ចំណេញសុទ្ធរបស់ធនាគារបានកើនឡើងខ្លាំងក្នុងឆ្នាំ២០២១ បន្ទាប់ពីបានថមថយក្នុងឆ្នាំ២០២០ ដែលជំរុញដោយប្រាក់ចំណូលខ្ពស់ និងកំណើនយឺតនៃការចំណាយលើសំវិធានធន និងការប្រាក់។** លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ធនាគារពាណិជ្ជបានកើនឡើងក្នុងឆ្នាំ២០២១ ដោយប្រាក់ចំណេញសុទ្ធបន្ទាប់ពីការបង់ពន្ធមានកំណើន ២៥% ដល់ ៤,១ ទ្រីលានរៀល (ក្រាហ្វ ២.២៥)។ ធនាគារជាតិនៃកម្ពុជាបានបន្ធូរបន្ថយ

**២.២៥ លទ្ធភាពស្វែងរកប្រាក់ចំណេញ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការហាមឃាត់ក្នុងការបែងចែកភាគលាភ (ដែលបានដាក់ចេញក្នុងឆ្នាំ២០២០) កាលពីឆ្នាំ២០២១ ប៉ុន្តែការបែងចែកប្រាក់ចំណេញរបស់ធនាគារនៅតែមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដើម្បីធានាថាធនាគារបានធ្វើសំវិធានធនតាមចំនួនដែលបានកំណត់ ដូចចែងក្នុងសារាចរណែនាំកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

កំណើននៃប្រាក់ចំណេញសុទ្ធត្រូវបានគាំទ្រដោយកំណើននៃចំណូលការប្រាក់ និងមិនមែនការប្រាក់ ដោយចំណូលមិនមែនការប្រាក់មានកំណើនខ្ពស់ក្នុងឆ្នាំ២០២១ គួបផ្សំនឹងកំណើនយឺតនៃការចំណាយលើការប្រាក់និងសំវិធានធនក៏បានរួមចំណែកគាំទ្រដល់លទ្ធភាពស្វែងរកប្រាក់ចំណេញ (ក្រាហ្វ ២.២៦)។ ស្របពេលដែលការចំណាយលើប្រតិបត្តិការបានកើនឡើងក្នុងល្បឿនលឿនក្នុងឆ្នាំ២០២១ ការចំណាយការប្រាក់មានកំណើនមធ្យម។ បន្ថែមពីនេះ ប្រាក់ចំណេញសុទ្ធត្រូវបានគាំទ្រដោយកំណើនយឺតនៃការចំណាយលើសំវិធានធន (៣៩% ក្នុងឆ្នាំ២០២១) ធៀបនឹងកំណើន ៦១,៥% កាលពីឆ្នាំ២០២០ ដែលធនាគារចាប់ផ្តើមធ្វើសំវិធានធនបន្ថែមអំឡុងពេលការរីករាលដាលវិបត្តិជំងឺកូវីដ-១៩។ ការងើបឡើងវិញនៃសេដ្ឋកិច្ចជាបណ្តើរៗនិងការថយចុះជាបន្តបន្ទាប់នៃភាពមិនច្បាស់លាស់នៃបំណុលរបស់អតិថិជន បានជួយធ្វើឱ្យតម្រូវការក្នុងការធ្វើសំវិធានធនស្ថិតក្រោមការគ្រប់គ្រងបាន។

កំណើនប្រាក់ចំណេញសុទ្ធរបស់ធនាគារពាណិជ្ជបានជួយជំរុញដល់ការងើបឡើងវិញនៃកម្រិតអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE) ក្នុងឆ្នាំ២០២១ (ក្រាហ្វ ២.២៧)។ ជាក់ស្តែង ROE បានកើនពី ៨,៧២% ក្នុងឆ្នាំ២០២០ ដល់ ៨,៩៥% ក្នុងឆ្នាំ២០២១

**២.២៦ ចំណូលនិងចំណាយ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.២៧ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មនិងដើមទុននៃធនាគារ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ស្របពេលដែល ROA បានកើនឡើង ៦ ពិន្ទុមូលដ្ឋាន ដល់ ១,៧% ក្នុងឆ្នាំ២០២១។ ការកើន-ឡើងនេះត្រូវបានជំរុញដោយកំណើនខ្ពស់នៃប្រាក់ចំណូលសុទ្ធ (២៥%) ធៀបនឹងកំណើនយឺតនៃទ្រព្យសកម្មជាមធ្យម (២០,៩%) និងមូលនិធិភាគទុនិក (២១,៩%) របស់គ្រឹះស្ថានធនាគារពាណិជ្ជ។

ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ធនាគារពាណិជ្ជ ដែលវាស់តាមការចំណាយលើប្រតិបត្តិ-ការនិងប្រាក់ចំណូលប្រតិបត្តិការដុល បានកើនឡើងដល់ ៤៥,២% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ២.២៨)។ ការចំណាយលើប្រតិបត្តិការនិងប្រាក់ចំណូលប្រតិបត្តិការដុលបានកើនឡើងក្នុងកម្រិតប្រហាក់ប្រហែលគ្នា ប៉ុន្តែកម្រិតខ្ពស់ជាងនៃប្រាក់ចំណូលប្រតិបត្តិការបានជួយជំរុញដល់អនុបាតនេះ។

**២.២៨ អនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយនៃធនាគារ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារបន្តមានកម្រិតខ្ពស់ និងខ្ពស់ជាងកម្រិតកំណត់ដោយធនាគារជាតិនៃកម្ពុជា។ ធនាគារពាណិជ្ជបន្តរក្សាបានកម្រិតខ្ពស់នៃដើមទុន ដោយអនុបាតសាធនភាព (CAR) ជារួមមានកម្រិត ២៣% ដែលបានថមថយបន្តិចពី ២៣,២% កាលពីឆ្នាំ២០២០ (ក្រាហ្វ ២.២៩)។ ការណ៍នេះបានគាំទ្រដោយកំណើនលឿនជាងនៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ (២៦%) ក្នុងឆ្នាំ២០២១ ធៀបនឹងកំណើននៃដើមទុន (២៥%)។ បើទោះជាបានថយចុះបន្តិចក្តី អនុបាតសាធនភាពរបស់ធនាគារដែលជាសូចនាករបង្ហាញពីលទ្ធភាពរបស់ធនាគារក្នុងទប់ទល់នឹងហានិភ័យ មានកម្រិតខ្ពស់ជាងកម្រិតកំណត់អប្បបរមា ១៥%។ ជាក់ស្តែង អនុបាតដើមទុនថ្នាក់ទី១មានកម្រិតប្រមាណ ២០% ខ្ពស់ជាងកម្រិតកំណត់អប្បបរមាសម្រាប់ដើមទុនជារួម។ លើសពីនេះ ទ្រនាប់

**២.២៩ ស្ថានភាពដើមទុន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដើមទុនខនសេរ៉ីវសិន (CCB) មានកម្រិត ១,២៥% ក្នុងឆ្នាំ២០២១ បន្ទាប់ពីត្រូវបានកាត់បន្ថយពី ២,៥% កាលពីខែឧសភា ឆ្នាំ២០២០ ដែលជាផ្នែកមួយនៃវិធានការឆ្លើយតបរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីជួយដល់គ្រឹះស្ថានធនាគារក្នុងការទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩។ កាលពីខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើ-ប្រាស់បរិមាណទាំងស្រុង (១០០%) នៃទ្រនាប់ដើមទុនខនសេរ៉ីវសិន និងបរិមាណសំវិធានធនមួយផ្នែកទៀតសម្រាប់ការរៀបចំឥណទានឡើងវិញ។

ការបែងចែកដើមទុនសរុបបានបង្ហាញថា ស្របពេលដែលដើមទុនថ្នាក់ទី១និងទី២មានកំណើនវិជ្ជមាន ដើមទុនថ្នាក់ទី២មានកំណើនខ្ពស់ជាងបន្តិច (២៩,៦% និង ២៧% រៀងគ្នា)។ ជាលទ្ធផល ការរួមចំណែកនៃដើមទុនថ្នាក់ទី២បានកើនឡើងដល់ ១៣% នៃដើមទុនសរុបរបស់ធនាគារ បើទោះជាដើមទុនថ្នាក់ទី១បន្តរួមចំណែកធំជាងគេ (៨៧%)។ ភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារមានកម្រិតរឹងមាំ ដែលគាំទ្រជាចម្បងដោយដើមទុនថ្នាក់ទី១មានគុណភាពល្អបានបន្តគាំទ្រដល់សមត្ថភាពរបស់ប្រព័ន្ធធនាគារក្នុងការទប់ទល់ក្នុងស្ថានភាពវិបត្តិ រួមទាំងការថមថយនៃកំណើនសេដ្ឋកិច្ចដែលបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩។

អនុបាតឥណទានមិនដំណើរការធៀបនឹងដើមទុនរបស់ធនាគារដែលជាសូចនាករបង្ហាញពីលទ្ធភាពរបស់ដើមទុនក្នុងការទប់ទល់នឹងឥណទានបាត់បង់ បានថយចុះសន្សឹមៗក្នុងរយៈពេលកន្លងមក ដោយបានធ្លាក់ចុះមកនៅត្រឹម ២,៩% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ២.៣០)។ បន្ថែមពីនេះ អនុបាតដើមទុនធៀបនឹងឥណទាន

**២.៣០ ភាពគ្រប់គ្រាន់នៃដើមទុន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សុទ្ធក៏បានបន្តថយចុះមកនៅត្រឹម ២៧,៧% ក្នុងឆ្នាំ២០២១ ដែលបង្ហាញពីទំហំនៃទ្រនាប់នៃដើមទុនដែលធនាគារមាន ក្នុងករណីដែលឥណទានមួយផ្នែកធំក្លាយជាឥណទានបាត់បង់។ សូចនាករទាំងពីរនេះបានជំរុញដល់ភាពគ្រប់គ្រាន់នៃដើមទុនឆ្លុះបញ្ចាំងតាមរយៈអនុបាតភាពគ្រប់គ្រាន់នៃដើមទុន។

## ២.៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ទោះបីជាមានផលប៉ះពាល់ពីការរាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ គ្រឹះស្ថានថ្មីៗត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការផងដែរ ដែលនាំឱ្យមានកំណើនទ្រព្យសកម្មក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ នៅចុងឆ្នាំ២០២១ ទ្រព្យសកម្មសរុបក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើង ៧,៣% ដល់ ៣៧,១ ទ្រីលានរៀល ធៀបនឹងកំណើន -៣,៧% ក្នុងឆ្នាំ២០២០ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) បានរួមចំណែក ៨៦,១% នៃទ្រព្យសកម្មសរុបនៅក្នុងវិស័យនេះ។ ទ្រព្យសកម្មរបស់ MDIs កើនឡើង ៥,៤% ដល់ ៣២ ទ្រីលានរៀល ហើយទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFIs) បានកើនឡើង ២០,៦% ដល់ ៥,១ ទ្រីលានរៀល (ក្រាហ្វ ២.៣១)។

**២.៣១ ទ្រព្យសកម្មក្នុងវិស័យមីក្រូហិរញ្ញវត្ថុ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ក. ប្រតិបត្តិការឥណទាន

ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩វិស័យមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុវិស័យកសិកម្ម និងសហគ្រាសធុនតូច និងមធ្យម។ ឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានចំនួន ៣១,៧ ទ្រីលានរៀល កើនឡើង ១៥,២% ធៀបនឹង ១២,៤% ក្នុងឆ្នាំ២០២០ ដែលអង្គភាពគ្រួសារបានរួមចំណែកធំជាងគេ (៦,១%) ការជួញដូរនិងពាណិជ្ជកម្ម (៥,៥%) កសិកម្ម (១,៤%) សេវាកម្ម (០,៧%) និងផ្សេងៗ ទៀត (១,៥%) (ក្រាហ្វ ២.៣២)។

**២.៣២ ការរួមចំណែករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំពោះតាមវិស័យ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឥណទានទៅអង្គភាពគ្រួសារនៅតែជាចំណែកធំជាងគេ ប្រមាណ ៣២,៤% នៃឥណទានសរុបរបស់វិស័យមីក្រូហិរញ្ញវត្ថុ បន្ទាប់មកពាណិជ្ជកម្ម ២៣% កសិកម្ម ១៨% សេវាកម្ម ១៩,៥% និងផ្សេងៗទៀត (ក្រាហ្វ ២.៣៣)។ តម្រូវការឥណទានកើនឡើង ជាពិសេសនៅក្នុងពេលដែលសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមបើកដំណើរការវិញ ហើយតម្រូវការទីផ្សារ និងឱកាសអាជីវកម្មកាន់តែមានភាពច្បាស់លាស់បន្ថែមទៀត ជាចម្បងទៅលើទុនបង្វិល។

២.៣៣ ចំណែកឥណទានមីក្រូហិរញ្ញវត្ថុតាមវិស័យ



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. គុណភាពឥណទាន

វិស័យមីក្រូហិរញ្ញវត្ថុបានរក្សានូវគុណភាពឥណទានរបស់ខ្លួន ក្នុងអំឡុងពេលមានការរាលដាលនៃជំងឺកូវីដ-១៩។ អនុបាតឥណទានមិនដំណើរការសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងក្នុងឆ្នាំ២០២១ ពី ១,៨% ក្នុងឆ្នាំ២០២០ ដល់ ២,៤% តែនៅមានកម្រិតទាបនៅឡើយ (ក្រាហ្វ ២.៣៤)។ យ៉ាងណាក៏ដោយ ផលប៉ះពាល់ទៅដល់អាជីវកម្ម និងការបាត់បង់ការងារនិងប្រាក់ចំណូល ដោយសារការបិទខ្ទប់និងវិធានការគម្លាតសង្គមក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ អាចនឹងដាក់សម្ពាធលើលទ្ធភាពសងត្រលប់របស់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពគ្រួសារជាច្រើនដែលធ្វើការក្នុងវិស័យក្រៅផ្លូវការ។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនេះ ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញរហូតដល់ខែមិថុនា ឆ្នាំ២០២២។ ទោះបីជាសំពៀតឥណទាននៅមានគុណភាពល្អ ធនាគារជាតិនៃកម្ពុជានៅតែបន្តការត្រួតពិនិត្យ ហើយតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើការវាយតម្លៃលើសំពៀតឥណទានរបស់ខ្លួន ដើម្បីចៀសវាងផលប៉ះពាល់លើដើមទុន នៅពេលដែលវិធានការគាំទ្រត្រូវបានដកចេញ។

២.៣៤ គុណភាពឥណទាន



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ. ស្ថានភាពសន្ទនីយភាព និងមូលនិធិ

ទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ MDIs បានរក្សាសន្ទនីយភាពខ្ពស់ក្នុងការទប់ទល់នឹងហានិភ័យផ្សេងៗ ដែលអាចឆ្លុះបញ្ចាំងតាមរយៈអនុបាតក្របខ័ណ្ឌសន្ទនីយភាពខ្ពស់ជាងកម្រិតបទប្បញ្ញត្តិអប្បបរមា ជាមួយនឹងវិធានការគាំទ្រពីធនាគារជាតិនៃកម្ពុជា។ អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ MDIs មានកម្រិត ១៦០% ដែលលើសពីកម្រិតបទប្បញ្ញត្តិ ១០០% ប៉ុន្តែបានថយចុះពី ២៤០,៤% ក្នុងឆ្នាំ២០២០ (ក្រាហ្វ ២.៣៥)។ ការថយចុះនៃអនុបាតក្របខ័ណ្ឌសន្ទនីយភាពមួយចំណែកដោយសារការកើនឡើងតម្រូវការឥណទាន ស្របពេលដែលការបិទខ្ទប់បានបន្ធូរបន្ថយ ហើយសកម្មភាពសេដ្ឋកិច្ចបានងើបឡើងវិញ។

**២.៣៥ អនុបាតក្របខ័ណ្ឌសន្ទនីយភាពគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំពោះប្រភពមូលនិធិ ប្រាក់បញ្ញើដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រមូលនិធិរបស់ MDIs ដោយបានរួមចំណែក ៥៥% នៃមូលនិធិសរុប ខណៈប្រាក់កម្ចី និងដើមទុនរួមចំណែក ២៨% និង ១៧% រៀងគ្នា។ សម្រាប់ MFIs មូលនិធិភាគច្រើនបានមកពីប្រភពផ្សេងៗ រួមមានជំនួយទ្វេភាគី និងពហុភាគី ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ (ក្នុងនិងក្រៅប្រទេស) និងវិនិយោគិន។ ដូច្នេះ ប្រភពមូលនិធិរបស់ MFIs ពឹងផ្អែកចម្បងលើប្រាក់កម្ចីដែលមានចំណែក ៦០% ខណៈដើមទុនមានចំណែក ៤០% (ក្រាហ្វ ២.៣៦)។

**២.៣៦ ប្រភពមូលនិធិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹមឆ្នាំ២០២១ មូលនិធិកម្ចីសរុបនៃវិស័យមីក្រូហិរញ្ញវត្ថុមានចំនួន ១១,៥ ទ្រីលានរៀល បានថយចុះ ១,២% ធៀបនឹងឆ្នាំ២០២០។ សមាមាត្រមូលនិធិកម្ចីរយៈពេលវែងធៀបនឹងមូលនិធិកម្ចីសរុបក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងពី ៨១,៧% ក្នុងឆ្នាំ២០២០ ដល់ ៨៦,៣% នៅក្នុង២០២១។ មូលនិធិកម្ចីរយៈពេលខ្លីបាន

**២.៣៧ មូលនិធិកម្ចីក្នុងវិស័យមីក្រូហិរញ្ញវត្ថុ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ថយចុះបន្តិចធៀបនឹងឆ្នាំមុន ដោយ MDIs និង MFIs ស្វែងរកមូលនិធិដែលមានស្ថិរភាពជាងមុន នៅពេលសេដ្ឋកិច្ចត្រលប់ទៅរកភាពប្រក្រតី (ក្រាហ្វ ២.៣៧)។ វិស័យមីក្រូហិរញ្ញវត្ថុបានទទួលមូលនិធិកម្ចីទាំងក្នុង និងក្រៅប្រទេស ដែលមូលនិធិកម្ចីក្នុងស្រុកមានចំនួន ២៧%។ ធៀបនឹងឆ្នាំ២០២០ មូលនិធិកម្ចីក្នុងស្រុកបានធ្លាក់ចុះ ៦,១% មកត្រឹម ៣,១ ទ្រីលានរៀល ខណៈដែលមូលនិធិកម្ចីបរទេសបានថយចុះបន្តិចមកត្រឹម ៨,៨ ទ្រីលានរៀល។ ការផ្តល់មូលនិធិកម្ចីពីអឺរ៉ុបបានកើនឡើង ១៥,៩% ពី ២,៨ ទ្រីលានរៀលក្នុងឆ្នាំ២០២០ ដល់ ៣,២ ទ្រីលានរៀលក្នុងឆ្នាំ២០២១ ស្មើនឹង ២៨% នៃមូលនិធិកម្ចីបរទេសសរុប (ក្រាហ្វ ២.៣៨)។

២.៣៨ កម្ចីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមប្រទេស ឆ្នាំ២០២១




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឃ. លទ្ធភាពស្វែងរកប្រាក់ចំណេញ

លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់វិស័យមីក្រូហិរញ្ញវត្ថុនៅរក្សាបានសុខភាពល្អ និងចីរភាព ដែលឆ្លុះបញ្ចាំងដោយការកើនឡើងនៃតម្រូវការឥណទាន ស្របពេលដែលសេដ្ឋកិច្ចមានភាពប្រសើរឡើង។ ប្រាក់ចំណេញរបស់ MDIs បានកើនឡើងបន្តិច គាំទ្រដោយចំណូលពីការប្រាក់ និងស្ថិរភាពចំណាយប្រតិបត្តិការ។ ការចំណាយលើសំវិធានធនបានកើនឡើងបន្តិច ដែលភាគច្រើន មកពីការកើនឡើងនៃសំវិធានធន ដោយ MDIs បានធ្វើការវាយតម្លៃលើឥណទានរៀបចំឡើងវិញ យោងតាមសារាចរណែនាំរបស់ធនាគារជាតិកម្ពុជា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ (ក្រាហ្វ ២.៣៩)។

២.៣៩ ប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

MFIs បន្តមានចំណាយប្រតិបត្តិការខ្ពស់ ដោយប្រតិបត្តិការនៅពឹងផ្អែកលើការអនុវត្តបែបប្រពៃណីនៅឡើយ។ យ៉ាងណាមិញ កំណើនចំណូលការប្រាក់បានជួយទប់ទល់នឹងកំណើនចំណាយនេះ ធ្វើឱ្យមានភាពចំណេញ។ ប្រហាក់ប្រហែលនឹង MDIs ការចំណាយលើសំវិធានធន MFIs ក៏កើនឡើងបន្តិចដែរ (ក្រាហ្វ ២.៤០) ។

២.៤០ ប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) ជាមធ្យមសម្រាប់ MDIs នៅរក្សាស្ថិរភាពប្រមាណ ៣% ខណៈ ROA របស់ MFIs មានការថយចុះពី ១,៩% ក្នុងឆ្នាំ២០២០ មកត្រឹម ១,២% ក្នុងឆ្នាំ២០២១។ លើសពីនេះ អនុបាតប្រាក់ចំណេញធៀបនឹងដើមទុន (ROE) ជាមធ្យមសម្រាប់ MDIs បានកើនឡើងបន្តិចពី ១៤,៨% ក្នុងឆ្នាំ២០២០ ដល់ ១៥,៩% ខណៈ ROE សម្រាប់ MFIs បានធ្លាក់ចុះពី ៤,៥% មកត្រឹម ៣,១% (ក្រាហ្វ ២.៤១)។

២.៤១ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អនុបាតប្រសិទ្ធភាពនៃប្រតិបត្តិការជាមធ្យមរបស់ MDIs មានភាពប្រសើរឡើងវិញក្នុងកម្រិត ៤២,៦% ក្នុងឆ្នាំ២០២១ ពី ៤៦,៨% ក្នុងឆ្នាំ២០២០ ដោយ MDIs បានទាញយកអត្ថប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of scale) និងប្រសិទ្ធភាពការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ខណៈពេលដែល MFIs នៅតែមានអត្រាខ្ពស់ជាងនៅ ៦៤,៨% ដោយសារប្រតិបត្តិការមានលក្ខណៈបែបប្រពៃណីនៅឡើយ (ក្រាហ្វ ២.៤២)។

២.៤២ អនុបាតប្រសិទ្ធភាពប្រតិបត្តិការ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. ស្ថានភាពដើមទុន

វិស័យមីក្រូហិរញ្ញវត្ថុបានបន្តមានភាពធន់ដោយ MDIs និង MFIs រក្សាកម្រិតដើមទុនខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ (១៥%)។ អនុបាតសាធនភាព (CAR) របស់ MDIs បានថយចុះបន្តិចពី ១៩,៨% ក្នុងឆ្នាំ២០២០ មកត្រឹម ១៨,២% ក្នុងឆ្នាំ២០២១ តែខ្ពស់ជាងកម្រិតមុនពេលកូវីដ-១៩ ខណៈដែល CAR របស់ MFIs មានភាពប្រសើរឡើងវិញពី ៣៨,៩% ក្នុងឆ្នាំ២០២០ ដល់ ៤០,៧% ក្នុងឆ្នាំ២០២១ (ក្រាហ្វ ២.៤៣)។ ការថយចុះបន្តិចនៃ CAR របស់ MDIs បានឆ្លុះបញ្ចាំងពីការកើនឡើងនៃទ្រព្យសកម្មថ្លឹងតាមកម្រិតហានិភ័យ (កើន ១២% ធៀបនឹងឆ្នាំ២០២០) ដោយតម្រូវការឥណទានកើនឡើង។

២.៤៣ ស្ថានភាពដើមទុន




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់៖ ២.១**

## ការរៀបចំឥណទានឡើងវិញ៖ ជួយសម្រួលបន្ទុកដល់ប្រជាជន ចំពេលមានការរាលដាលនៃជំងឺកូវីដ-១៩

នៅខែមីនា ឆ្នាំ២០២០ វលកជំងឺកូវីដ-១៩ បានចាប់ផ្តើមរីករាលដាលនៅប្រទេសកម្ពុជា។ សកម្មភាពសេដ្ឋកិច្ចមានការថយចុះ ដោយសារការរឹតត្បិតការធ្វើដំណើរនិងការដាក់គម្លាតសង្គម ដែលមានផលប៉ះពាល់ដល់លទ្ធភាពសងបំណុលរបស់អតិថិជន។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំស្តីពីឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ក្នុងគោលបំណងជួយដល់អតិថិជនដែលបានជួបប្រទះការធ្លាក់ចុះចំណូល និងមានការលំបាកក្នុងការសងប្រាក់កម្ចី។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានណែនាំឱ្យរៀបចំឥណទានឡើងវិញសម្រាប់អតិថិជនក្នុងវិស័យចម្បងចំនួន៤៖ វិស័យទេសចរណ៍ សំណង់ កាត់ដេរ និងដឹកជញ្ជូន។ ប៉ុន្តែដោយសារការរីករាលដាលជំងឺកូវីដ-១៩នៅតែបន្ត ការរៀបចំឥណទានឡើងវិញត្រូវបានអនុញ្ញាតសម្រាប់វិស័យទាំងអស់ដែលរងផលប៉ះពាល់នៅចុងឆ្នាំ២០២០។

បន្ទាប់ពីចេញសារាចរណែនាំនៅខែមេសា ឆ្នាំ២០២០ ប្រព័ន្ធធនាគារមានឥណទានរៀបចំឡើងវិញចំនួន ១០៦.៦១៣ គណនី ស្មើនឹង ៦,១ ទ្រីលានរៀល។ បន្ទាប់មក ឥណទានរៀបចំឡើងវិញ បន្តកើនឡើងដោយចំនួនគណនី ២៥៤.៣០២ គណនី និងទំហំទឹកប្រាក់ ១៦,៤ ទ្រីលានរៀល នៅចុងឆ្នាំ២០២០ (ក្រាហ្វ ក និង ខ)។

ទោះបីជាការបិទខ្ទប់ និងរឹតត្បិតការធ្វើដំណើរ ត្រូវបានដាក់នៅឆ្នាំ២០២០ កម្ពុជាទើបតែមានការឆ្លងរាលដាលទ្រង់ទ្រាយធំក្នុងសហគមន៍នៅដើមឆ្នាំ២០២១ ដែលត្រូវបានហៅថាព្រឹត្តិការណ៍ ២០-កុម្ភៈ។ ជាលទ្ធផល ព្រឹត្តិការណ៍នេះបានធ្វើឱ្យការរឹតត្បិតការធ្វើដំណើរកាន់តែតឹងរ៉ឹង និងមានកន្លែងមួយចំនួនត្រូវបានដាក់ក្នុងតំបន់ចត្តាឡីស័កខណៈដែលសកម្មភាពសេដ្ឋកិច្ចត្រូវបានផ្អាកម្តងទៀត។ ជាលទ្ធផល ឥណទានរៀបចំឡើងវិញបានបន្តកើនឡើងនៅត្រីមាសទី២ ឆ្នាំ២០២១ រហូតដល់ ៣៨៨.០៨៤ គណនី ស្មើ ២២,៣ ទ្រីលានរៀលនៅខែមិថុនា ឆ្នាំ២០២១។ ការរៀបចំឥណទានឡើងវិញនៅតែបន្តនៅត្រីមាសទី៣ ឆ្នាំ២០២១

**ក ចំនួនគណនីឥណទានរៀបចំឡើងវិញ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ខ ចំនួនឥណទានរៀបចំឡើងវិញ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប៉ុន្តែបានថយមកវិញនៅត្រីមាសទី៤ ដោយការឆ្លងក្នុងសហគមន៍ស្ថិតក្នុងសភាពអាចគ្រប់គ្រងបាននិងសកម្មភាពសេដ្ឋកិច្ចបន្តឡើងវិញដោយសារនយោបាយជំរុញការចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាល។ នៅចុងឆ្នាំ២០២១ ឥណទានរៀបចំឡើងវិញថយចុះដល់ ៣១០.៧៩៦ គណនី ស្មើ ២០,១ ទ្រីលានរៀល។ គួររំលេចថា MDIs បានរៀបចំឥណទានឡើងវិញច្រើនជាងគេចំនួន ១៣៥.២២០ គណនី គិតត្រឹមឆ្នាំ២០២១ ខណៈធនាគារពាណិជ្ជ រៀបចំឥណទានឡើងវិញតិចជាងគេ តែមានទំហំទឹកប្រាក់ធំជាងគេចំនួន ១៦,៦ ទ្រីលានរៀល។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានរៀបចំឥណទានឡើងវិញដល់វិស័យអាទិភាពទាំង៤ ក្នុងនោះវិស័យទេសចរណ៍មានចំនួន ២៧.២៣០ គណនី វិស័យកាត់ដេរចំនួន ៤៧.៦៨៦ គណនី វិស័យសំណង់ចំនួន ២៨.១៩២ គណនី វិស័យដឹកជញ្ជូននិងឡូជីស្ទិកចំនួន ១៦.៧៣០ គណនី និងវិស័យផ្សេងៗចំនួន ១៩០.៩០៨ គណនី (ក្រាហ្វ គ) នៅចុងឆ្នាំ២០២១។ បើគិតជាទំហំទឹកប្រាក់ វិស័យទេសចរណ៍មានចំនួន ៣,៨ ទ្រីលានរៀល វិស័យកាត់ដេរមានចំនួន ០,៧ ទ្រីលានរៀល វិស័យដឹកជញ្ជូននិងឡូជីស្ទិកមានចំនួន ១ ទ្រីលានរៀល និងវិស័យផ្សេងៗមានចំនួន ១១,៧ ទ្រីលានរៀល (ក្រាហ្វ ឃ)។ គួរឱ្យកត់សម្គាល់ថា វិស័យទេសចរណ៍បានទទួលអត្ថប្រយោជន៍ធំជាងគេបើគិតជាទំហំទឹកប្រាក់ឥណទានរៀបចំឡើងវិញ បើទោះបីវិស័យកាត់ដេរមានចំនួនគណនីឥណទានរៀបចំឡើងវិញច្រើនជាងក៏ដោយ។

**គ** ចំនួនគណនីឥណទានរៀបចំឡើងវិញតាមវិស័យ ក្នុងឆ្នាំ២០២១




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ឃ** ចំនួនឥណទានរៀបចំឡើងវិញតាមវិស័យក្នុងឆ្នាំ២០២១




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៤ ធនាគារឯកទេស

ធនាគារឯកទេសត្រូវបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តសកម្មភាពមូលដ្ឋានមួយក្នុងចំណោមប្រតិបត្តិការចម្បងទាំងបី (ការផ្តល់ប្រាក់កម្ចី ការទូទាត់ និងការប្រមូលប្រាក់បញ្ញើ) ដូចដែលបានចែងក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ បច្ចុប្បន្ន ធនាគារឯកទេសភាគច្រើនផ្តោតតែលើការសម្របសម្រួលផ្នែកហិរញ្ញប្បទានទៅដល់វិស័យសេដ្ឋកិច្ច ដោយហេតុនេះធនាគារឯកទេសមិនមានការទទួលប្រាក់បញ្ញើ និងសេវាទូទាត់ទេ។ នៅចុងឆ្នាំ២០២១នេះ ទ្រព្យសកម្មសរុបរបស់ធនាគារឯកទេសមានប្រមាណ ២,៦ ទ្រីលានរៀល ធ្លាក់ចុះ -២១,៨% ធៀបនឹងឆ្នាំ២០២០ ត្រឹម ៣,៤ ទ្រីលានរៀល (ក្រាហ្វ ២.៤៤)។ ការធ្លាក់ចុះនៃទ្រព្យសកម្មសរុបក្នុងឆ្នាំ២០២១ នេះ ដោយសារធនាគារឯកទេសមួយបានប្រែក្លាយខ្លួនទៅជាធនាគារពាណិជ្ជ។

**២.៤៤ ទ្រព្យសកម្មសរុប**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ធនាគារឯកទេសបានផ្តល់ឥណទានដល់វិស័យផ្សេងៗ ក្នុងនោះតម្រូវការផ្ទាល់ខ្លួន (មិនរាប់បញ្ចូលកម្ចីទិញផ្ទះ)មាន ៨០%នៃឥណទានសរុប ខណៈការលក់រាយ និងកម្ចីទិញផ្ទះមានចំនួន ៤% បន្ថែមទៀត។ ចំណែកឥណទានក្នុងវិស័យអចលនទ្រព្យមានត្រឹមតែ ២% ប៉ុណ្ណោះ។ ក្នុងឆ្នាំ២០២១ កំណើនឥណទានបានធ្លាក់ចុះ -២៤,៨% ដោយសារការថយចុះនៃចំនួនគ្រឹះស្ថាន។ យ៉ាងណាក៏ដោយ វិស័យសំខាន់ៗនៅក្នុងសេដ្ឋកិច្ចមានអត្រាកំណើន ដោយឥណទានសម្រាប់វិស័យកម្មន្តសាល ការលក់ដុំ និងសណ្ឋាគារ និងភោជនីយដ្ឋានបានកើនឡើង ២១,៣% ១៩,៥% និង ៥៩,៦% រៀងគ្នា ធៀបនឹងកំណើនអវិជ្ជមានក្នុងឆ្នាំ២០២០ បន្ទាប់ពីវិធានការទប់ស្កាត់ និងរឹតបន្តឹងការធ្វើដំណើរត្រូវបានបន្ធូរបន្ថយបន្តិចម្តងៗ (ក្រាហ្វ ២.៤៥)។

**២.៤៥ កំណើនឥណទានតាមវិស័យ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

នាពេលថ្មីៗនេះ អនុបាតឥណទានមិនដំណើរការជាមធ្យមរបស់ធនាគារឯកទេសកើនឡើងពី ៦,៥% ក្នុងឆ្នាំ២០២០ ទៅ ៩,១% ក្នុងឆ្នាំ២០២១។ ការកើនឡើងនេះក៏ដោយសារសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចាប់ផ្ដើមវាយតម្លៃ លើលទ្ធភាពសងត្រលប់របស់អតិថិជន និងធ្វើចំណាត់ថ្នាក់ មុនពេលដែលវិធានការគាំទ្រដែលបានដាក់ចេញកាលពីមុនត្រូវផុតកំណត់។

បើទោះជាមានការរីករាលដាលជំងឺកូវីដ-១៩ ធនាគារឯកទេសនៅតែរក្សាបានភាពគ្រប់គ្រាន់នៃដើមទុន ជាមួយនឹងដើមទុនខ្ពស់ជាងកម្រិតបទប្បញ្ញត្តិអប្បបរមា ១៥%។ អនុបាតសាធនភាពមានកម្រិត ៣៧% ក្នុងឆ្នាំ២០២១ ធៀបនឹង ៤៦% ឆ្នាំ២០២០។ ជារួម ដើមទុនរបស់គ្រឹះស្ថានធនាគារឯកទេសមានភាពរឹងមាំក្នុងការអនុញ្ញាតឱ្យគ្រឹះស្ថានមានលទ្ធភាពទប់ទល់នឹងហានិភ័យដែលអាចកើតមាន (ក្រាហ្វ ២.៤៦)។

**២.៤៦ អនុបាតសាធនភាព និងអនុបាតឥណទានមិនដំណើរការ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់៖ ២.២

## វិធានការគាំទ្ររបស់ធនាគារជាតិនៃកម្ពុជាអំឡុងពេល ការរីករាលដាលជំងឺកូវីដ-១៩

ធនាគារជាតិនៃកម្ពុជាបានអនុវត្តវិធានការគាំទ្រមួយចំនួន ដើម្បីផ្តល់សន្ទនីយភាពបន្ថែមទៅក្នុងប្រព័ន្ធធនាគារ ក៏ដូចជាសម្រួលបន្ទុកដល់អ្នកខ្ចីប្រាក់។ វិធានការបឋមមានដូចខាងក្រោម៖

i/-រក្សាការអនុវត្តទ្រនាប់ដើមទុនខនសើរវេសិន (CCB) នៅត្រឹម ១,២៥% កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០២០

ii/-កាត់បន្ថយអត្រាការប្រាក់អប្បបរមារបស់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ០,៥០% សម្រាប់គ្រប់ឥណប្រតិទាន កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

iii/-កាត់បន្ថយអត្រាការប្រាក់របស់មូលបត្រអាចជួញដូរបាន (NCD) ចំពោះប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកក្នុងកម្រិតសមស្រប

iv/-កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច (RRR) ពី ៨% សម្រាប់ប្រាក់រៀល និងរូបិយប័ណ្ណបរទេសពី ១២,៥% មកត្រឹម ៧% ចំពោះគ្រប់រូបិយប័ណ្ណទាំងអស់សម្រាប់រយៈពេល ៦ខែ ចាប់ពីខែមេសា ឆ្នាំ២០២០ តទៅ

v/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញសម្រាប់អតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ (ប៉ុន្តែជាឥណទានដំណើរការ) នៅក្នុងវិស័យអាទិភាព និងវិស័យផ្សេងទៀតនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

vi/-ទទួលស្គាល់ប្រាក់ចំណេញសុទ្ធដែលបានធ្វើសវនកម្មប្រចាំត្រីមាស និងអនុញ្ញាតឱ្យរួមបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០

vii/-មិនអនុញ្ញាតឱ្យមានការបែងចែកភាគលាភដល់ភាគទុននិកសម្រាប់ប្រាក់ចំណេញដែលបានធ្វើសវនកម្មក្នុងឆ្នាំ២០២០។

នៅពេលដែលសេដ្ឋកិច្ចចាប់ផ្តើមងើបឡើងវិញបន្តិចម្តងៗ ធនាគារជាតិនៃកម្ពុជានៅតែបន្តអនុវត្តវិធានការដែលបានរៀបរាប់ខាងលើ ទន្ទឹមនេះ ក៏បានដាក់ចេញនូវយុទ្ធសាស្ត្រចាកចេញមួយចំនួន ក្នុងគោលបំណងការពារ Moral Hazard និងធានាការអភិវឌ្ឍប្រព័ន្ធធនាគារស្របតាមការងើបឡើងវិញនៃសេដ្ឋកិច្ច។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការបន្ថែមក្នុងឆ្នាំ២០២១ រួមមាន៖

i/-តម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើសំវិធានធន ផ្អែកលើការវាយតម្លៃលទ្ធភាពសងត្រលប់របស់អតិថិជនដែលទទួលបានការរៀបចំឥណទានឡើងវិញ ស្របតាមសារាចរណែនាំនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

ii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ប៉ុន្តែអតិថិជនដែលបានដាក់ស្នើសុំកាលពីខែមីនា ឆ្នាំ២០២០ កន្លងទៅ មិនអាចទទួលបានការផលប្រយោជន៍ក្នុងគ្រាថ្មីនេះទេ

iii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរក្សាទ្រនាប់ដើមទុនខនស៊ើវេសិនបានទាំងស្រុង

iv/-ហាមមិនឱ្យមានការបែងចែកភាគលាភដល់ភាគទុននិកសម្រាប់ប្រាក់ចំណេញដែលបានធ្វើសវនកម្មក្នុងឆ្នាំ២០២១ លើកលែងតែមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

v/-រក្សាអត្រាទុនបម្រុងកាតព្វកិច្ចត្រឹម ៧% រហូតដល់មានការណែនាំថ្មី។

# III វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

*ទីផ្សារភាគហ៊ុនកម្ពុជាបានបន្តអភិវឌ្ឍ ដោយមានក្រុមហ៊ុនចំនួនមួយបានចុះបញ្ជីជាលើកដំបូងនៅក្នុងទីផ្សារកំណើនសម្រាប់សហគ្រាសធុនតូចនិងមធ្យម (SMEs) បន្ទាប់ពីទីផ្សារនេះត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ២០១៥។ ទោះបីជាសកម្មភាពជួញដូរបានកើនឡើងធៀបនឹងឆ្នាំមុនក៏ដោយ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) និងមូលធនូបនីយកម្មទីផ្សារបានធ្លាក់ចុះ ដោយសារធនាគារអេស៊ីលីដា (ABC) បានដាក់ឱ្យជួញដូរបន្ថែមនូវភាគហ៊ុនរបស់ខ្លួនប្រមាណ ១៧ លានភាគហ៊ុន។ ទន្ទឹមនេះ ទីផ្សារមូលបត្របំណុលកម្ពុជានៅតែជាប្រភពហិរញ្ញប្បទានដ៏សំខាន់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាក្រុមហ៊ុនឯកជនផងដែរ។ ស្ថានភាពវិស័យធានារ៉ាប់រងបន្តមានភាពវិជ្ជមាន ដែលគាំទ្រដោយការកើនឡើងទាំងបុព្វលាភធានារ៉ាប់រងទូទៅនិងធានារ៉ាប់រងអាយុជីវិត។*

## ៣.១ ទីផ្សារទ្រព្យសកម្ម

### ក. ទីផ្សារមូលធន

សន្ទស្សន៍ផ្សារមូលបត្រកម្ពុជានិងមូលធនូបនីយកម្មទីផ្សារបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ធៀបនឹងឆ្នាំមុន។ នៅចុងឆ្នាំ២០២១នេះ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជាមានកម្រិត ៤៧៣,៤ សន្ទស្សន៍ ថយចុះ -២៦,៩% ពី ៦៤៨ សន្ទស្សន៍កាលពីឆ្នាំមុន (ក្រាហ្វ ៣.១)។ ការធ្លាក់ចុះនេះបណ្ដាលមកពីការធ្លាក់ថ្លៃនៃភាគហ៊ុនរបស់ធនាគារអេស៊ីលីដា (ABC) និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) ដោយបានថយចុះ -៣៨,៥% និង -៦,២% រៀងគ្នា។

**៣.១ ផ្សារមូលបត្រកម្ពុជា**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

មូលធនូបនីយកម្មទីផ្សារ បានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ដោយមានក្រុមហ៊ុនកាន់តែច្រើនបានចុះបញ្ជី ប៉ុន្តែបានថយចុះមកវិញតាមនិន្នាការរបស់ធនាគារអេស៊ីលីដា។ មូលធនូបនីយកម្មទីផ្សារបានថយចុះ -២៦,៩% ពី ៩,៨ ទ្រីលានរៀលនៅឆ្នាំ២០២១ មកត្រឹម ៧,២ ទ្រីលានរៀល ក្នុងនោះភាគហ៊ុនរបស់ធនាគារអេស៊ីលីដាមានចំនួន ៤,៦ ទ្រីលានរៀល (៦៣,៥% នៃមូលធនូបនីយកម្មទីផ្សារសរុប) (ក្រាហ្វ ៣.២)។

**៣.២ ទំហំមូលធនូបនីយកម្មទីផ្សារ**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា និង ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ទីផ្សារមូលធនកម្ពុជាមានភាពសកម្មក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងគួរឱ្យកត់សម្គាល់នៃការជួញដូរប្រចាំថ្ងៃ។ យោងតាមផ្សារមូលបត្រកម្ពុជា បរិមាណជួញដូរប្រចាំថ្ងៃជាមធ្យមបានកើនឡើង ៣៨១,៩% និងតម្លៃជួញដូរប្រចាំថ្ងៃជាមធ្យមបានកើនឡើង ១២៣,៩% ពី ៩៧៣,៩ លានរៀល ដល់១,១ ប៊ីលានរៀល (ក្រាហ្វ ៣.៣)។

សម្រាប់ទស្សនវិស័យ ទីផ្សារមូលធនកម្ពុជានឹងបន្តរីកចម្រើនជាលំដាប់។ ក្រុមហ៊ុនកាន់តែច្រើនត្រូវបានរំពឹងថានឹងចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា ដែលអាចអនុញ្ញាតឱ្យវិនិយោគិនទាំងក្នុងស្រុកនិងបរទេសមានជម្រើសនិងយុទ្ធសាស្ត្រពិពិធកម្មកាន់តែសម្បូរបែប។ ជាលទ្ធផល ការជួញដូរប្រចាំថ្ងៃត្រូវបានរំពឹងថានឹងបន្តមានភាពសកម្ម។ ចំណែកឯថ្លៃភាគហ៊ុនរបស់ធនាគារអេស៊ីលីដាអាចនឹងវិលមករកថ្លៃមុនពេលធ្វើនិយ័តកម្មរបស់ក្រុមហ៊ុន ASA ដូច្នេះសន្ទស្សន៍ផ្សារមូលបត្រកម្ពុជានឹងអាចកើនឡើងមកវិញ។

ទីផ្សារកំណើនបានបើកឱកាសសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីទទួលបានហិរញ្ញប្បទានបន្ថែម ដោយបានចាប់ផ្តើមពីការចុះបញ្ជីរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (DBDE)។ ក្រុមហ៊ុន DBDE គឺជាក្រុមហ៊ុនវិស្វកម្មនិងសំណង់ ដែលបានចុះបញ្ជីកាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១។ ក្រុមហ៊ុននេះបានបោះផ្សាយភាគហ៊ុនប្រមាណ ៦,៥ លានភាគហ៊ុន ដែលមានតម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូងចំនួន ២.៣៨០ រៀលក្នុងមួយភាគហ៊ុន។ កាលពីចុងឆ្នាំ២០២១ តម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន DBDE មានចំនួន ២.៣១០ រៀលក្នុងមួយភាគហ៊ុន (ក្រាហ្វ ៣.៤)។ ភាគជោគជ័យនៃការចុះបញ្ជីក្នុងទីផ្សារ

៣.៣ **ទំហំនិងតម្លៃជួញដូរជាមធ្យម**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

៣.៤ **តម្លៃភាគហ៊ុនក្រុមហ៊ុនឌី ប៊ី ឌី អ៊ិនជីនារីង**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

ភាគហ៊ុនរបស់ក្រុមហ៊ុន DBDE បានទាក់ទាញចំណាប់អារម្មណ៍ដល់សហគ្រាសធុនតូចនិងមធ្យមផ្សេងទៀត ក្នុងការស្វែងរកជម្រើសហិរញ្ញប្បទាន ដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួន។ ដូច្នេះ ទីផ្សារកំណើននឹងទាក់ទាញសហគ្រាសធុនតូចនិងមធ្យមបន្ថែមទៀត ដែលផ្តល់ជម្រើសកាន់តែច្រើនដល់វិនិយោគិនដែលមានកម្រិតទទួលយកហានិភ័យផ្សេងៗគ្នា។

**ប្រអប់ ៣.១**

## គួរអខ្គសំខាន់ក្នុងទីផ្សារភាគហ៊ុន ៖ ការប្រែប្រួលថ្លៃភាគហ៊ុនរបស់ធនាគារអេស៊ីលីដា

ធនាគារអេស៊ីលីដា គឺជាធនាគារដំបូងនៅប្រទេសកម្ពុជា ដែលបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ជាមួយនឹងតម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូងចំនួន ១៦.២០០ រៀល និងមានថ្លៃបិទទីផ្សារដំបូងចំនួន ១៦.៥០០ រៀល។ ចំនួនភាគហ៊ុនសរុបដែលបានចុះបញ្ជីមានចំនួន ៤៣៣.១៦៣.០១៩ ភាគហ៊ុន ក្នុងនោះ ៤.៣៤៤.៨៦៥ ភាគហ៊ុនបានបោះផ្សាយនៅផ្សារមូលបត្រកម្ពុជា (ក្រាហ្វ ក)។ នៅពេលបោះផ្សាយដំបូង ភាគហ៊ុនរបស់ធនាគារអេស៊ីលីដា (ABC) មានចំណែកធំជាងគេនៅក្នុងមូលធនូបនីយកម្មទីផ្សារ ដែលមានចំនួនទឹកប្រាក់ ៧,១ ទ្រីលានរៀល (៧៥% នៃមូលធនូបនីយកម្មទីផ្សារសរុប) និងបានកើនឡើងដល់ ៧,៤ ទ្រីលានរៀលនៅចុងឆ្នាំ២០២០ (ក្រាហ្វ ខ)។ បន្ទាប់មក តម្លៃភាគហ៊ុនរបស់ធនាគារអេស៊ីលីដាប្រែប្រួលជាមធ្យមក្នុងរង្វង់ ១៧.០០០ រៀល មុនពេលការធ្វើនិយ័តកម្មភាគហ៊ុន។

**ក** **តម្លៃភាគហ៊ុនរបស់ធនាគារអេស៊ីលីដា**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

**ខ** **មូលធនូបនីយកម្មទីផ្សារ**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ធនាគារអេស៊ីលីដាបានប្រកាសថា ក្រុមហ៊ុន អេ អេស អេ (ASA) ដែលជាភាគហ៊ុននិករបស់ខ្លួន នឹងយកភាគហ៊ុនចំនួន ១៦,២% នៃភាគហ៊ុនសរុបដែល ASA កាន់កាប់ ស្មើនឹងជាង ១៧ លានភាគហ៊ុន (៤% នៃភាគហ៊ុនសរុបរបស់ ABC) ដាក់ឱ្យធ្វើការជួញដូរ

នៅក្នុងផ្សារមូលបត្រកម្ពុជា។ ការផ្លាស់ប្តូរនេះធ្វើឡើងដើម្បីអនុញ្ញាតឱ្យបុគ្គលិកធនាគារអេស៊ីលីដាអាចជួញដូរភាគហ៊ុនរបស់ធនាគារបាននៅក្នុងផ្សារមូលបត្រកម្ពុជា។ ASA គឺជាភាគហ៊ុននិកធំទីពីររបស់ធនាគារអេស៊ីលីដា ដែលត្រូវបានបង្កើតឡើងដើម្បីដើរតួនាទីជាក្រុមហ៊ុនដែលមានភាគកម្ម (holding company) របស់ធនាគារ ដែលអនុញ្ញាតឱ្យបុគ្គលិកធនាគារនិងវិនិយោគិនពាក់ព័ន្ធ អាចទទួលបានអត្ថប្រយោជន៍ពីការរីកចម្រើន និងការកើនឡើងតម្លៃភាគហ៊ុនរបស់ធនាគារអេស៊ីលីដានៅក្នុងរយៈពេលវែង។

មុនពេលធ្វើនិយ័តកម្ម ASA បានកាន់កាប់ភាគហ៊ុនប្រមាណ ២៤,៨% នៃភាគហ៊ុនសរុបរបស់ ធនាគារអេស៊ីលីដា ស្មើនឹង ១០៧.២០៤.៥៤៧ ភាគហ៊ុន។ បន្ទាប់ពីការធ្វើនិយ័តកម្មរួច ASA នៅបន្តកាន់កាប់ភាគហ៊ុន ៨៩.៨៧៨.០២៦ ភាគហ៊ុន ឬ ២០,៨% នៃភាគហ៊ុនសរុបរបស់ធនាគារអេស៊ីលីដា ហើយតម្លៃភាគហ៊ុនចាប់ផ្តើមថយចុះបន្ទាប់ពីមានការផ្គត់ផ្គង់ភាគហ៊ុនក្នុងបរិមាណច្រើនទៅក្នុងទីផ្សារ។ នៅចុងឆ្នាំ២០២១ តម្លៃភាគហ៊ុនរបស់ធនាគារអេស៊ីលីបានធ្លាក់ចុះ -៣៥,១% ធៀបនឹងតម្លៃនៅថ្ងៃប្រកាសធ្វើនិយ័តកម្ម ពី១៦.២២០ រៀលក្នុងមួយភាគហ៊ុន មកត្រឹម ១០.៥២០ រៀលក្នុងមួយភាគហ៊ុន (ក្រាហ្វ ក)។

## ខ. ផ្សារមូលបត្របំណុល

ផ្សារមូលបត្របំណុលបានបន្តដើរតួនាទីជាប្រភពផ្តល់ហិរញ្ញប្បទានជារូបិយវត្ថុក្នុងស្រុក។ គិតត្រឹមចុងឆ្នាំ២០២១ មូលធនូបនីយកម្មទីផ្សារមានចំនួន ៥៤២,៤ ប៊ីលានរៀល ក្នុងនោះមូលបត្របំណុលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ៣៧៧,៩ ប៊ីលានរៀល (ប្រមាណ ៦៩,៧% នៃមូលធនូបនីយកម្មទីផ្សារសរុប) (ក្រាហ្វ ៣.៥)។ ការណ៍នេះឆ្លុះបញ្ចាំងពីតួនាទីនៃផ្សារមូលបត្របំណុលក្នុងការផ្តល់នូវប្រភពហិរញ្ញប្បទានរយៈពេលវែងបន្ថែម សម្រាប់វិស័យធនាគារ។ ក្នុងចំណោមមូលបត្របំណុលដែលមានឥណប្រតិទានរយៈពេល ៣ឆ្នាំ មូលបត្របំណុលរបស់ធនាគារ ABA ផ្តល់ទិន្នផលទីផ្សារខ្ពស់ជាងគេប្រមាណ ១០% ខណៈដែលមូលបត្របំណុលរបស់ក្រុមហ៊ុនអ អិម អេ ផ្តល់ទិន្នផលទីផ្សារខ្ពស់ជាងគេចំនួន ៥,៥% សម្រាប់មូលបត្របំណុលដែលមានឥណប្រតិទានរយៈពេល ៥ឆ្នាំ (ក្រាហ្វ ៣.៦)។

**៣.៥ មូលធនូបនីយកម្មទីផ្សារមូលបត្របំណុល**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**៣.៦ ផលចំណូលពីមូលបត្របំណុល**




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

នៅឆ្នាំ២០២១ ក្រុមហ៊ុន តែលកូ ថេក ដែលជាក្រុមហ៊ុនទូរគមនាគមន៍ បានចុះបញ្ជីថ្មីនៅក្នុងទីផ្សារមូលបត្របំណុល។ ក្រុមហ៊ុននេះបានបោះផ្សាយមូលបត្របំណុលសាជីវកម្មជារូបិយវត្ថុដែលមានឥណប្រតិទានរយៈពេល ៥ឆ្នាំ ចំនួន ៨០០.០០០ ឯកតា ដែលមានតម្លៃ ៨០ ប៊ីលានរៀល និងផ្តល់អាត្រាគូប៉ុង ៨,៥% ក្នុងមួយឆ្នាំ ព្រមទាំងទូទាត់ការប្រាក់ត្រលប់មកវិញរៀងរាល់ ៦ខែម្តង។ នៅចុងឆ្នាំ២០២១ ធនាគារពាណិជ្ជចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២ ក្រុមហ៊ុននាំចេញ-នាំចូលចំនួន ១ និងក្រុមហ៊ុនទូរគមនាគមន៍ចំនួន ១ បានចុះបញ្ជីនៅក្នុងផ្សារមូលបត្របំណុល។ ទោះបីជាចំនួនក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលបានកើនឡើងក៏ដោយ ក៏ផ្សារមូលបត្របំណុលនៅតែមិនទាន់មានភាពសកម្មជួញដូរនៅឡើយ ដោយវិនិយោគិនជាច្រើនមានបំណងរក្សាមូលបត្របំណុលរបស់ពួកគេរហូតដល់ឥណប្រតិទាន។ គួរកត់សម្គាល់ថា មូលបត្របំណុលសាជីវកម្មដែលបានបោះផ្សាយដោយធនាគារហត្ថា ដែលជាក្រុមហ៊ុនបោះផ្សាយមូលបត្រសាជីវកម្មដំបូងគេ បានឈានដល់ឥណប្រតិទាននៅខែវិច្ឆិកា ឆ្នាំ២០២១។

## ៣.២ វិស័យធានារ៉ាប់រង

វិស័យធានារ៉ាប់រងបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត។ បុព្វលាភសរុបបានកើនឡើង ១០,២% ដល់ ១,២ ទ្រីលានរៀលនៅឆ្នាំ២០២១ (ក្រាហ្វ ៣.៧)។ សំណងធានារ៉ាប់រងសរុបបានកើនឡើង ១២,១% ដល់ ១៦៤,៧ ប៊ីលានរៀល ខណៈដែលអនុបាតការផ្តល់សំណង (ការផ្តល់សំណងធានារ៉ាប់រងធៀបនឹងបុព្វលាភធានារ៉ាប់រងសរុប) បានកើនឡើងពី ១៣,៦% ដល់ ១៣,៨% (ក្រាហ្វ ៣.៨)។

៣.៧ បុព្វលាភធានារ៉ាប់រង




ប្រភព៖ សមាគមធានារ៉ាប់រងនៃកម្ពុជា

បុព្វលាភធានារ៉ាប់រងអាយុជីវិតបានកើនឡើង ១១,៨% ដល់ ៦៩៣,៧ ប៊ីលានរៀល ដែលត្រូវបានគាំទ្រជាចម្បងដោយការលក់កិច្ចសន្យាទាយជ្ជទាន (៨,២% នៃកំណើនសរុប) និងការលក់ធានារ៉ាប់រងអាយុជីវិតជាក្រុម (៣,៩%)។ កិច្ចសន្យាទាយជ្ជទានមានចំណែកធំជាងគេនៅក្នុងបុព្វលាភធានារ៉ាប់រងអាយុជីវិត ដែលស្មើនឹង ៧៩,៨% នៃបុព្វលាភសរុប បន្ទាប់មកគឺធានារ៉ាប់រងអាយុជីវិតជាក្រុម (១២,៥%) និងធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ (៥,៣%) (ក្រាហ្វ ៣.៩)។ លើសពីនេះចំនួនកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតសម្រាប់ធុរកិច្ចថ្មីបានកើនឡើង ៣,៨% ពី ១៣៣.៦៤៨ ដល់ ១៣៨.៦៦២ ស្របពេលដែលចំនួនកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតបន្តជាថ្មីបានកើនឡើង ៨,៩% ពី ៣៤២.៣២២ ដល់ ៣៧២.៩៣៨។ អនុបាតការផ្តល់សំណងបានកើនឡើងពី ៤,៥% ដល់ ៦,៣% ខណៈដែលការផ្តល់សំណងធានារ៉ាប់រងអាយុជីវិតបានកើនឡើង ៥៤,៦% ដល់ ៤៣,៤ ប៊ីលានរៀល។

បុព្វលាភធានារ៉ាប់រងទូទៅបានកើនឡើង ៨,២% ដល់ ៥០១,៥ ប៊ីលានរៀល ដែលត្រូវបានរួមចំណែកជាចម្បងដោយធានារ៉ាប់រងសុខភាព (៥,៤% នៃកំណើនសរុប) ធានារ៉ាប់រងផ្សេងៗ (០,៩%) និងធានារ៉ាប់រងយានយន្ត (០,៨%)។ លើសពីនេះ ធានារ៉ាប់រងលើទ្រព្យសម្បត្តិឬអគ្គិភ័យ មានចំណែកធំជាងគេនៅក្នុងបុព្វលាភធានារ៉ាប់រងទូទៅដល់ ៣៣,១% បន្ទាប់មកគឺធានារ៉ាប់រងសុខភាព (២២,១%) និងធានារ៉ាប់រងយានយន្ត (១៦,៦%) (ក្រាហ្វ ៣.១០)។ អនុបាតការផ្តល់សំណងបានថយចុះពី ២៥,៦% មកត្រឹម ២៤,២% ហើយការផ្តល់សំណងសម្រាប់ធានា-រ៉ាប់រងទូទៅ បានកើនឡើង ២% ពី ១១៨ ប៊ីលានរៀល ដល់ ១២១,៣ ប៊ីលានរៀល។

**៣.៨ ការផ្តល់សំណងសរុប (ប្រាក់រៀល)**




ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**៣.៩ សមាសធាតុបុព្វលាភធានារ៉ាប់រងអាយុជីវិត**




ប្រភព៖ សមាគមធានារ៉ាប់រងនៃកម្ពុជា

**៣.១០ សមាសធាតុបុព្វលាភធានារ៉ាប់រងទូទៅ**




ប្រភព៖ សមាគមធានារ៉ាប់រងនៃកម្ពុជា

# IV ប្រព័ន្ធទូទាត់សងប្រាក់៖ ការអភិវឌ្ឍថ្មីៗ

*ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាបានអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ-១៩។ ចំនួនប្រជាជនវ័យក្មេងច្រើន អត្រាប្រើប្រាស់ទូរស័ព្ទចល័តនិងអ៊ីនធឺណិតខ្ពស់ និងក្របខ័ណ្ឌបទប្បញ្ញត្តិអំណោយផល បានលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ឱ្យប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយភាពច្នៃប្រឌិត ជាមួយនឹងទីតាំងភ្នាក់ងារផ្តល់សេវាជាច្រើនកន្លែងនៅទូទាំងប្រទេស ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ជាក់ស្តែង ទំហំទឹកប្រាក់ទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិកបានកើនឡើងជាលំដាប់រហូតដល់ជិត ៨ដងនៃផ.ស.ស ហើយចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនឡើងដល់ ១៣,៦ លានគណនី ដែលស្មើនឹងជាង ៨០% នៃចំនួនប្រជាជនសរុប។*

**ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាត្រូវបានអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេសប្រព័ន្ធទូទាត់អេឡិចត្រូនិក ហើយវិបត្តិកូវីដ-១៩ បានពន្លឿនការប្រើប្រាស់ប្រតិបត្តិការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់គួរឱ្យកត់សម្គាល់។** ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល ធនាគារជាតិនៃកម្ពុជាបានលើកទឹកចិត្តនិងគាំទ្រការច្នៃប្រឌិតក្នុងការផ្តល់សេវាហិរញ្ញវត្ថុឌីជីថល ដើម្បីកាត់បន្ថយការចំណាយ ជំរុញអន្តរប្រតិបត្តិការ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធទូទាត់ និងផាត់ទាត់ជាបន្តបន្ទាប់សម្រាប់ការទូទាត់ទាំងតម្លៃរាយនិងតម្លៃធំដើម្បីគាំទ្រដល់សេវាហិរញ្ញវត្ថុឌីជីថលដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស រួមមាន៖ ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធធនាគារអនឡាញ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធខេមបូឌានស៊ែស្វិច ប្រព័ន្ធរីថែលផេ និងប្រព័ន្ធបាគង (ក្រាហ្វ ៤.១)។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់ដុលភ្លាមៗកំពុងត្រូវបានអភិវឌ្ឍដើម្បីជួយសម្រួលដល់ប្រតិបត្តិការទូទាត់តម្លៃធំនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។

**៤.១ ប្រព័ន្ធទូទាត់សងប្រាក់របស់ធនាគារជាតិនៃកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានកើនឡើងគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងពីកំណើននៃការប្រើប្រាស់ និងជំនឿទុកចិត្តរបស់សាធារណជន។** នៅក្នុង២០២១ ការទូទាត់មូលប្បទានប័ត្រទាំងជាប្រាក់រៀលនិងដុល្លារអាមេរិកតាមប្រព័ន្ធផាត់ទាត់ជាតិ បានថយចុះទាំងទំហំទឹកប្រាក់និងចំនួនប្រតិបត្តិការ ប៉ុន្តែការទូទាត់ការបញ្ជាផ្ទេរឥណទានបានកើនឡើងដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងការដាក់វិធានការរឹតត្បិតបានលើកទឹកចិត្តអ្នកប្រើប្រាស់និងក្រុមហ៊ុនអាជីវកម្មប្រើប្រាស់និងទទួលយកប្រព័ន្ធទូទាត់សងប្រាក់ដោយគ្មានសាច់ប្រាក់។ ការដាក់ឱ្យប្រើប្រាស់ទាន់ពេលវេលានៃប្រព័ន្ធទូទាត់សងប្រាក់អេឡិចត្រូនិកថ្មីៗដោយធនាគារជាតិនៃកម្ពុជារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានជួយសម្រួលប្រតិបត្តិការទូទាត់សងប្រាក់ប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពជាពិសេសក្នុងអំឡុងពេលមានការរីករាលដាលជំងឺកូវីដ-១៩។ ជាក់ស្តែង ទំហំទឹកប្រាក់នៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក[១២] រួមទាំងប្រាក់រៀលនិងដុល្លារអាមេរិក បានកើនឡើង ៣៤,៥% ដល់ ៤១៥,៥ ទ្រីលានរៀល ស្មើនឹងប្រមាណ ៣,៨ដងនៃផ.ស.ស (ក្រាហ្វ ៤.២)។

**៤.២ ទំហំទឹកប្រាក់នៃការទូទាត់រាយតាមអេឡិចត្រូនិក**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ចំនួនប្រជាជនវ័យក្មេងច្រើន អត្រាប្រើ-ប្រាស់ទូរស័ព្ទចល័តនិងអ៊ីនធឺណិតខ្ពស់ និងការគាំទ្រផ្នែកក្របខ័ណ្ឌបទប្បញ្ញត្តិ បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អភិវឌ្ឍនិងធ្វើទំនើបកម្មសេវាកម្មទូទាត់ឌីជីថលប្រកបដោយភាពច្នៃប្រឌិតជាមួយនឹងចំនួនភ្នាក់ងារជាច្រើននៅទូទាំងប្រទេស។** គិតត្រឹមឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានផ្តល់សេវា

[១២] រួមបញ្ចូលប្រតិបត្តិការទូទាត់តាមរយៈគណនីកាបូបអេឡិចត្រូនិក សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត និងប្រព័ន្ធបាគង។

ទូទាត់សងប្រាក់ចំនួន ៣០ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ២ ដែលផ្តោតជាសំខាន់លើការផ្តល់សេវាទូទាត់សងប្រាក់ឌីជីថលតាមរយៈកម្មវិធីទូរស័ព្ទ និងភ្នាក់ងារផ្តល់សេវា (ចំនួន ៤៦.២៧៨ ទីតាំង) ដែលបានរួមចំណែកយ៉ាងសំខាន់ដល់បរិយាបន្នហិរញ្ញវត្ថុ។ អតិថិជនជាង ១៣,៦ លាននាក់បានចុះឈ្មោះប្រើប្រាស់គណនីកាបូបអេឡិចត្រូនិក (e-wallet) ស្របពេលដែលអតិថិជនជាច្រើនអាចទៅប្រើប្រាស់សេវាដោយផ្ទាល់នៅតាមបណ្តាញភ្នាក់ងារណាមួយដើម្បីធ្វើប្រតិបត្តិការផ្សេងៗ ដូចជា ការទូទាត់វិក្កយបត្រ និងការផ្ទេរប្រាក់ជាដើម (អតិថិជន ១០៦,២ លាននាក់បានទៅប្រើប្រាស់សេវាទូទាត់ដោយផ្ទាល់នៅតាមភ្នាក់ងារនៅឆ្នាំ២០២១) ដែលអនុញ្ញាតឱ្យអ្នកមិនធ្លាប់បានប្រើប្រាស់សេវាធនាគារ អាចទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការក្នុងតម្លៃសមរម្យ (ក្រាហ្វ ៤.៣)។ នៅឆ្នាំ២០២១ ទំហំទឹកប្រាក់សរុបនៃការទូទាត់តាមប្រព័ន្ធអ៊ីនធឺណិតដោយប្រើគណនីកាបូបអេឡិចត្រូនិក បានកើនឡើង ១៧,៣% ដល់ជិត ២០០ ទ្រីលានរៀល ជាមួយនឹងប្រតិបត្តិការសរុបចំនួន ៣៤៣,៨ លាន (ក្រាហ្វ ៤.៤)។

ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការទទួលយកយ៉ាងឆាប់រហ័សក្នុងចំណោមសាធារណជន ក៏បានលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកាន់តែច្រើនធ្វើការអភិវឌ្ឍ និងផ្តល់សេវាធនាគារអ៊ីនធឺណិត (internet banking) និងសេវាធនាគារចល័ត (mobile banking) ដើម្បីឱ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារឌីជីថលយ៉ាងទូលំទូលាយ ដូចជា ការទូទាត់សងឥណទាន ការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ សេវាបញ្ចូលទឹកប្រាក់ទូរស័ព្ទ ការបើកប្រាក់បៀវត្សរ៍ និងការពិនិត្យមើលសមតុល្យនៅក្នុងគណនី ជាដើម។ នៅឆ្នាំ២០២១ ទំហំទឹកប្រាក់នៃការទូទាត់តាម

៤.៣ ចំនួនគណនីកាបូបអេឡិចត្រូនិកដែលចុះបញ្ជី ចំនួនអតិថិជន និងចំនួនភ្នាក់ងារ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

៤.៤ ទំហំនិងទឹកប្រាក់នៃប្រតិបត្តិការតាមកាបូបអេឡិចត្រូនិក




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សេវាធនាគារអ៊ីនធឺណិតបានកើនឡើងជិត ២ដង ដល់ ៩០,១ ទ្រីលានរៀល ជាមួយនឹងប្រតិបត្តិការ ចំនួន ៤,៤ លាន ហើយការទូទាត់តាមសេវាធនាគារ ចល័តបានកើនឡើង ២៨,៦% ដល់ ២៨,៩ ទ្រីលាន រៀល ដោយមានប្រតិបត្តិការសរុបចំនួន ២៥៤,១ លាន (ក្រាហ្វ ៤.៥)។

ជាមួយគ្នានេះ ការប្រើប្រាស់ប័ណ្ណទូទាត់ បានកើនឡើងជាលំដាប់ ដោយប័ណ្ណទូទាត់ ប្រមាណ ១០,៦ លានត្រូវបានចេញផ្សាយ។ នៅ ឆ្នាំ២០២១ ទំហំទឹកប្រាក់សរុបនៃការទូទាត់តាម ប័ណ្ណទូទាត់បានកើនឡើង ២០% ដល់ ៨៤,១ ទ្រីលានរៀល ជាមួយនឹងប្រតិបត្តិការ ១០៥,៣ លាន (ក្រាហ្វ ៤.៦)។ ដើម្បីសម្រួលដល់និន្នាការ កើនឡើងជាលំដាប់នៃការទូទាត់តាមប័ណ្ណទូទាត់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានដំឡើងម៉ាស៊ីន ATM ចំនួន ៣.៦៣៩ និងម៉ាស៊ីនឆូតកាត POS ចំនួន ៤៩.៤៣២ នៅទូទាំងប្រទេស។ ទន្ទឹមនេះ ការទូទាត់តាម QR កូដក៏បានកើនឡើងគួរឱ្យ កត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ ស្តង់ដារ KHQR កូដ ដើម្បីជួយសម្រួលដល់ការ ទូទាត់តាម QR កូដ ដែលអាចធ្វើអន្តរប្រតិបត្តិការ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជា លើកកម្ពស់ការតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយ ប្រទេសនៅក្នុងតំបន់។ នៅឆ្នាំ២០២១ ទំហំទឹក-ប្រាក់នៃការទូទាត់តាម QR កូដបានកើនឡើង ២,២ដង ដល់ ៩៥៣,៩ ប៊ីលានរៀល ដែលមាន ប្រតិបត្តិការសរុបចំនួន ៤,៤ លាន (ក្រាហ្វ ៤.៧)។

៤.៥ ទំហំទឹកប្រាក់នៃប្រតិបត្តិការសេវាធនាគារតាមអ៊ីនធើណិត និងសេវាធនាគារចល័ត




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

៤.៦ ទំហំនិងទឹកប្រាក់នៃការទូទាត់ដោយប្រើប្រាស់ប័ណ្ណទូទាត់




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

៤.៧ ទំហំជាទឹកប្រាក់និងចំនួនប្រតិបត្តិការនៃការទូទាត់តាម QR កូដ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់៖ ៤.១**

## ការអភិវឌ្ឍប្រព័ន្ធបាគង

ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់សងប្រាក់ផ្អែកលើបច្ចេកវិទ្យាប្លុកឆេន (blockchain) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការដោយធនាគារជាតិនៃកម្ពុជា នៅខែតុលា ឆ្នាំ២០២០។ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា DLT បាគងគឺជាប្រព័ន្ធទូទាត់កន្លោង ដែលមានគោលបំណងជួយសម្រួលអន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់សងប្រាក់ លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងលើកទឹកចិត្តឱ្យប្រើប្រាស់ការទូទាត់ដោយគ្មានសាច់ប្រាក់ជារូបិយវត្ថុជាតិ។

ប្រព័ន្ធនេះត្រូវបានទទួលស្គាល់ទាំងក្នុងតំបន់និងអន្តរជាតិ ថាជាប្រព័ន្ធទូទាត់របស់ធនាគារកណ្តាលដំបូងគេដែលប្រើបច្ចេកវិទ្យាប្លុកឆេន។ នៅខែមេសា ឆ្នាំ២០២១ សន្ទស្សន៍សកលនៃរូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល (CBDC global index) របស់ក្រុមហ៊ុន PwC បានផ្តល់ចំណាត់ថ្នាក់គម្រោងបាគងរបស់កម្ពុជា ជាគម្រោងរូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាលសម្រាប់ការទូទាត់រាយទីមួយនៅអាស៊ី និងទីពីរនៅលើពិភពលោក បន្ទាប់ពីគម្រោងប្រាក់សៃនដ៍ដុល្លាររបស់ប្រទេសបាហាមា។ លើសពីនេះ កាលពីខែមករា ឆ្នាំ២០២២នេះ ប្រព័ន្ធបាគងបានឈ្នះពានរង្វាន់ឆ្នើមស្តីពី ពានរង្វាន់សេវាកម្មនិងផលិតផលឆ្នើមប្រចាំឆ្នាំ២០២១ ពីទស្សនាវដ្តី Nikkei Asia សម្រាប់បច្ចេកវិទ្យាច្នៃប្រឌិត និងឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេស។

គិតត្រឹមឆ្នាំ២០២១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥៥ បានចូលរួមជាសមាជិកក្នុងប្រព័ន្ធនេះ ដែលក្នុងនោះគ្រឹះស្ថានចំនួន ២៧ បានដាក់ឱ្យដំណើរការជាផ្លូវការ ហើយសមាជិកចំនួន ២៨ ផ្សេងទៀតបាននិងកំពុងធ្វើសន្ធានកម្មប្រព័ន្ធ។ ទន្ទឹមនេះ ចំនួនគណនីដែលបានចុះឈ្មោះប្រើប្រាស់កម្មវិធីបាគង បានកើនឡើងដល់ ២៨៧.៥៥៨ គណនី ស្របពេលដែលចំនួនអតិថិជនជាច្រើនអាចប្រើប្រាស់ប្រព័ន្ធនេះដោយប្រយោលតាមរយៈកម្មវិធីទូរស័ព្ទចល័តរបស់គ្រឹះស្ថានសមាជិក។ នៅឆ្នាំ២០២១ ទំហំទឹកប្រាក់សរុបនៃប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងមានចំនួន ១៩,៣ ទ្រីលានរៀល ជាមួយនឹងប្រតិបត្តិការសរុបចំនួន ៨,២ លាន (ក្រាហ្វ ក)។

**ក ទំហំទឹកប្រាក់ ចំនួនប្រតិបត្តិការ និងចំនួនគណនីនៅក្នុងប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបាគង និងស្តង់ដារ KHQR កូដ បានសម្រួលអន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុក ព្រមទាំងបានលើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាព និងកាត់បន្ថយកម្រៃសេវា។ លើសពីនេះ ប្រព័ន្ធបាគងក៏បានជួយសម្រួលដល់ប្រតិបត្តិការទូទាត់ឆ្លងដែនផងដែរ បន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយធនាគារមេយប៊ែង ចាប់ពីខែសីហា ឆ្នាំ២០២១ មក ដែលអនុញ្ញាតឱ្យពលករធ្វើការនៅប្រទេសម៉ាឡេស៊ីអាចផ្ញើប្រាក់មកកម្ពុជាក្នុងតម្លៃទាប។ សម្រាប់ទិសដៅអនាគត ធនាគារជាតិនៃកម្ពុជានឹងពង្រីកការតភ្ជាប់ការទូទាត់ក្នុងតំបន់ ជាពិសេសជាមួយប្រទេសសមាជិកអាស៊ាន ដើម្បីជំរុញសមាហរណកម្មហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ សំដៅសម្រួលដល់ការទូទាត់ឆ្លងដែនសម្រាប់សកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ និងការផ្ទេរប្រាក់របស់ពលករនៅក្រៅប្រទេស ក៏ដូចជាការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ជាដើម។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើការប្រើប្រាស់ប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំ ដើម្បីពង្រឹងប្រសិទ្ធភាពនិងសុវត្ថិភាពនៃការទូទាត់ដុលនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ស្របតាមការអភិវឌ្ឍក្នុងតំបន់និងពិភពលោក។